ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 27-Mar-2012, 14:43
CMS/CFO: Kauv Keoratanak

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសង

**ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១២**

**ម៉ោង ០៩:០៣ នាទី**

**សវនាការលើកទី៤១**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍ *(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ *(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង) *(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ឌុច ផារី

លោក រ៉ូជ័រ ហ្វីលីព *(Mr.Roger PHILLIP)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

លោក វេង ហ៊ត់

លោក វីល្លៀម ស្មីត *(Mr. William SMITH)*

លោក ឌេល លីសាក់ *(Mr. Dale LYSAK)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ម៉ៃខល ផេសមិន

*(Mr. Michiel PESTMAN)*

លោក ហ្សាស្ពើ ប៉ៅ*(Mr Jasper PAUW)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកកែន

*(Arthur VERCKEN)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោកស្រី ស៊ីន សុវ៉ន

លោក វ៉ែន ពៅ

លោកស្រី ស៊ីន សុវ៉ន

កញ្ញា លី ម៉ាញៀន *(Ms.Lyma NGUYEN)*

លោក បាណាបេ ណេគុឺ *(Mr. Barnabé NEKUIE)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណា

# បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក វីល្លៀម ស្មីត | អង់គ្លេស |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក ម៉ៃខល ផេសមិន | អង់គ្លេស |
| លោក អាង ឧត្តម | ខ្មែរ |
| លោក អាកទួរ វែកគែន | បារាំង |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| កញ្ញា លី ម៉ាញឿន | អង់គ្លេស |
| លោក នួន ជា | ខ្មែរ |
| លោក កាំង ហ្គេកអ៊ាវ | ខ្មែរ |

# ឧបសម្ព័ន្ធ

## ការសួរសំណួរទៅសាក្សី លោក កាំង ហ្កេកអ៊ាវ ហៅ ឌុច

សួរបន្តដោយលោក វីល្លៀម ស្មីត ផ្តើមពី....... .......................................................................ទំព័រ ០២

## កិច្ចដំណើរការនីតិវិធី

[០៩:០៣:២៥]

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ តាមកាលវិភាគដែលបានគ្រោងទុកនៅថ្ងៃនេះ អង្គជំនុំជម្រះនឹងបន្តសវនាការស្តាប់សក្ខីកម្មសាក្សី កាំង ហ្កេកអ៊ាវ ហៅ ឌុច ដែលនឹងតការសួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញា។ ជាបន្តនេះ អង្គជំនុំជម្រះសូមផ្តល់វេទិកាទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី កាំង ហ្កេកអ៊ាវ ហៅ ឌុច។

ហើយសាជាថ្មីម្តងទៀត មុននឹងដំណើរការ សូមរំឭកសាក្សី សូមយកចិត្តទុកដាក់នៅក្នុងការនិយាយឲ្យបានយឺត ដើម្បីឲ្យការដេញដោលនេះមានប្រសិទ្ធភាព ហើយស្តាប់បានគ្រប់ជ្រុងជ្រោយទាំងបីភាសា។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[០៩:០៤:៤៣]

**លោក វីល្លៀម ស្មីត៖**

សូមជម្រាបសួរតុលាការ លោក លោកស្រីចៅក្រម ហើយនិងភាគីទាំងអស់នៅក្នុងរឿងក្តីនេះ។ ហើយជម្រាបសួរផងដែរ លោក កាំង ហ្កេកអ៊ាវ។ កាលពីថ្ងៃពុធ យើងបានបញ្ចប់សួរសំណួរមួយចំនួនអំពីទិដ្ឋភាពមួយចំនួននៃគោលការណ៍ទិតៀន និងស្វ័យទិតៀននៅក្នុងបក្សកុម្មុយនីស្តកម្ពុជា។ លោកបានពន្យល់អំពីវិធីដែលថា គោលការណ៍នោះគឺត្រូវបានយកទៅអនុវត្ត ហើយនិងនៅក្នុងកិច្ចប្រជុំជីវភាពផងដែរ ហើយក៏នៅក្នុង តាមវិធីមួយជាបន្តបន្ទាប់ ដើម្បីធានាថា សមាជិកបក្សកុម្មុយនីស្តកម្ពុជាបន្តកសាងខ្លួននៅក្នុងៗទិសដៅមួយត្រឹមត្រូវ នៅក្នុងបក្សកុម្មុយនីស្តកម្ពុជានោះ។ ហើយខ្ញុំក៏សូមសួរលោកអំពីសំណួរពីរបីទៀត ទាក់ទងនឹងបញ្ហានេះ បន្ទាប់មកហើយគឺយើងភ្ជាប់ទៅនឹងគោលការណ៍ ដែលថាគោលការជាមូលដ្ឋាននៃបក្សកុម្មុយនីស្តកម្ពុជា ជាលក្ខន្តិកៈបក្សនោះផងដែរ។ ហើយក៏នឹងយើងពិនិត្យទៅលើលក្ខណវិនិច្ឆ័យចូលជាសមាជិកនៃបក្សកុម្មុយនីស្តកម្ពុជា ហើយនិងភារកិច្ចរបស់គេ ថាតើសមាជិកមានតួនាទីអ្វីខ្លះ? ហើយជាពិសេសករណីយកិច្ចរបស់សមាជិកជាន់ខ្ពស់នៃបក្សកុម្មុយនីស្ត

កម្ពុជាដែលគេធ្វើការនៅក្នុងអង្គការដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជានោះ។

[០៩:០៦:២៤]

ហើយនៅទីបញ្ចប់ នៅថ្ងៃនេះ ខ្ញុំនឹងនិយាយអំពីទំនាក់ទំនង ជាខ្សែទំនាក់ទំនងរវាងសមាជិកនីមួយៗ ហើយនិងអង្គការចាត់តាំងនីមួយៗនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនោះ ហើយសូមឲ្យលោកពន្យល់អំពីវិធីថាតើសមាជិកហ្នឹង បុគ្គលម្នាក់ៗហ្នឹងទំនាក់ទំនងគ្នាដូចម្ដេចរវាងអង្គការចាត់តាំងផ្សេងៗនៅក្នុងបក្សកុម្មុយនីស្តកម្ពុជានោះ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរបន្តដោយលោក វីល្លៀម ស្មីត៖**

**ស៖** ដូច្នេះ ប្រសិនបើយើងអាចត្រឡប់ទៅចំណុចមួយ អំពីការប្រជុំធ្វើស្វ័យទិតៀននោះ ជាពិសេសនៅក្នុងការប្រជុំជីវភាពរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលធ្វើឡើងជារៀងរាល់ខែនោះ តើលោកអាចនិយាយបានទេ ថាតើការប្រជុំទាំងអស់នោះគេស្វ័យទិតៀន និងការទិតៀនហ្នឹងគឺត្រូវកត់ត្រាជាលាយលក្ខណ៍អក្សរ ឬក៏គ្រាន់តែជាវគ្គនិយាយផ្ទាល់មាត់ មិនបានកត់ត្រាជាកំណត់ហេតុអ្វីទេនោះបាទ?

[០៩:០៧:២៨]

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** ការប្រជុំជីវភាព ជាការទិតៀន និងស្វ័យទិតៀននេះ អត់មានបានកត់ត្រាជាកំណត់ហេតុអីទេ។ ដោយផ្នែកសន្និបាតហ្នឹងទើបបានកត់ត្រា។ ឯកសារនៅសល់ចាស់របស់ ស-២១ ព្រះរាជអាជ្ញាឃើញស្រាប់ហើយ មានកំណត់ហេតុនេះ។ នេះសូមបញ្ចប់ប៉ុណ្ណេះ។

**ស៖** នៅក្នុងលក្ខន្តិកៈនិយាយថា វគ្គស្វ័យទិតៀននោះគឺជាវិធីមួយ ដើម្បីតស៊ូ ដើម្បីកសាងបក្សពីផ្ទៃក្នុង ដើម្បីលុបបំបាត់ ហើយនិងកែមុខខ្សោយខ្លាំង ហើយនិងដើម្បីបំបាត់នូវភាពស្មុគស្មាញនៅក្នុងបក្ស តើលោកអាចពន្យល់តុលាការបានទេ ថាតើលក្ខន្តិកៈបក្សនេះគឺមានន័យដូចម្ដេចទាក់ទងទៅនឹងពាក្យថាការកែសម្រួល ហើយនិងការធ្វើម៉េចកុំឲ្យមានករណីសង្ស័យនៅក្នុងបក្សនោះ? តើពាក្យវា *"វារៀសខន់ព្យសិន"* គឺការសង្ស័យនានា ឬក៏ការភ័ន្តច្រឡំនានានោះវាមានន័យដូចម្ដេច?

[០៩:០៩:០៥]

**ឆ៖** កថាខណ្ឌទី៧ មាននិយាយមែនអំពីការភ័ន្តច្រឡំ។ ការភ័ន្តច្រឡំនេះ គឺជាការភ័ន្តច្រឡំផ្ទៃក្នុងបក្ស ក្នុងការយល់ដឹង។ ឧទាហរណ៍ ដូចរឿងមិត្ត ហ៊ី គាត់អនុវត្តភារកិច្ចរបស់គាត់ យកអ្នកទោស

ម្នាក់យកទៅកម្ទេចតាមភារកិច្ចរបស់គាត់។ តែវាដាច់ចម្លើយ។ ហ្នឹងជាការភ័ន្តច្រឡំរបស់មនុស្សម្នាក់ក្នុងកិច្ចប្រតិបត្តិ។ គេដោះស្រាយបានតាមការទិតៀន ស្វ័យទិតៀន ហើយនិងតាមមេជួយមតិ។

ដូច្នេះមិនមែនជាការភ័ន្តច្រឡំរវាងយើង និងខ្មាំងទេ។ កំហុសនេះជាកំហុសផ្ទៃក្នុងបក្ស កំហុសក្នុងការយល់ដឹង។ ខ្ញុំសូមបញ្ចប់ប៉ុណ្ណេះ។

[០៩:១០:០៧]

**ស៖** សូមអរគុណ។ យើងអាចនឹងចូលទៅដល់គោលការណ៍មួយទៀត លេខប្រាំបី ដែលនិយាយថា បក្សកុម្មុយនីស្តកម្ពុជាប្រកាន់ខ្ជាប់ទៅនឹងគោលការណ៍ ហើយនិងគោលជំហរឯករាជ្យ ម្ចាស់ការ ខ្លួនទីពឹងខ្លួន ខ្លួនកាន់កាប់វាសនាលើខ្លួនឯង។ នៅក្នុងបរិបទនៃលក្ខន្តិកៈនេះមានន័យថាដូចម្ដេច ការដែលប្រើពាក្យឯករាជ្យម្ចាស់ការនេះ បាទ?

**ឆ៖** ខ្ញុំបានអធិប្បាយរួចមកហើយថា បក្សកុម្មុយនីស្តកម្ពុជាប្លែកគេត្រង់គោលការណ៍ហ្នឹងមួយជាសំខាន់។ ឯករាជ្យម្ចាស់ការ គឺឯករាជ្យពីបក្សវៀតណាម ឯករាជ្យពីបក្សកុម្មុយនីស្តចិន ហើយក៏ឯករាជ្យអំពីនិរេតបក្សកុម្មុយនីស្ត ដែលម៉ាក្ស និងអង់ហ្គេល គាត់សរសេរនៅឆ្នាំ១៨៤៨ទៅទៀត។ គេច្បិចយកតែអ្វីដែលជាប់នឹងសភាពការណ៍ជាក់ស្ដែងនៅកម្ពុជា។ ឯករាជ្យម្ចាស់ការ គឺអ៊ីចឹង។

[០៩:១១:៥០]

**ស៖** រីឯការកាន់កាប់វាសនាដោយខ្លួនឯងនេះ តើមានន័យដូចម្ដេចនៅក្នុងបរិបទនៃលក្ខន្តិកៈបក្សនេះ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលឆ្លើយ។ សូមអញ្ជើញលោកមេធាវី!

**លោក ម៉ៃខល ផេសមិនៈ**

សូមជម្រាបសួរតុលាការ។ សូមអរគុណលោកប្រធាន ខ្ញុំមានការជំទាស់ពីរទៅនឹងសំណួរនេះ។ ទីមួយ សាក្សីហ្នឹងគឺត្រូវបានស្នើឲ្យធ្វើការបកស្រាយនូវលក្ខន្តិកៈ ដែលមិនគប្បីអនុញ្ញាតទេតាមដែលខ្ញុំដឹង។ បើសិនជាសហព្រះរាជអាជ្ញាសួរឲ្យគាត់បកស្រាយនោះ ដើម្បីឲ្យពន្យល់អត្ថន័យនោះ គឺថាសហព្រះរាជអាជ្ញាត្រូវសួរខុសពីហ្នឹង ដើម្បីប្រភពនៃចំណេះរបស់គាត់។ គាត់មិនមែនជាអ្នកជំនាញនៅក្នុងការយល់ដឹងពីលក្ខន្តិកៈបក្សទេ គាត់ជាសាក្សីធម្មតាតែប៉ុណ្ណោះ បើយើងពិនិត្យទៅ។

តាមដែលខ្ញុំដឹង នេះគឺជាលក្ខន្តិកៈ គឺអនុម័តទាំងពីឆ្នាំ១៩៧៦ ដែលខ្ញុំចង់ជម្រាបតុលាការថា

សូមឲ្យសហព្រះរាជអាជ្ញាសួរទាក់ទងទៅនឹងវគ្គទីមួយនៃសវនាការនេះ។ ខ្ញុំគិតថា សហព្រះរាជអាជ្ញាគប្បីតែពិនិត្យមើលថាតើលក្ខន្តិកៈនេះ គេអនុវត្តនៅក្នុងពេលវេលាដែលពាក់ព័ន្ធដែលត្រូវពិចារណា ថាតើវាមានគោលការណ៍ថ្មីអ្វីនៅក្នុងទីនោះ។ បាទ តើវាមានការកែប្រែទេ តើត្រូវយកមកអនុវត្តនៅក្នុងឆ្នាំ១៩៧៥ដែរឬទេ នៅពេលដែលគេធ្វើសេចក្តីសម្រេចដើម្បីយើងពិនិត្យមើលឲ្យឃើញច្បាស់។

ប្រសិនបើមិនបែបនោះទេ គឺថាការសួរសំណួរបែបនេះមិនមានសហប្រយោជន៍ដល់តុលាការទេ។ សូមអរគុណលោកប្រធាន ហើយនិងអង្គជំនុំជម្រះ។

[០៩:១៣:៥២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណមេធាវី។ សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក វីល្លៀម ស្មីត៖**

ខ្ញុំសូមជំទាស់ទៅនឹងការជំទាស់របស់មេធាវី។ គឺថា ទោះបីជាសាក្សីមិនមែនជាអ្នកសរសេរលក្ខន្តិកៈ ប៉ុន្តែគាត់បានរៀនសូត្រ គាត់បានបង្រៀន ហើយគាត់ក៏បានផ្តល់សក្ខីកម្មជាច្រើន។ ហើយគាត់តួនាទីរបស់គាត់ គឺថាគាត់ជាអ្នកអប់រំសមាជិកបក្សកុម្មុយនីស្តកម្ពុជា ហើយពន្យល់អំពីខ្លឹមសារអត្ថន័យអីចឹងហើយគឺថា យើងយល់ថាគាត់យល់ច្បាស់ គាត់ជាអ្នកដែលមានការយល់ដឹងច្បាស់ដែលអាចពន្យល់ថាតើពាក្យមួយៗមានអត្ថន័យនៅក្នុងនេះ។ ដូច្នេះហើយ ទើបបានជាយើងខ្ញុំសួរបែបនេះ គឺថាបើខុសពីគាត់ មិនមានអ្នកណាអាចពន្យល់ឲ្យច្បាស់ជាងនេះនោះទេ។ ទោះណាមានអ្នកជំនាញផ្សេងមកនោះ ក៏អាចនឹងបញ្ជាក់បន្ថែម។ ហើយខ្ញុំនឹងចង់ពិនិត្យមើលថា តើគោលការណ៍ទាំងអស់នេះត្រូវបានអនុវត្តមុនឆ្នាំ៧៦ដែរឬទេ? ហើយលោក នួន ជា ខ្លួនឯងនោះក៏បាននិយាយដែលថា គោលការណ៍ក៏បានធ្វើឡើងនៅក្នុង១៩៧៦ ហើយគោលការណ៍ហ្នឹងក៏ត្រូវបានចែងនៅក្នុងឆ្នាំ១៩៦០នោះដែរ។

ដូច្នេះភាពស៊ីសង្វាក់គ្នានេះ អំពីពាក្យពេចន៍ជាដើម។ មូលដ្ឋាននៃពាក្យពេចន៍ទាំងអស់ហ្នឹងក៏ត្រូវបានកំណត់ឡើងហើយមេធាវីការពារក៏បានបញ្ជាក់បែបនោះដែរ។ លោកចៅក្រមបានជ្រាបហើយថាសាក្សីបានបញ្ជាក់ពីខាងដើមថា ក្រៅពីការកែប្រែខ្លះនៅក្នុងលក្ខន្តិកៈនេះ ដែលទាក់ទងទៅនឹងសេចក្តីផ្តើម ឬក៏ការដាក់ឲ្យអនុវត្តនូវលក្ខខណ្ឌ ធាតុផ្សេងៗដែលគេប្រើនៅក្នុងឆ្នាំ១៩៧១ ហ្នឹង គោលការណ៍នៃលក្ខន្តិកៈនេះ គឺនឹងនិយាយដូចគ្នាដដែលទេ។ ដូច្នេះ ដើម្បីឲ្យលោក លោកស្រីចៅក្រមយល់ច្បាស់ថា តើលក្ខន្តិកៈនេះមានន័យដូចម្តេច? គឺថា អ្នកបង្រៀន ហើយអ្នករៀនសូត្រលក្ខន្តិកៈនៅពេលនោះ គឺមាន

តែសាក្សីរូបនេះឯងដែលគាត់អាចបំភ្លឺបាននោះ។ នេះជាទស្សនៈរបស់ខ្ញុំបាទ។

[០៩:១៦:១០]

**ប្រធានអង្គជំនុំ៖**

អញ្ជើញៗលោកមេធាវី!

**លោក ម៉ៃខល ផេសមិន៖**

ដោយនិយាយសង្ខេប ប៉ុន្តែខ្ញុំមិនយល់ មិនចាំទេដែលថាសាក្សីបញ្ជាក់ថា គោលការណ៍ពីរនៅក្នុងលក្ខន្តិកៈ ប៉ុន្តែខ្ញុំចាំថា នៅក្នុងកិច្ចប្រជុំដែលគេពន្យល់មកគាត់ទេ មិនមែនគាត់ជាអ្នកពន្យល់គេទេ។ នេះតាមខ្ញុំស្តាប់។ សហព្រះរាជអាជ្ញា តាមយកចម្លើយរបស់ខ្លួនទៅឱ្យសាក្សីពន្យល់ទៅវិញ។ ដូច្នេះគាត់គួរតែសួរទៅសាក្សីដែលថា លក្ខន្តិកៈឆ្នាំ១៩៧៦ នោះ គឺត្រូវបានអនុម័ត ហើយនឹងគឺយកមកអនុវត្តជាបន្ត គឺមិនធាត់ថយនោះទេ។ ខ្ញុំមិនឃើញថា មូលហេតុអីបានជាព្រះរាជអាជ្ញាយកថា អាច្បាប់ពីដើមនោះ ដូចគ្នាអាច្បាប់ថ្មីនេះ ខ្ញុំមិនយល់ទេ។ ដូច្នេះគឺគប្បីតែរកពន្លឺឱ្យឃើញនៅក្នុងចំណុចនេះ។ បាទសូមអរគុណ។

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:១៧:៣៩]

**ប្រធានអង្គជំនុំ៖**

សេចក្តីជំទាស់របស់មេធាវីអន្តរជាតិការពារក្តី នួន ជា គ្មានប្រសិទ្ធភាព។ សាក្សីត្រូវឆ្លើយតបទៅនឹងសំណួរដែលបានសួរចុងក្រោយដោយតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ។ ប្រសិនបើចាំ។ បើសិនជាមិនចាំនឹងសំណួរទេ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិអាចតាំងសំណួរនេះម្តងទៀត ដើម្បីឱ្យសាក្សីស្តាប់បាន និងយល់អំពីសំណួរដែលសួរ ដើម្បីគាត់ឆ្លើយតបបានជាក់ច្បាស់។

[០៩:១៨:២៣]

**សួរដោយលោក វីល្លៀម ស្មីត៖**

**ស៖** លោកសាក្សីតើលោកចាំសំណួរនោះទេ? បើមិនចាំខ្ញុំរំឭកឡើងវិញ។ នៅក្នុងលក្ខន្តិកៈដែលមានឃ្លាមួយនិយាយថាៗ បក្សកុម្មុយនីស្តកម្ពុជាប្រកាន់ខ្ជាប់នូវគោលការណ៍ នូវគោលជំហរឯករាជ្យម្ចាស់ការ។ តាមអ្វីដែលលោកបានរៀនលក្ខន្តិកៈហ្នឹងនៅក្នុងសម័យនោះ តើពាក្យនេះមានអត្ថន័យដូចម្តេច? សូមលោកជួយពន្យល់តុលាការបាទ។

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** ពាក្យ "ឯករាជ្យម្ចាស់ការ" នេះ ត្រូវបានបង្រៀនដល់បក្ខជនទាំងអស់ ហើយបក្ខជនទាំងអស់ក៏បានបង្រៀនដល់អង្គភាពរបស់ខ្លួនជាប់ជាហូរហែតាំងពីឆ្នាំ១៩៧១។ មុននោះ ខ្ញុំសូមមិននិយាយទេ ព្រោះខ្ញុំនៅជាប់គុកដាច់ឆ្ងាយពីចលនាទូទាំងប្រទេស ចលនាក្នុងសាខារបស់បក្ស។ បញ្ហា "ឯករាជ្យម្ចាស់ការ" នេះ ដូចខ្ញុំបានអត្ថាធិប្បាយអំមិញអ៊ីចឹង ពន្យល់អំមិញអ៊ីចឹង គឺឯករាជ្យពីបក្សពលករវៀតណាម ឯករាជ្យពីបក្សកុម្មុយនីស្តចិន ឯករាជ្យពីបក្សកុម្មុយនីស្តសហភាពសូវៀត។ ដូច្នេះ យើងម្ចាស់ការខ្លួនយើង យកលទ្ធិម៉ាក្ស-លេនីន យកមកច្នៃប្រឌិតឲ្យស្របតាមសភាពការណ៍កម្ពុជា ដើម្បីដឹកនាំជោគវាសនាបក្សប្រជាជនកម្ពុជាទៅរកទិសដៅមួយដែលយើងចង់បាន។ នេះគឺមានន័យអ៊ីចឹង។ នេះតាមដែលការខ្ញុំបានត្រូវបានគេបង្រៀន ហើយខ្ញុំបានយកទៅបង្រៀននៅក្នុងអង្គភាព ហើយដឹកនាំអនុវត្តរបៀបហ្នឹង។ នេះ គឺសូមជម្រាបបញ្ជាក់អ៊ីចឹង។

[០៩:២០:៣០]

**ស៖** សូមអរគុណដែលលោកបានបំភ្លឺពីតួនាទី អំពីការរៀនសូត្រ និងការបង្រៀនលក្ខន្តិកៈនេះ។ សំណួរមួយទៀត ពាក្យថា "ការធ្វើបដិវត្តន៍ខ្លួនឯង គឺដោយខ្លួនឯង កសាងខ្លួនដោយខ្លួនឯង" នោះតើមានន័យដូចម្ដេច? ពាក្យដែលថា បដិវត្តន៍-- ធ្វើបដិវត្តន៍ដោយខ្លួនឯងជាដាច់ខាតហ្នឹង។

**ឆ៖** សូមលោកសហព្រះរាជអាជ្ញារំឭក បញ្ជាក់អំពីកថាខណ្ឌខ្លះ ពីព្រោះការបកប្រែល្បឿនចុះល្បឿនឡើងបន្តិច។

**ស៖** បាទនៅក្នុងកថាខណ្ឌទីប្រាំបី ហើយខ្ញុំយល់ថា ពាក្យទាំងអស់នេះ នៅពេលដែលយើងមើលទៅ មើលនៅក្នុងផ្នែកផ្សេងៗនៃលក្ខន្តិកៈ ប៉ុន្តែវាមានការជាន់គ្នា។ មូលហេតុ ដែលខ្ញុំសួរលោកពីសំណួរនេះនោះ គឺថាយើងមើលនៅក្នុងបរិបទនៃកន្លែងដែលសរសេរនៅក្នុងលក្ខន្តិកៈ។ នៅក្នុងចំណុចទីប្រាំបីនេះ គឺថាបក្សកុម្មុយនីស្តកម្ពុជាប្រកាន់ខ្ជាប់នូវគោលជំហរឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួន ខ្លួនកាន់កាប់វាសនាដោយខ្លួនឯង បដិវត្តខ្លួនដោយខ្លួនឯងដាច់ខាត។ តើមានន័យដូចម្ដេចឃ្លានេះ? ត្រង់ពាក្យថា បដិវត្តខ្លួនដោយខ្លួនឯងដាច់ខាតនេះ។ បាទ នៅក្នុងទំព័រទីប្រាំមួយ ភាសាខ្មែរនៃលក្ខន្តិកៈ គឺបន្ទាត់ទីមួយ ដែលនិយាយថា "បដិវត្តខ្លួន ដោយខ្លួនឯងដាច់ខាត"។

[០៩:២២:៣៤]

**ឆ៖** ឃ្លានេះមិនដាច់គ្នាទេ។ ឃ្លានេះ វាជាប់គ្នា ដែលខ្ញុំសូមអានដូចតទៅ៖

ខ្លួនទីពឹងខ្លួន។ មួយឃ្លាទៀត គឺខ្លួនកាន់កាប់វាសនាបដិវត្តខ្លួនដោយខ្លួនឯងដាច់ខាត និងគ្រប់កាលៈទេសៈ។ ដូច្នេះ បានន័យថា គ្មានបក្សវណ្ណៈអធនណា មកបញ្ជាឲ្យយើងលើកមាគ៌ាតាមផលប្រយោជន៍របស់គេទេ។ យើងលើកមាគ៌ាបក្ស ទៅតាមផលប្រយោជន៍របស់បក្សកុម្មុយនីស្តកម្ពុជា ទៅតាមផលប្រយោជន៍របស់វណ្ណៈអធនកម្ពុជា ដោយខ្លួនយើង មិនមែនដោយចិន មិនមែនដោយយួននោះទេ។ នេះគឺមានន័យអ៊ីចឹង។ បើតាមការដែលខ្ញុំត្រូវបានបង្រៀន និងការដែលខ្ញុំបានបង្រៀនគេ។

**ស៖** សូមអរគុណ។ សំណួរចុងក្រោយដែលខ្ញុំសួរលោក ទាក់ទងទៅនឹងគោលការណ៍របស់បក្សកម្ពុជានោះ គឺនៅក្នុងគោលការណ៍ទីប្រាំបួន ចំណុចចុងក្រោយនៃចំណុចទីប្រាំបួននេះ គឺទាក់ទងទៅនឹងអ្វីដែលលោកបាននិយាយ ប៉ុន្តែនិយាយយ៉ាងច្បាស់ជាងនេះទៅទៀត។ ដូច្នេះ ខ្ញុំអាចអានជូនលោកហើយសួរ ថាតើលោកអាចបំភ្លឺតុលាការតាមការយល់ដឹងរបស់លោកអំពីពាក្យនេះ មានន័យដូចម្ដេចនោះ។ បក្សកុម្មុយនីស្តកម្ពុជាយល់យ៉ាងច្បាស់ពីភារកិច្ចរបស់ខ្លួនយ៉ាងធ្ងន់ គឺជាភារកិច្ចដ៏ខ្ពង់ខ្ពស់។ សមាជិកគ្រប់រូបត្រូវតែកសាង ហើយនិងបញ្ចូលនូវសាមគ្គី ហើយនិងឯកភាពនៅក្នុងបក្ស ដើម្បីឲ្យបក្សខ្លាំង ទាំងនយោបាយ ទាំងខាងសតិអារម្មណ៍ និងខាងការចាត់តាំងគ្រប់កាលៈទេសៈ។ ហើយត្រូវវាយសម្រុកដាច់-- សម្រុកជាប់ បាទ លត់ដុំជាប់ ដុតកំដៅជាប់ បំផុសបំផុលជាប់ វាយជំរុញជាប់ ក្នុងមហាចលនាបដិវត្តដ៏ក្ដៅគគុក និងដ៏ជ្រាលជ្រៅបំផុតរបស់មហាជន កម្មករ កសិករ ក្នុងសហជីព ហើយនិងបន្តទៅទៀត។ សំណួរចំពោះលោក តើៗឃ្លានេះជាឃ្លាដែលដាក់ភារកិច្ចដ៏ធ្ងន់ទៅដល់សមាជិកម្នាក់ៗ ដើម្បីជួយ ដើម្បីលើកកម្ពស់គោលដៅរបស់បក្សកុម្មុយនីស្តកម្ពុជាដែរឬទេ?

**ឆ៖** អរគុណ។ មុនដំបូងខ្ញុំសូមបញ្ជាក់ថា កថាខណ្ឌនេះ វាជាសេចក្ដីបញ្ចប់នៃផ្នែកទីមួយទាំងមូល មិនមែនជាសេចក្ដីបញ្ចប់នៃកថាខណ្ឌទី៩ទេ។ វាអធិប្បាយអំពីភារកិច្ចដ៏ឧត្តុង្គឧត្តម ដែលជាភារកិច្ចរបស់បក្ខជនម្នាក់ៗត្រូវតែធ្វើ។ បើយើងនិយាយថា ភារកិច្ច ខ្ញុំគិតថាវាមិនទាន់គ្រប់ទេ គួរណាស់តែនិយាយថា កាតព្វកិច្ចដែលបក្សប្រគល់ឲ្យ ប្រជាជនប្រគល់ឲ្យបក្ខជនគ្រប់រូប។ នេះខ្ញុំសូមឆ្លើយប៉ុណ្ណេះ។

[០៩:២៦:៣២]

**ស៖** ដោយយើងនឹងចូលទៅដល់គោលការណ៍មួយទៀត ដែលនិយាយអំពី នៅក្នុងលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ដែលៗគេយកទៅអនុវត្តមុនឆ្នាំ១៩៧៥។ សំណួរប្រសិនជា-- នេះប្រហែលជាលោកស្ដាប់មិនទាន់ គោលការណ៍នេះដែលនិយាយនៅក្នុងផ្នែកទីមួយនៃលក្ខន្តិកៈ ថាតើវាស្របទៅនឹងគោលការណ៍ក្នុងឆ្នាំ១៩៧១ ហើយនិងឆ្នាំ១៩៦០ ដែរឬទេ? តើលោកអាចឆ្លើយបានទេ បាទ?

**ផ៖** ខ្ញុំគិតថា ព្រះរាជអាជ្ញាលោកសួរខ្ញុំអំពីជំពូកពីរ មានលក្ខន្តិកៈ តើមែនទេ?

**ស៖** សូមភ័យទោសដែលខ្ញុំធ្វើឲ្យលោកច្រឡំ ហើយខ្ញុំសួរថា តើគោលការណ៍ទូទៅពីខាងដើម នៃលក្ខន្តិកៈនេះ វាដូចគ្នា ឬស្រដៀងគ្នា ឬ/ហើយស្របគ្នាទៅនឹងគោលការណ៍ទូទៅនៅក្នុងលក្ខន្តិកៈ បក្សពីមុនទេ ឆ្នាំ១៩៧១ បាទ?

**ផ៖** ខ្ញុំសូមអនុញ្ញាតនិយាយឲ្យបានក្បោះក្បាយ។ លក្ខន្តិកៈបក្សឆ្នាំ១៩៧១ និងលក្ខន្តិកៈបក្សឆ្នាំ ១៩៧៦ ប្លែកគ្នាតិចតួចណាស់ ស្ទើរតែអត់ក៏ថាបាន ដែលប្លែកគ្នាបន្តិច បើតាមខ្ញុំចាំ គឺអំពីកងទ័ព។ លក្ខន្តិកៈបក្សឆ្នាំ១៩៧៦ ចែងលម្អិតអំពីរឿងកងទ័ពបន្តិច។ ដោយឡែកខ្ញុំបានបញ្ជាក់ពីមុនរួចមកហើយ លក្ខន្តិកៈបក្សឆ្នាំ១៩៧១ និង៧៦ ដូចគ្នាត្រង់១០(ខ) ជ្រើសរើសកម្មាភិបាលនេះឯង ដែលប្លែកអំពី លក្ខន្តិកៈបក្សឆ្នាំ១៩៦០ ដែលគេគិតអំពីអតីតភាព។ បញ្ហាពីរនេះ ខ្ញុំចាប់អារម្មណ៍ ព្រោះខ្ញុំបានរៀន លក្ខន្តិកៈទាំងបីហ្នឹង។ ខ្ញុំឃើញប្លែកច្បាស់មុនគេ។ ឯចំណែក ផ្នែកទីមួយ នៃលក្ខន្តិកៈបក្សឆ្នាំ៧១ និង ៧៦ ខ្ញុំមិនអាចជម្រាបបានថា តើវាដូចគ្នានឹងលក្ខន្តិកៈបក្សឆ្នាំ១៩៦០ ឬអត់។ ខ្ញុំមិនអាចជម្រាបបានទេ ព្រោះខ្ញុំរៀនយូរហើយ ហើយនៅថ្មីពេក ខ្ញុំវង្វេងហើយ។ ខ្ញុំមិនអាចជម្រាបបានថា តើលក្ខន្តិកៈបក្សឆ្នាំ ១៩៦០ មានផ្នែកទីមួយនេះដែរឬអត់? ខ្ញុំសូមបញ្ជាក់ប៉ុណ្ណេះ។

[០៩:២៩:៤៧]

**ស៖** ឥឡូវនេះ យើងអាចពិនិត្យទៅលើភារកិច្ច និងតួនាទី ឬក៏លក្ខណៈសម្បត្តិក្នុងនាមជា បក្ខជនរបស់បក្សកុម្មុយនីស្ត។ ប្រសិនបើមើលមាត្រាទី១ គឺបានពន្យល់អំពីលក្ខណៈសម្បត្តិនៃការចូល រួមក្នុងបក្សកុម្មុយនីស្ត ហើយបានបញ្ជាក់នូវលក្ខណៈសម្បត្តិចំនួនពីរ។ ប៉ុន្តែមុននឹងយើង-- មុននឹងអាច បំពេញនូវលក្ខណៈសម្បត្តិទាំងពីរនេះបាន គឺមាននូវតម្រូវការមួយចំនួន មុននឹងអាចចូលរួមនៅក្នុងបក្ស កុម្មុយនីស្តបាន។ ហើយនៅក្នុងមាត្រាទី១ បានបញ្ជាក់ថា អ្នកដែលអាចចូលបក្សកុម្មុយនីស្តកម្ពុជាបាន គឺជាសមាជិកអង្គការស្នូលរបស់បក្ស។ ឧទាហរណ៍ យុវកសិ-- យុវកក និងបង្គោល អាចជាបុរសក្តី នារីក្តី ដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ ហើយដែលអាចបំពេញបាននូវប្រភេទលក្ខណៈសម្បត្តិពីរ យ៉ាងដូចតទៅ។ សំណួររបស់ខ្ញុំគឺថា តើលោកអាចពន្យល់ដល់តុលាការបានឬទេ? តើពាក្យ “យុវកក” ហ្នឹងមានន័យយ៉ាងម៉េច?

[០៩:៣២:១២]

**ផ៖** ស.យុវកក នេះមានន័យថា សម្ព័ន្ធយុវជនកុម្មុយនីស្តកម្ពុជា។

**សៈ** ហើយលោកយល់ថាតើគេបង្កើតនូវសម្ព័ន្ធយុវកកហ្នឹងនៅពេលណា? ហើយគេបង្កើតលក្ខណៈបែបណាដែរ?

**ឌុៈ** សូមបញ្ជាក់ថា "សម្ព័ន្ធយុវកក"នេះ វាមិន ខ្ញុំមិនដឹងជាកំណើតពីពេលណាមកទេ។ ក៏ប៉ុន្តែជាអង្គការមួយដែលគេជ្រើសរើសមនុស្ស ដែលគេជ្រើសរើសជនបដិវត្តន៍ ពីជនចម្រើន ពីអង្គការមហាជន ជាជនចម្រើន មកជាអង្គការសម្ព័ន្ធយុវកកសិន។ គេលត់ដំ ដាក់ភារកិច្ច គេតាមដានភារកិច្ចនេះមួយរយៈ ទើបបានគេបញ្ចូលយុវកកហ្នឹងមកជាបក្ខជន។ ដូច្នេះគេហៅថាជា ថ្នាល ឬក៏ជា អង្គការស្នូលរបស់បក្ស។ អង្គការស្នូល ដែលរំឭកក្នុងនេះមានពីរ ទីមួយគឺ យុវកក ទីពីរ គឺបង្គោល។ យុវកកហើយនិងបង្គោលខុសគ្នាយ៉ាងម៉េច? អ្នកណាដែលមានមុខរបរ ជាអនុធនអីហើយ គេមិនមិនបញ្ចូលយុវកកទេ ដែលមានអាយុលើសពី១៨ឆ្នាំហើយ គេមិនបញ្ចូលយុវកកទេ គេបញ្ចូលអង្គការបង្គោល ជនបង្គោល។ ជាក់ស្តែង ខ្ញុំ, អ៊ិន លន ហៅ ណាត ចូលអង្គការបង្គោលទេ អត់បានចូលយុវកកហ្នឹងគេទេ ព្រោះខ្ញុំមានប្រាក់ខែ មានលុយ មានកាក់ អាយុលើស១៨ឆ្នាំទៅហើយ។ នេះសូមបញ្ជាក់ប៉ុណ្ណេះ។

[០៩:៣៤:៤៨]

**សៈ** សូមអរគុណ។ ហើយប្រសិនបើយើងមើលមាត្រាទី២៦ នៃលក្ខន្តិកៈនេះ គឺបាននិយាយអំពីបក្សកុម្មុយនីស្តកម្ពុជា ហើយនិងបង្គោលនៅ-- ហើយនិងបង្គោលដែលជាអង្គការស្នូលរបស់បក្ស ដើរតួនាទីជាៗដៃស្តាំ និងកម្លាំងជំនួយបក្សក្នុងការអនុវត្តមាគ៌ានយោបាយ គោលជំហរសតិអារម្មណ៍ និងមាគ៌ាចាត់តាំងរបស់បក្សក្នុងមហាជនកម្មករ កសិករ និងកងទ័ពបដិវត្តន៍កម្ពុជា។ តើលោកអាចពន្យល់ដល់តុលាការបានឬទេ ថាតើទាំងអស់នេះ គឺជាតួនាទីរបស់បង្គោលរបស់យុវជនបង្គោលដែលលោកធ្លាប់ជាសមាជិកនៃអង្គការស្នូលរបស់បក្សនោះដែរឬទេ? គឺនៅក្នុងចុងនៃទំព័រ៥២ នៃឯកសារជាភាសាខ្មែររបស់លោក។

**ឌុៈ** មាត្រានេះចែងថា អង្គការស្នូលទាំងពីរអង្គការនេះ ជាសេនាដៃស្តាំរបស់បក្ស បញ្ហានេះត្រូវ។ ខ្ញុំត្រូវគេបញ្ជាឲ្យអនុវត្តបែបនេះជាហូរហែ។ ហើយដល់ក្រោយមក ខ្ញុំក៏ដឹកនាំ និងដាក់ភារកិច្ចឲ្យយុវកកនៅក្នុងមន្ទីរស-២១ ហើយនៅម-១៣ អនុវត្តតាមរបៀបនេះជាហូរហែ។

[០៩:៣៦:៤០]

**សៈ** តើលោកជាសមាជិកនៃអង្គការស្នូលហ្នឹងមានរយៈពេលប៉ុន្មាន មុននឹងពេលក្លាយទៅជាបក្ខជន?

**ឆ៖** ខ្ញុំស្ថិតនៅក្នុងជាអង្គការស្ងួលជាមួយ ណាត ជាមួយអ្នកផ្សេងទៀតនៅក្នុងឆ្នាំ១៩៦៥។ ហើយខ្ញុំចូលបក្សជាបក្ខជនត្រៀមនៅថ្ងៃ២៥ ធ្នូ ១៩៦៧។ ហើយខ្ញុំមកបំពេញសិទ្ធិនៅគុកធំ នៅថ្ងៃ២០ កក្កដា ១៩៦៩។

**ស៖** សូមអរគុណ។ ហើយបុរេលក្ខខណ្ឌបាន១ចែងថា បានន័យថា បុរេលក្ខខណ្ឌមួយនៅក្នុងលក្ខន្តិកៈនេះបានចែងថា បេក្ខជនត្រូវបំពេញនូវលក្ខណៈសម្បត្តិចំនួនពីរ បើសិនជាយើងមើលនៅមាត្រាមួយ១ គឺចំណុច(ក) គឺមានលក្ខណៈសម្បត្តិយ៉ាងតិចក៏ប្រាំ នៅក្នុងប្រភេទលក្ខណៈសម្បត្តិទីមួយ។ បានន័យថាយើងត្រូវមានហោចណាស់ក៏ប្រាំលក្ខណៈសម្បត្តិមុននឹងក្លាយជាបក្ស សមាជិកបក្សកុម្មុយនីស្ត។ ខ្ញុំចង់សួរលោកថាតើចំណុច(ក) ហ្នឹង បានន័យថាលក្ខន្តិកៈទាំងប្រាំហ្នឹង វាមានអ្វីខ្លះ? តើវាមានន័យយ៉ាងម៉េចខ្លះ? ឥឡូវយើងមើលទៅលើចំណុច(ក) ដែលបានចែងថា សមាជិកត្រូវមានសកម្មភាពប្រយុទ្ធល្អ និងជាប់ជានិច្ចតាមការសាកល្បងក្នុងការងារបដិវត្តន៍ជាបន្តបន្ទាប់ក្នុងសហជីព សហករណ៍ និងកងទ័ពបដិវត្តន៍ តាមមាគ៌ានយោបាយរបស់បក្ស តាមជំហរសតិអារម្មណ៍របស់បក្ស និងតាមមាគ៌ាចាត់តាំងរបស់បក្ស។

ដូច្នេះ សំណួរដែលខ្ញុំចង់សួរគឺថា តើចំណុចនេះមានន័យយ៉ាងម៉េចដែរ ដែលថាបក្សត្រូវមានសកម្មភាពប្រយុទ្ធល្អ និងជាប់ជានិច្ចតាមការសាកល្បង? តើចំណុចទាំងអស់នេះ ដែល១និយាយថាមានសកម្មភាពប្រយុទ្ធល្អ និងជាប់ជានិច្ចតាមការសាកល្បងនោះ វាមានន័យយ៉ាងដូចម្តេចដែរ?

[០៩:៣៩:២៩]

**ឆ៖** អ្នកដែលនៅក្នុងអង្គការស្ងួល ដើម្បីឲ្យក្លាយទៅជាបក្ខជន ត្រូវមានសកម្មភាពប្រយុទ្ធល្អ និងជាប់ជានិច្ច។ ប្រយុទ្ធល្អនេះ វាអាស្រ័យទៅតាមបរិបទសង្គម ដែលរស់នៅធ្វើសកម្មភាព។ ខ្ញុំជាសាស្ត្រាចារ្យមធ្យមសិក្សាបឋមភូមិនៅវិទ្យាល័យស្គន់ ដឹកនាំបានកូនសិស្សបាចខិត្តប័ណ្ណ។ បាចហើយបាចទៀត ពេលណាបក្សត្រូវការ។ ដូច្នេះប្រយុទ្ធជាប់ក្នុងបញ្ហានេះ ធ្វើសកម្មភាពពង្រីកជួររបស់ខ្លួនជាប់ ពង្រីកសីលធម៌របស់បក្សដែលត្រឹមត្រូវ ស្លូតបូត ទន់ភ្លន់ជាមួយមហាជនជាប់។ នេះហៅថាប្រយុទ្ធល្អក្នុងបរិបទប្រវត្តិសាស្ត្រសង្គម និងសង្គមជំនាន់នុំង ហើយលក្ខន្តិកៈនេះ និយាយអ្នកប្រតិបត្តិប្រយុទ្ធល្អជាប់ជានិច្ចក្នុងសហជីព និងក្នុងសហករណ៍ វាប្លែកគ្រង់នុងដែរ។ ដូច្នេះ យុវកក ហើយនិងជនបង្គោល នៅក្នុងសហករណ៍ត្រូវគិត តើបក្សឲ្យធ្វើស្អី? ជាប់មហាជនយ៉ាងម៉េច? ដឹកនាំប្រយុទ្ធជាប់ជានិច្ចយ៉ាងម៉េច? នេះវា១អាស្រ័យទៅតាមនុំង។ នេះខ្ញុំបញ្ចប់ការអធិប្បាយរបស់ដោយពាក់ព័ន្ធនឹងខ្លួន

ឯងបែបនេះ។

[០៩:៤១:០២]

**ស៖** ដូច្នេះដើម្បីឲ្យច្បាស់លាស់ លក្ខណៈសម្បត្តិទីមួយនៃ ប្រភេទលក្ខណៈសម្បត្តិទីមួយ មិនតម្រូវឲ្យសមាជិកហ្នឹងចូលរួមនៅក្នុងការប្រយុទ្ធ ឬក៏ចូលរួមជាសមាជិកនៃកងឈ្លប ឬកងទ័ពដែរឬទេ? បានន័យថា គ្រាន់តែឲ្យមានការប្រុងប្រយ័ត្ន ឬក៏ត្រៀមលក្ខណៈក្នុងការគោរពទៅតាមសតិអារម្មណ៍ទៅតាមមនោគមន៍វិជ្ជាបក្សតែប៉ុណ្ណោះ ឬមួយក៏យ៉ាងណា?

**ឆ៖** សូមអរគុណ។ ខ្ញុំរស់នៅក្រោមជ្ឈដ្ឋានដែលកសាងកងឈ្លប ហើយក៏ក្រោមជ្ឈដ្ឋានដែលកសាងកងការពារសម្ងាត់។ បើពាក់ព័ន្ធទៅដល់មជ្ឈដ្ឋានដែលគេកសាងកងឈ្លប ហើយនិងកងការពារសម្ងាត់ ពិតជាតម្រូវលើបញ្ហានេះដែរ។ នេះតាមខ្ញុំយល់ នេះនិយាយពីយល់វិញ។

**ស៖** សូមអរគុណ។ ប្រសិនបើយើងបន្តទៅលក្ខណៈសម្បត្តិទីពីរ វាចែងថា សមាជិកត្រូវមានវណ្ណភាពល្អ ជាវណ្ណភាពដើម ហើយជាពិសេសជំហរវណ្ណៈកម្មករ។ ដូច្នេះ តើពាក្យថា "ជាវណ្ណភាពល្អ" "ជាវណ្ណភាពដើម" តើវាមានន័យយ៉ាងម៉េច? តើនៅក្នុងមនោគមន៍វិជ្ជារបស់បក្សកុម្មុយនីស្តកម្ពុជាហ្នឹង តើវាន័យយ៉ាងម៉េចដែរ ដែរថាវណ្ណភាពល្អនោះ។

[០៩:៤៣:០០]

**ឆ៖** សូមអរគុណ។ "វណ្ណភាពល្អ" នេះ បើខាងកសិករវិញ គេសំដៅកសិករក្រ និងកសិករកណ្តាលថ្នាក់ក្រោម។ បើខាងកម្មករ គឺសំដៅកម្មករឧស្សាហកម្ម បើជាយុវជនសិក្សាគេសំដៅវណ្ណភាពម៉ែឪ បឋមសិក្សាហើយនិងមធ្យមសិក្សា គេសំដៅវណ្ណភាពឪពុកម្តាយ។ នេះវណ្ណភាពដើមល្អ។ សូមបញ្ចប់។

**ស៖** ដូច្នេះយើងយល់ច្បាស់ថា យើងយល់ច្បាស់ពីចំណុចនេះ ប៉ុន្តែថាតើវណ្ណភាពមិនល្អ ឬក៏វណ្ណភាពអាក្រក់ ដែលផ្អែកតាមមនោគមន៍វិជ្ជានៃលក្ខន្តិកៈនេះ តើសំដៅទៅលើអ្វីដែរ? វណ្ណភាពមិនល្អ ឬក៏វណ្ណភាពអាក្រក់នោះ?

**ឆ៖** វណ្ណភាពក្រៅពីនេះ គេចាត់ទុកជាជម្រើសទីពីរ និងជម្រើសទីបី។ កសិករកណ្តាលថ្នាក់កណ្តាល និងកសិករកណ្តាលថ្នាក់លើ ហើយនិងពួកអនុធន គេចាត់ទុកជាជម្រើសទីពីរ។ ជម្រើសទីមួយ គេជ្រើសយកកសិករក្រ និងកណ្តាលថ្នាក់ក្រោម ហើយនិងកម្មករ ហើយយុវជនសិក្សាដែលមានមាតាបិតាជាកម្មករ។ ឯចំណែកជម្រើសទីពីរ គេជ្រើសរើសយកអនុធន ជ្រើសរើសយកកសិករកណ្តាល

ជាទូទៅ។ នេះដល់ជម្រើសទីបី អ្នកផ្សេងទៀត ក្រៅពីហ្នឹង។

[០៩:៤៥:០០]

**ស៖** ហើយលក្ខខណ្ឌតម្រូវ ក៏តម្រូវឲ្យសមាជិកត្រូវមានវណ្ណៈជាកម្មករ តើមានន័យយ៉ាងម៉េច ដែលថាមានជំហរវណ្ណៈកម្មករនោះ?

**ឆ៖** បញ្ហាពាក្យនេះដាក់ឡើងមានលក្ខណៈជាទ្រឹស្ដីច្រើនជាងជាក់ស្ដែង។ វណ្ណភាពល្អនេះ វណ្ណភាពល្អតាមមាគ៌ាវណ្ណៈរបស់បក្ស គឺសំដៅធាតុពិតប្រាំយ៉ាង។ ធាតុពិតវិទ្យាសាស្ត្រសង្គម ធាតុពិតសមូហភាព ស្អីក៏គិតសមូហភាពៗ។ ធាតុពិតសតិអារម្មណ៍អង្គការវិន័យ ធាតុពិតកងឈានមុខ។ ខ្ញុំរាប់នេះខ្ញុំច្រឡំមួយហើយ មិនដឹងជាត្រង់ណាទេ។ ដូច្នេះគេសំដៅយកធាតុពិតទាំង៥(ខ)នេះ របស់វណ្ណៈកម្មករ ដែលឡេនីន ម៉ាក្ស-លេនីនកំណត់មក។ ក៏ប៉ុន្តែខ្ញុំក្នុងការអនុវត្តជាក់ស្ដែងឃើញបញ្ហានេះជាទ្រឹស្ដីសុទ្ធសាធ។

[០៩:៤៦:២៥]

**ស៖** ហើយប្រសិនបើយើងមើលលក្ខណៈសម្បត្តិទី(គ) គឺថាត្រូវមានសីលធម៌រស់នៅស្អាតស្អំ និងស្អាតស្អំខាងនយោបាយ។ តើពាក្យថា "សីលធម៌រស់នៅល្អស្អាតស្អំ"ហ្នឹងមានន័យយ៉ាងដូចម្ដេចដែរ?

**ឆ៖** អរគុណ។ សីលធម៌រស់នៅស្អាតស្អំគឺ ទីមួយមិនស្រា ទីពីរមិនស្រី ទីបីមិនល្បែងពាលាពួកម៉ាកពួកភឿន។ នេះសីលធម៌ស្អាតស្អំក្នុងការរស់នៅ។

**ស៖** ចុះចំពោះពាក្យថា ស្អាតស្អំខាងនយោបាយហ្នឹងតើមានន័យយ៉ាងដូចម្ដេច?

**ឆ៖** ស្អាតស្អំខាងនយោបាយនេះ វាមានន័យពីរ។ ទីមួយន័យសំខាន់គឺធ្លាប់ធ្វើសកម្មភាពជាមួយខ្មាំង បំផ្លាញបដិវត្តន៍។ នេះហៅថាមិនស្អាតស្អំខាងនយោបាយ។ ហើយមួយទៀត គឺមានជាប់ជំពាក់បងប្អូនជាមួយនឹងសមាសភាពខ្មាំង។

**ស៖** សូមអរគុណ។ ហើយនៅក្នុងបរិបទនៃលក្ខណៈសម្បត្តិមួយនេះ តើសត្រូវមានន័យយ៉ាងម៉េចដែលយើងនិយាយថា មិនមានអ្វីជំពាក់វាក់វិននឹងខ្មាំងហ្នឹង តើខ្មាំងហ្នឹងមានន័យយ៉ាងម៉េចនៅក្នុងបរិបទនេះ?

[០៩:៤៨:៣៨]

**ឆ៖** "ខ្មាំង" ក្នុងបរិបទនេះ លក្ខន្តិកៈនេះតម្រូវមុនឆ្នាំ៧៥ ច្រើនជាង។ ឧទាហរណ៍មិនជាប់សកម្មភាពជាមួយនឹង លន់ នល់ មិនជាប់សកម្មភាពជាមួយនឹង លន់ ណុន មិនជាប់សកម្មភាពជាមួយ

ជា គឹមអេង ឧត្តមសេនីយ៍ខាងប៉េអឹម។ នេះគឺសំដៅអ៊ីចឹង។ ហើយក្រោយ១៩៧៥ លំបាកនិយាយណាស់។ វន វ៉េត គេចាប់ទៅ កូនប្រសារស្អីៗត្រូវចាត់ទុកជាជាប់សកម្មភាពជាមួយនឹងខ្មាំង។ មិត្តណយ ដែលកូនប្រសារ វន វ៉េត។

**ស៖** ហើយប្រសិនបើយើងមើលទៅលក្ខណៈសម្បត្តិ(ឃ) បានចែងថា ត្រូវពិនិត្យសាកសួរ និងស្ទង់មតិមហាជន ហើយអ្នកដែលត្រូវជ្រើសរើសចូលបក្សរស់នៅ ឬធ្វើការដោយសហករណ៍ក្តី សហជីពក្តី។ តើមានន័យយ៉ាងម៉េចដែរ ដែលថា "ត្រូវពិនិត្យសាកសួរ និងស្ទង់មតិមហាជន"។ តើពាក្យនេះមានន័យយ៉ាងម៉េចដែរ?

**ឆ៖** ពាក្យនេះ វាមានន័យជាក់ស្តែងក្នុងការអនុវត្តខ្លាំងណាស់។ ក្រោយ១៧ មេសា ១៩៧៥ បន្តិច ខាងកងពល៧០៣ ចាត់តាំងមនុស្សម្នាក់ កម្មាភិបាលម្នាក់ចំណាស់បន្តិចដែរ ឈ្មោះ យូ ប៉េងគ្រី ហៅ ម៉ុន ឲ្យទៅតាមដានប្រវត្តិរូបតាមមូលដ្ឋាន អ្នកណា មិត្តណា មានមូលដ្ឋាននៅស្រុកភូមិណា? យូ ប៉េងគ្រី ហៅ ម៉ុន ទៅសួរកម្មាភិបាលមូលដ្ឋានគេ ថាតើពីដើមមកយ៉ាងម៉េច? ធ្លាប់ធ្វើចោរទេ? ធ្លាប់កាប់គេទេ ធ្លាប់អីទេ? នេះគេមានចាត់តាំងទៅសួរអ៊ីចឹងច្បាស់លាស់។ ក្រោយឆ្នាំ១៩៧៥ សួរម្តងហ្នឹងហើយ គឺគេតាមដានពីក្នុងអង្គភាពរបស់ខ្លួន ជាសហករណ៍កសិកម្ម សហករណ៍កសិករ ជាសហជីពកម្មករ និងជាអនុសេនាធំ ព្រោះមនុស្សទាំងអស់នៅកម្ពុជាប្រមូលផ្តុំរស់នៅក្នុងអង្គភាព។ ដូច្នេះគេសួរយោបល់ពីអង្គភាព។

ហើយក្នុងការអនុវត្តជាក់ស្តែង អង្គភាពរាយការណ៍ទៅលើអំពីមិត្តនេះ ប្រវត្តិរូបយ៉ាងនេះៗ អង្គភាពអនុសេនាធំជាអ្នករាយការណ៍។

[០៩:៥២:០២]

**ស៖** ខ្ញុំគិតថា នេះជាពេល នេះជាលើកដំបូងហើយ ដែលលោកបានលើកមកបញ្ហានូវឃ្លានេះ។ បានន័យថា នេះជាលើកដំបូងដែលយើងចោទសួរលោកទៅលើឃ្លានេះ ហើយលក្ខណៈសម្បត្តិចុងក្រោយនៃប្រភេទលក្ខណៈសម្បត្តិទីមួយ។ ដូច្នេះហើយ តម្រូវឲ្យមាននូវប្រវត្តិរូប គឺថាតម្រូវឲ្យមានប្រវត្តិរូបច្បាស់លាស់។ ដូច្នេះតើលោកអាចពន្យល់បានទេ ថាតើពាក្យត្រូវមានប្រវត្តិរូបច្បាស់លាស់ហ្នឹងមានន័យយ៉ាងដូចម្តេចដែរ?

**ឆ៖** អរគុណ ខ្ញុំពន្យល់អំមិញខាងដើម អំពីស-២១ ចាត់តាំង យូ ប៉េងគ្រី ហៅ ម៉ុន ឲ្យទៅតាមដាននៅមូលដ្ឋានហ្នឹង គឺតាមដានប្រវត្តិរូបច្បាស់លាស់នេះឯង។ ដូច្នេះតាមដានប្រវត្តិសកម្មភាព សភាព

ការណ៍ខ្លាំងក្លានៅក្នុងអង្គភាព គេតាមដានក្នុងសហករណ៍ និងក្នុងសហជីព ហើយនិងក្នុងអនុសេនាធំ។ ប្រវត្តិច្បាស់លាស់គឺអ៊ីចឹង កុំឲ្យគេភរ។ ឧបមាថារូបខ្ញុំអ៊ីចឹង មកភរថា អ្ហឺ! ខ្ញុំវណ្ណៈភាពជាកម្មករ មិនបានទេ។ ខ្ញុំវណ្ណៈភាពជាអនុធន។

[០៩:៥៣:៤៣]

**សៈ** ដូច្នេះ ខ្ញុំគិតថាលោកចាប់ផ្ដើមឆ្លើយនូវសំណួរបន្តរបស់ខ្ញុំហើយ គឺខ្ញុំចង់និយាយអំពីប្រភេទលក្ខណៈសម្បត្តិទីពីរដែលតម្រូវឲ្យមានចំពោះបេក្ខជន ព្រោះថានៅក្នុងនេះគឺមានអង្គការបក្សច្រើនថ្នាក់ពិនិត្យវិនិច្ឆ័យ និងសម្រេចជាសមូហភាព ទើបហើយចូលបក្សបាន។ ហើយដូច្នេះលោកអាចឃើញនៅក្នុងមាត្រា២(២) បានរៀបរាប់នូវកម្រិតជាច្រើននៃគណៈកម្មការ ដែលតម្រូវជាពិសេសសម្រាប់បុគ្គលនីមួយៗ ដើម្បីធ្វើការពិនិត្យទៅលើពាក្យសុំ។ ដូច្នេះជាឧទាហរណ៍ ប្រសិនបើយើងមើលទៅលើប្រភេទទីមួយបានបញ្ជាក់ថា ចំណុច(ក) ចំពោះមូលដ្ឋានត្រូវមានអង្គការបក្សបួនថ្នាក់ពិនិត្យវិនិច្ឆ័យ និងសម្រេចជាសមូហភាព គឺសាខាគណៈកម្មាធិការបក្សស្រុក គណៈកម្មាធិការបក្សតំបន់ និងគណៈកម្មាធិការបក្សភូមិភាគ។ ហើយបានរៀបរាប់ទៅប្រភេទផ្សេងៗគ្នានៃបេក្ខជនដែលអាចចូលរួមបានដែរ ដែលតម្រូវឲ្យមានបេក្ខភាពនេះ ដើម្បីពិនិត្យ និងសម្រេច។ ដូច្នេះសំណួររបស់ខ្ញុំ គឺថាហេតុអ្វីបានជាតម្រូវឲ្យមានលក្ខណៈសម្បត្តិបែបនេះ? បានន័យថា ហេតុអ្វីតម្រូវឲ្យមានគណៈកម្មការ អង្គការបក្សបួនប្រាំថ្នាក់នេះ ដើម្បីសម្រេចទៅលើបេក្ខភាពនៃបក្ខជន? តើលោកយល់ថា ហេតុអ្វីក៏តម្រូវឲ្យមាននូវគណៈកម្មការបីបួនបែបដូច្នេះ? តើលោកអាចបកស្រាយបានដែរឬទេ?

**ឆៈ** ខ្ញុំបានរៀនវគ្គសិក្សាមួយ ប៉ុន្តែឆ្នាំណា អ្នកណាបង្រៀនខ្ញុំភ្លេចទៅហើយ។ មុនឆ្នាំ១៩៧០ ជាពិសេសមុនឆ្នាំ១៩៧៥ អ្នកណាក៏មិនចង់ចូលបក្សដែរ ព្រោះគ្រោះថ្នាក់។ ក្រោយឆ្នាំ១៩៧៥ អ្នកណាក៏ចង់ចូលបក្សដែរ ព្រោះដើម្បីមានតួនាទីដឹកនាំ។ នេះវគ្គ ខ្លឹមសារវគ្គហ្នឹងបានឧទ្ទេសនាមបានច្បាស់អ៊ីចឹង។ ដូច្នេះការបង្កើតឲ្យមានសមូហភាពច្រើនស្រទាប់ ដើម្បីសម្រេចបេក្ខភាពរបស់បក្ខជនម្នាក់ៗ ដើម្បីទប់ហ្នឹងឯង។ កុំឲ្យខ្មាំងជ្រាបចូលទៅក្នុងផ្ទៃក្នុងរបស់បក្សបាន។

[០៩:៥៦:៥១]

**សៈ** សូមអរគុណលោក ហើយតាមពិតទៅនៅក្នុងលក្ខន្តិកៈនៃ ក្រោមមាត្រា២(ង) ការវាយតម្លៃនេះ គឺតម្រូវឲ្យមានការពិភាក្សា ហើយត្រូវធ្វើឡើងនៅក្នុងរយៈពេលជាច្រើន។ ប្រសិនបើយើងមើលទៅលើទំព័រ១៤ នៃលក្ខន្តិកៈនោះ បាននិយាយថា បានចែងអំពីរយៈពេលត្រៀម ហើយរយៈពេល

ត្រៀមហ្នឹង គឺមានពីរប្រភេទទៀត គឺប្រភេទទីមួយ និងប្រភេទទីពីរ ដែលតម្រូវទៅតាមប្រភេទនៃបុគ្គលនីមួយៗដែលដាក់ពាក្យសុំ។ ទីមួយ គឺការត្រួតពិនិត្យ គឺបំពេញទៅតាមលក្ខខណ្ឌចំនួនដប់។ លក្ខណៈសម្បត្តិចំនួនដប់របស់បក្ស ហើយបន្ទាប់មកត្រូវពិនិត្យតាមចលនាដែលសាមីខ្លួននោះបានរួមប្រាស្រ័យជាចលនាក្តៅ ឬមិនសូវក្តៅ។ ហើយទីបី ពិនិត្យតាមវណ្ណៈភាពដើមរបស់សាមីខ្លួន។ តើលោកអាចឆ្លើយបានដែរឬទេ ចំពោះសំណួរដែលខ្ញុំចោទសួរថាតើលក្ខន្តិកៈនេះនៅពេលដែលចែងថា ដែលៗសាមីខ្លួននោះរួមប្រាស្រ័យជាចលនាក្តៅ ឬមិនសូវក្តី? តើពាក្យថា "ចលនាក្តៅ ឬមិនសូវក្តៅ" នុំងវាមានន័យយ៉ាងដូចម្តេចដែរ?

**ឆ៖** ចលនាមានពីរដាច់ដោយឡែកពីគ្នា។ "ចលនាក្តៅ" គឺចលនាយោធា ប្រយុទ្ធស្លាប់រស់នៅសមរភូមិមុខ។ "ចលនាមិនសូវក្តៅ" គឺចលនាសហ-- (សូមទោស) ចលនាមន្ទីរ។ ឧទាហរណ៍ យុទ្ធជនធ្វើការនៅមន្ទីរក-១៣ ចលនាហ្នឹងមិនក្តៅទេ។ យុទ្ធជនធ្វើការនៅមន្ទីរស-២១ ចលនានោះមិនក្តៅទេ។ ចលនានៅក្នុងសហករណ៍ ជាចលនាក្តៅ ប្រយុទ្ធជាប់ជានិច្ច លើកភ្លឺ ដោះស្រាយប្រព័ន្ធស្រោចស្រព ដោះស្រាយទឹក ដី និងពូជ ដើម្បីសម្រេចបីតោន ហ្នឹងចលនាហ្នឹងក្តៅ។ ហ្នឹងសូមបញ្ជាក់ជូនប៉ុណ្ណោះ។

[០៩:៥៩:៤០]

**ស៖** ហើយមាត្រានេះ បានចែងអំពីរយៈពេលត្រៀមពីរ គឺរយៈពេលត្រៀមប្រាំមួយខែ សម្រាប់គុណភាពប្រភេទទីមួយ និងរយៈពេលត្រៀម១២ខែ សម្រាប់ប្រភេទគុណភាពទីពីរ។ តើលោកអាចឆ្លើយបានទេ ហេតុអ្វីក៏ចាំបាច់តម្រូវឲ្យមានរយៈពេលត្រៀមពីរ? បានន័យថា រយៈពេលត្រៀមសម្រាប់គុណភាពប្រភេទទីមួយ និងគុណភាពប្រភេទទីពីរយ៉ាងដូច្នេះ?

**ឆ៖** សូមអរគុណ។ មនុស្សយើង កាលណាចូលជាបក្ខជនត្រៀមហើយ បក្សប្រគល់ភារកិច្ចឲ្យយើងធ្វើ បក្សតាមដាន។ គុណភាពប្រភេទទីមួយនោះ គឺសំដៅអ្នកដែលមានវណ្ណភាពដើមល្អ។ ត្រៀមតែបីខែ-- អ៎ ប្រាំមួយខែទេ គេឲ្យចូលបក្ស។ ឯចំណែក ស្រទាបកណ្តាលដែលជាជម្រើសទីពីរនេះ គេឲ្យត្រៀមពីរដណ្តប់ខែ គេទុកតាមដានយូរបន្តិច។ បើសិនជា គេមិនពេញចិត្ត គេបន្តទៅទៀត។ នេះ សូមបញ្ជាក់ប៉ុណ្ណោះ។

[១០:០១:១១]

**ស៖** ផ្អែកទៅលើបទពិសោធន៍ការងាររបស់លោកនៅក្នុងបក្ស នៅក្នុងរយៈនោះ ហើយនិងនៅមុនពេល បានន័យថា មុនកម្ពុជាប្រជាធិបតេយ្យ និងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ តើគេពិនិត្យ

ការ-- បានន័យថា ការពិនិត្យទៅលើសមាជិកហ្នឹង កើតឡើងនៅពេលនោះដែរឬទេ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ថា ខ្ញុំមិនបានិយាយអំពីការអនុវត្តលក្ខន្តិកៈបក្សឆ្នាំ១៩៦០ទេ។ ខ្ញុំនិយាយត្រឹមពីការអនុវត្តលក្ខន្តិកៈបក្សឆ្នាំ១៩៧១ មកចុះ។ គេគិត គេអនុវត្តអ៊ីចឹង។ ឯចំណែកលក្ខន្តិកៈបក្សឆ្នាំ១៩៦០ បើតាមខ្ញុំចាំខុសពីនេះបន្តិច។ ជម្រើសទីមួយ គេត្រៀមតែបីខែទេ។ ជម្រើសទីពីរ ត្រៀមប្រាំមួយខែ ក៏ប៉ុន្តែដល់ខ្ញុំចូលជាសមាជិកត្រៀមនៅថ្ងៃ២៥ ខែធ្នូ ឆ្នាំ១៩៧០ នែ៎ ៦០ សូមទោស ១៩៧៧--- ៦៧ ប៉ុនដល់ខ្ញុំជាប់គុក គ្មានសាខាអីត្រឹមត្រូវ មិនអាចបំពេញសិទ្ធិបាន មកបំពេញសិទ្ធិនៅគុកធំនៅថ្ងៃ២០ កក្កដា។ រយៈពេលហ្នឹង ខ្ញុំត្រៀមតែប្រាំមួយខែទេ។ តាមច្បាប់ ខ្ញុំត្រូវត្រៀមតែប្រាំមួយទេ។ ដល់លក្ខន្តិកៈបក្សថ្មីនេះ ជម្រើសទីមួយ ត្រៀមប្រាំមួយខែ។ ជម្រើសទីពីរ ត្រៀមពីរដណ្តប់ខែ។ ដូច្នេះវាខុសគ្នាអ៊ីចឹង។ គឺធ្វើម៉េច គេតាមដានមនុស្សឲ្យបានយូរបន្តិច ដើម្បីនឹងឲ្យចូលបក្ស។

[១០:០៣:១៤]

**ស៖** សូមអរគុណ។ ប៉ុន្តែការបកប្រែជាអង់គ្លេស គឺឆ្នាំ១៩៧៧ ប៉ុន្តែយើងមើលឯកសារហ្នឹងផ្ទៀងផ្ទាត់ នៅចុងបញ្ចប់នៃការត្រៀម ពេលវេលាត្រៀមនោះ គឺថាលក្ខន្តិកៈនិយាយថា លុះដល់ពេលបញ្ចប់រយៈពេលត្រៀម របស់សាមីខ្លួនម្នាក់ៗ ហើយក៏ត្រូវថ្នាក់បក្សទាំងអស់ ដែលមានភារកិច្ចខុសត្រូវបញ្ចូល និងពិនិត្យសម្រេចជាសមូហភាព ជាមូលដ្ឋាន មន្ទីរក្រសួងបួនថ្នាក់ កងទ័ពប្រមូលផ្តុំប្រាំថ្នាក់ ដើម្បីបំពេញសិទ្ធិបេក្ខជនត្រៀមនោះ ទើបបានការ។ តាមការសង្កេតរបស់លោកទៅលើពាក្យសុំទៅតាមលក្ខខណ្ឌនេះ ថាតើត្រូវដែរឬទេ ថាគ្រប់ថ្នាក់ទាំងអស់នៃគណៈកម្មាធិការពិនិត្យនោះ ត្រូវតែយល់ព្រមទៅលើលក្ខខណ្ឌ ឬក៏លក្ខណៈសម្បត្តិរបស់សមាជិកម្នាក់ៗ ដែលគេដាក់ពាក្យសុំនោះ?

[១០:០៤:៣២]

**ឆ៖** អរគុណ។ តាមពិត ពាក្យសុំនេះ ក្នុងការអនុវត្តជាក់ស្តែង គឺអនុសេនាធំ ឬក៏សហករណ៍ ឬក៏សហជីពជាអ្នកសុំទេ។ ឯចំណែកអ្នកសម្រេច ទៅតាមលំដាប់ហ្នឹង។ នៅក្នុងអង្គការមូលដ្ឋានត្រូវប្រាំថ្នាក់ គឺថ្នាក់ភាគជាអ្នកសម្រេច។ ឯចំណែកនៅកងទ័ពត្រូវការ-- អ៎ សុំទោស នៅមូលដ្ឋានបួនថ្នាក់ គឺត្រូវអង្គការភាគជាអ្នកសម្រេច ឯចំណែកនៅខាងកងទ័ពត្រូវប្រាំថ្នាក់។ អាហ្នឹងគេសម្រេចពេញទីអ៊ីចឹង អត់មានឲ្យខុសទេ។

**ស៖** សូមអរគុណ។ នៅក្នុងមាត្រា៣(ខ) ដែលទាក់ទងទៅនឹងសិទ្ធិរបស់សមាជិកបក្ស ហើយនៅក្នុងផ្នែកខាងលើនៃទំព័រ១៩ នៃឯកសារដែលលោកមាន គឺបង្ហាញឈ្មោះ ចួន ឈរឈ្មោះជាបេក្ខជន

ឲ្យគេជ្រើសរើស និងជ្រើសរើសអ្នកដទៃដើម្បីចូលអង្គការ ដើម្បីដឹកនាំផ្សេងៗរបស់បក្ស បាទ។ ដូច្នេះ នៅក្នុងមាត្រានេះនិយាយសមាជិកពេញសិទ្ធិហ្នឹង គឺថាមានសិទ្ធិនឹង ដើម្បីឈរឈ្មោះសម្រាប់ឲ្យគេជ្រើសរើស ហើយ/ឬក៏ជ្រើសរើសអ្នកដទៃនៅក្នុងអង្គការចាត់តាំង ឬក៏ដឹកនាំរបស់បក្សនោះ។ សំណួររបស់ខ្ញុំជូនទៅលោកនោះ គឺថា ចុះបើសិនជាសមាជិកបក្សធម្មតាវិញ មិនមែនជាសមាជិកសម្រាប់ថ្នាក់ដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជាទេ គឺសមាជិកធម្មតាមានសិទ្ធិ ជាសមាជិកពេញសិទ្ធិ តម្រូវឲ្យខ្លួននៅឈរឈ្មោះ ឬក៏ដាក់ពាក្យឲ្យគេជ្រើសរើស។ ថាតើអ្នកដាក់ពាក្យសុំ គឺថាអាចដាក់ពាក្យដោយខ្លួនឯងបានឬទេ បើខ្លួនជាសមាជិក ហើយចង់ឲ្យក្លាយខ្លួនជាសមាជិកធម្មតារបស់បក្សនោះ?

[១០:០៦:៥៥]

**ឆ៖** ទីមួយ និយាយអំពីសមាជិកពេញសិទ្ធិធម្មតា។ តើដាក់ពាក្យយ៉ាងម៉េច? សាខាជាអ្នកចាត់ចែង សាមីខ្លួនៗឯងគិតតែពីខំធ្វើការងារទៅ ឯចំណែកសាខាគេអ្នកចាត់ចែង។ ហើយដាក់ពាក្យហ្នឹងក្នុងសមាជិកធម្មតាមានឡើងត្រឹមតែជាគណៈកម្មាធិ-- ឡើងត្រឹមតែសមាជិកសាខា ជាលេខាសាខាប៉ុណ្ណោះឯងទេ អត់មានឡើងទៅជាស្អីទេ។

**ស៖** ដូច្នេះដើម្បីឲ្យក្លាយជាបក្ខជនធម្មតារបស់បក្សកុម្មុយនីស្តកម្ពុជា ថាតើសាខាត្រូវតែងតាំង ឬក៏សាមីជននោះ គឺសុំដោយខ្លួនឯងបាទ?

**ឆ៖** តាមពិតសាខាជាអ្នកលើកសំណូមពរ សាមីខ្លួនហ្នឹងចង់ហើយ អ្នកណាក៏ចង់ដែរ។ ឯចំណែកសាខា គណៈគេៗជាអ្នកលើកសំណូមពរទៅខាងលើ ឬខាងលើមានមតិមក ថាគួរដាក់មិត្តនេះវិញ អាហ្នឹងខាងលើទេ។ គេសម្រេច គេពិភាក្សាគ្នា គេសម្រេច នេះគឺក្នុងការអនុវត្តជាក់ស្តែង។

**ស៖** លោកបានប្រើពាក្យថា "ជាសមាជិកត្រៀម" ថាតើត្រូវទេនិយាយបុគ្គលម្នាក់ក្លាយទៅជាសមាជិកត្រៀមចាប់ពីពេលដែលទទួលបានការតែងតាំងពីដំបូងឲ្យចូលជាសមាជិក រហូតដល់ពេលមួយដែលគេបានទទួលសមាជិកពេញសិទ្ធិ គឺថានៅចុងបញ្ចប់នៃពេលរយៈពេលត្រៀមនោះ តើអ៊ីចឹងដែរឬទេបាទ?

[១០:០៨:៥៨]

**ឆ៖** ត្រូវហើយៗ។ សូមបញ្ជាក់ថា សមាជិកត្រៀមគ្មានសិទ្ធិត្រូវគេជ្រើសតាំងចូលជាលេខាសាខាបានទេ នៅជាក្រោមបង្គាប់គេ ស្តាប់គេ។

**ស៖** នៅខណៈខាងដើមលោកបានយោងទៅរកសេចក្តីពន្យល់ថា គឺគេហៅថា "សមាជិក

ត្រៀម" ដែលហៅអង់គ្លេសថា "*អលធើណេត មេមប៊ឺ*" ជាសមាជិកត្រៀមនោះ តើលោកសំដៅយកអ្វី?

**ឆ៖** សមាជិកត្រៀមនេះ គឺសំដៅយកអង្គការស្នូលរបស់បក្ស ដែលមានគុណធម៌គ្រប់គ្រាន់ល្មមឲ្យគេបញ្ចូលជាសមាជិកបក្សបាន។ ក៏ប៉ុន្តែបក្សមិនទាន់បានលត់ដំអ្នកនេះឲ្យស្គាល់ ថាតើគុណធម៌ប្រយុទ្ធកម្រិតណា? ឲ្យនៅអ្នកឯងនៅជាត្រៀមសិន។ នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណេះ។

**ស៖** តើពាក្យ "សមាជិកត្រៀម" ហើយនិង "សមាជិកបម្រុង" ដែលអង់គ្លេស គេប្រើពាក្យពីរថា "*អាល់ធើណេត មេមប៊ឺ*" ហើយនិង "*ខេនឌីឌេត មេមប៊ឺ*"។ សមាជិកត្រៀម និងសមាជិកបម្រុងហ្នឹងវាខុសគ្នាដែរឬទេ?

[១០:១០:៥០]

**ឆ៖** នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ប្រើតែមួយម៉ាត់ទេ អត់ប្រើ "សមាជិកបម្រុង"ទេ ប្រើ "ត្រៀម"។ដូច្នេះ ខ្ញុំមិនអាចពន្យល់បញ្ហានេះបានទេ។

**ស៖** សូមអរគុណ។ លោកទើបតែបានពន្យល់ជូនតុលាការ អំពីលក្ខណៈសម្បត្តិ អំពីគុណសម្បត្តិដែលថា បេក្ខជនត្រូវតែមានដើម្បីឲ្យខ្លួនក្លាយទៅជាសមាជិកនៃបក្សកុម្មុយនីស្តកម្ពុជា។ ហើយលោកក៏បានពន្យល់តុលាការដែរថា ការពិនិត្យដើម្បីចូលហ្នឹងគឺថាមានរយៈពេលត្រៀម ហើយមានគណៈកម្មការមួយចំនួន ជាអ្នកសម្រេចថាតើជនម្នាក់ជាបេក្ខជនហ្នឹង គឺអាចមានលក្ខណៈសម្បត្តិធ្វើជាសមាជិកបក្សដែរឬទេ? សំណួររបស់ខ្ញុំទៅទៀតនោះ គឺទាក់ទងទៅនឹងសមាជិករបស់បក្ស ដែលចង់ដាក់ពាក្យសុំដើម្បីធ្វើការជាមួយបក្ស ធ្វើជាថ្នាក់ដឹកនាំ ជាលេខាដឹកនាំ។ យើងមើលមាត្រា៥ នៅក្នុងជំពូកទី២ នៃលក្ខន្តិកៈ ហើយវាមានលក្ខណៈសម្បត្តិ ១០យ៉ាង ដើម្បីឲ្យជនម្នាក់ក្លាយទៅជាសមាជិកក្នុងថ្នាក់ដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា។ សំណួររបស់ខ្ញុំ នៅក្នុងអង្គការដឹកនាំរបស់បក្សនោះ។ សំណួររបស់ខ្ញុំ តើពាក្យ "អង្គការដឹកនាំនានា ផ្សេងៗរបស់បក្ស" នោះ មានន័យដូចម្ដេច? ថាតើ "អង្គការដឹកនាំរបស់បក្ស" នោះ តើមានអត្ថន័យដូចម្ដេចបាទ? គឺនៅខាងចុងទំព័រ២២ នៅខាងក្រោមនៃអត្ថបទភាសាខ្មែរ ដែលជាលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា។

[១០:១៣:១១]

**ឆ៖** មាត្រា៥ ដើម្បីលើកគុណភាពដល់នាទីដឹកនាំរបស់បក្ស និងធានាអះអាងដល់ភាពរឹងប៉ឹងនិងបរិសុទ្ធយ៉ាងជាប់លាប់ខាងនយោបាយ សតិអារម្មណ៍ និងចាត់តាំងរបស់បក្ស។ ត្រូវកំណត់លក្ខណៈសម្បត្តិផ្សេង ធ្វើអីផ្សេង ធ្វើជាលក្ខណៈវិនិច្ឆ័យ ដើម្បីជ្រើសរើសកម្មាភិបាលឲ្យចូលគណៈកម្មាធិការ

ដឹកនាំរបស់បក្ស។ គណៈកម្មាធិការដឹកនាំផ្សេងៗរបស់បក្ស សាខាវាជាអង្គការដឹកនាំកម្រិតទាបបំផុតរបស់បក្ស កម្រិតមូលដ្ឋាន។ សាខាវាអាចដឹកនាំសហករណ៍ សាខាវាអាចដឹកនាំអនុសេនាធំ ដល់លើសពីនោះទៅទៀត កម្រិតខ្ពស់ជាងនោះបន្តិច វាទៅជាគណៈកម្មាធិការ។ គណៈកម្មាធិការបក្ស វរសេនាតូច អានេះនិយាយក្នុងកងទ័ព។ លើសពីនោះទៅទៀត គណៈកម្មាធិការវរសេនាធំ នេះនិយាយពីនៅក្នុងកងទ័ព។ គណៈកម្មាធិការវរកងពល នេះនិយាយពីនៅក្នុងទ័ព និងគណៈកម្មាធិការសេនាធិការ នេះនិយាយពីនៅក្នុងកងទ័ព។ ហើយលើសពីនោះទៅទៀត វាចូលដល់ទៅក្នុងគណៈកម្មាធិការមជ្ឈិមបក្ស។ សូមបញ្ជាក់ថា ស-២១ វាជាគណៈកម្មាធិការវរសេនាធំរបស់បក្ស។

[១០:១៥:១៦]

**សៈ** សូមអរគុណ។ ចម្លើយនេះជួយឲ្យយល់អំពីកម្រិតនៃៗអង្គការដឹកនាំបក្សមួយចំនួន ហើយយើងនឹងសង្កត់ធ្ងន់ទៅលើអង្គការថ្នាក់ដឹកនាំនានារបស់បក្ស ដែលអង្គការដឹកនាំបក្សនោះដែលយើងនិយាយជាទូទៅនៅក្នុងផ្នែកនេះនៅក្នុងមាត្រា៥។ តើលោកអាចធ្វើចំណាត់ថ្នាក់ ថាតើលក្ខន្តិកៈនេះបែងចែងដូចម្តេច ដែលថាគណៈកម្មាធិការដឹកនាំផ្សេងៗរបស់បក្សនោះ បាទ?

**ឆៈ** ខ្ញុំសូមបញ្ជាក់ថា នៅក្នុងបក្សកុម្មុយនីស្តកម្ពុជាបក្សកាន់កាប់សព្វមុខដាច់ខាតទាំងស្រុងនិងគ្រប់ផ្នែក។ នៅក្នុងអនុសេនាធំមួយ សាខាវាកាន់កាប់គ្រប់ផ្នែក។ នៅក្នុងសហករណ៍មួយ សាខាវាកាន់កាប់គ្រប់ផ្នែក។ នៅក្នុងសហជីពមួយ សាខាកាន់កាប់គ្រប់ផ្នែក។ ដូច្នេះ វាចេះតែឡើងទៅ។ ខ្ញុំមិនចាំ ថាតើអនុសេនាធំវាស្មើនឹងស្អី? ស្មើនឹងសហករណ៍ ឬក៏ស្មើនឹងកងផលិត កងចល័ត មិនច្បាស់។ ក៏ប៉ុន្តែខ្ញុំនៅចាំបានថា គណៈកម្មាធិការវរសេនាតូច វាស្មើនឹងឃុំៗ។ គណៈកម្មាធិការវរសេនាធំ វាស្មើនឹងគណៈកម្មាធិការស្រុក។ នេះខ្ញុំនៅចាំអ៊ីចឹង វាទៅតាមថ្នាក់របស់វាអ៊ីចឹង។

[១០:១៧:៤៥]

**សៈ** សូមអរគុណ។ ហើយយើងមើលលក្ខណៈសម្បត្តិទីមួយនៃការជ្រើសតាំងទៅកម្មាភិបាលដឹកនាំរបស់បក្សនោះនិយាយថា វាត្រូវមានគោលជំហររឹងមាំ បាទគោលជំហរបដិវត្តន៍រឹងមាំ ខាងមាគ៌ានយោបាយរបស់បក្ស ត្រូវមានជំហរនយោបាយត្រឹមត្រូវរឹងប៉ឹងជាលំដាប់មិនៗស្តាំ មិនឆ្វេង ក្នុងការបំពេញភារកិច្ច នយោបាយជាក់ស្តែងរបស់បក្សដែលខ្លួនអនុវត្តជាបន្តបន្ទាប់ ហើយជាពិសេសក្នុងកិច្ចការការពារប្រទេស និងកសាងប្រទេសកម្ពុជាប្រជាធិបតេយ្យ។ សំណួររបស់ខ្ញុំសួរទៅលោក នៅពេលដែលយើងនិយាយថា សមាជិកត្រូវតែមានបំពេញទៅតាមការងារជាក់លាក់របស់បក្សនោះ តើប្រភេទ

ភារកិច្ចដូចម្តេចដែលក្របខ័ណ្ឌនេះចង់និយាយនៅក្នុងលក្ខណៈសម្បត្តិនេះ?

[១០:១៩:០២]

**ឆ៖** បញ្ហាជាគន្លឹះដែលមានចែងនៅក្នុងគោលការណ៍ទីមួយនៃមាត្រា៥ គឺគោលជំហរនយោបាយត្រឹមត្រូវជាបន្តបន្ទាប់ មិនឆ្វេង មិនស្តាំ។ បញ្ហាសំខាន់គឺអាម៉េចហៅឆ្វេង និងអាម៉េចហៅស្តាំ? ឆ្វេងស្អីក៏ដោយ ក៏ឃើញសុទ្ធតែខ្មាំង។ ឧទាហរណ៍ ដូចមិត្ត ហ៊ី គាត់យក សឺន សារី ទៅសម្លាប់ ទៅកម្ទេចតាមភារកិច្ចរបស់គាត់មុននឹងសួរចប់។ យើងកុំមើលឃើញថា ខ្មាំង បើយើងមើលឃើញថាខ្មាំង មិត្ត ហ៊ី ជាខ្មាំង យើងឆ្វេងហើយ។ សម្លាប់អនុលេខារបស់ខ្លួនឯងដោយសារកំហុសមួយដោយគ្នាមិនទាន់យល់។ ក៏ប៉ុន្តែឧទាហរណ៍មួយទៀត ដូច ណាត គាត់សម្រេចចិត្តចាប់គេតាមអត្តនោម័តិរបស់គាត់។ សម្រេចចាប់កូនចៅរបស់គាត់តាមអត្តនោម័តិរបស់គាត់។ បើសិនជាយើងនៅស្ងៀមមិនៗមានមតិ យើងស្តាំហើយ យើងស៊ុមគ្រលុំអំពើដែលខុស ព្រោះវាប៉ះពាល់ដល់អាយុជីវិតយុវជនរបស់យើង ជាសាច់ឈាមរបស់យើងរួចទៅហើយ។ នេះគឺខ្ញុំសូមពន្យល់អំពីឆ្វេង ហើយនិងស្តាំ គន្លឹះនៅត្រង់ហ្នឹង។ គោលការណ៍ទីមួយគន្លឹះនៅត្រង់ហ្នឹង មិនឆ្វេង មិនស្តាំ។

**ស៖** សូមអរគុណ។ ហើយនៅក្នុងមាត្រានេះក៏បាននិយាយផងដែរថា ត្រូវតែមានការងារនយោបាយជាក់លាក់របស់បក្ស ជាពិសេសក្នុងការការពារប្រទេស ហើយនិងការកសាងប្រទេសកម្ពុជាប្រជាធិបតេយ្យ។ តាមការសង្កេតរបស់លោកអំពីការអនុវត្តគោលនយោបាយនៅក្នុងសម័យកាលនោះ តើអ្វីជាលក្ខខណ្ឌសំខាន់នៃការការពារជាតិ ហើយនិងការកសាងជាតិកម្ពុជាប្រជាធិបតេយ្យនោះ វាមានអ្វីជាគោលការណ៍សំខាន់ក្នុងសម័យនោះ?

[១០:២២:០២]

**ឆ៖** ការការពារប្រទេសសំខាន់សំដៅការពារប្រទេសកុំឱ្យយួនចូលមកបាន យួនឈ្លានពានបាន នេះការពារប្រទេស។ បញ្ហាអាមេរិកាំងចប់ហើយ វាមានកម្សួលបន្តិចចុងក្រោយក៏ពិតមែន ក៏ប៉ុន្តែវាចប់ហើយ។ ដូច្នេះ ការពារប្រទេសធ្វើម៉េចកុំឱ្យយួនចូលបាន កុំឱ្យយួនជ្រៀតជ្រែកបាន។ នេះបញ្ហាការពារប្រទេស។ ឯចំណែកកសាងប្រទេស គឺកសាងសេដ្ឋកិច្ចទៅតាមទិសមួយដែលជាជំហានលោតផ្លោះពីសង្គមនិយមឱ្យដល់កុម្មុយនីស្តនិយមឱ្យឆាប់។ តាមគំរូនៃកងផលិត ហ៊ុម តាចាយ (ប្រកបតាមសំឡេងដើម) នៃមហាបដិវត្តន៍វប្បធម៌។ នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង។

**ស៖** សូមអរគុណ។ ចុះពាក្យថា “ការការពារជាតិ” តើវាប់បញ្ចូលទាំងទស្សនៈ ការការពារ

ទល់នឹងខ្មាំងនៅក្នុងប្រទេស ហើយនិងខ្មាំងក្រៅប្រទេសដែរឬទេ? ឬក៏និយាយថា ខ្មាំងខាងក្រៅប្រទេស?

**ឆ៖** ក្នុងខួរក្បាលខ្ញុំអត់ទាន់និយាយមានបញ្ហាពីរនេះដាច់ដោយឡែកពីគ្នាទេ ក្នុងការអនុវត្តកន្លងមក។

**ស៖** យើងមើលលក្ខណៈសម្បត្តិទីពីរ ដែលថា គោលជំហរបដិវត្តន៍រឹងមាំគឺថា រឹងប៉ឹងខាងសតិបញ្ញា សតិអារម្មណ៍អធនរបស់បក្ស ត្រូវមានជំហរសតិអារម្មណ៍វណ្ណៈអធនត្រឹមត្រូវ និងរឹងប៉ឹងលើគ្រប់ខាងសម្ភារៈ សិទ្ធិអំណាច និងសមធម៌នៅក្នុងកម្ពុជាប្រជាធិបតេយ្យក្នុងទិសដៅសង្គមនិយម ដើម្បីកសាងសង្គមនិយមឲ្យបាន។ តើមានន័យដូចម្ដេចចំពោះឃ្លាថា សមាជិកត្រូវតែៗមានគោលជំហរយ៉ាងរឹងមាំក្នុងការប្រយុទ្ធ និងការតស៊ូប្រយុទ្ធជាប់នោះ បាទ?

[១០:២៤:២៧]

**ឆ៖** សូមអរគុណ។ ត្រូវមានជំហរប្រយុទ្ធមោះមុតសកម្ម ទ្រាំទ្រលំបាកវេទនាគ្រប់កាលៈទេសៈក្នុងការតស៊ូវណ្ណៈដាច់ខាត ក្នុងកិច្ចការពារប្រទេស និងកសាងប្រទេសកម្ពុជាប្រជាធិបតេយ្យ តាមទិសបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយម។ ដូច្នេះ បក្ខជនម្នាក់ៗមិនត្រូវរាថយទេ ត្រូវដាច់ខាតប្រយុទ្ធទៅមុខជានិច្ច។ ក្នុងការតស៊ូវណ្ណៈ ក្នុងការការពារប្រទេស និងក្នុងការកសាងប្រទេស។

តស៊ូវណ្ណៈប្រឆាំងនឹងអី? នៅក្នុងនេះបញ្ជាក់ច្បាស់ពីខាងលើរួចមកហើយ គឺប្រឆាំងនឹងសម្ភារនិយម ជាឡាន ជាម៉ូតូ ជាមាសពេជ្រ កម្មសិទ្ធិខាងអំណាច។ ជេរគេជេរឯង ជេរកូនជេរចៅពាសវាលពាសកាល កូនចៅទាស់បន្តិច គ្នាខ្លាំង។ នេះគេហៅថាកម្មសិទ្ធិអំណាច។ ដូច្នេះគោលជំហរតស៊ូវណ្ណៈដាច់ខាតនេះ គឺកុំស្ងួនតួជាគ្រួសារនិយម ជាសម្ភារនិយម ជាទ្រព្យសម្បត្តិនិយម ហើយខំពុះពារការលំបាកគ្រប់បែបយ៉ាង។ លំបាកក្នុងការងារ លំបាកក្នុងការតស៊ូសតិអារម្មណ៍ប្រឆាំងនឹងកម្មសិទ្ធិខាងអំណាច អាជ្ញា ខាងសម្ភារៈទាំងអស់ហ្នឹង។ ហ្នឹងខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង។

[១០:២៦:៣២]

**ស៖** សូមអរគុណ។ ហើយយើងចូលទៅដល់លក្ខណៈសម្បត្តិទីបីនៅក្នុងខាងដើមនៃទំព័រ២៤ ដែលនិយាយថា ដើម្បីខ្លួនជាសមាជិកក្នុងថ្នាក់ដឹកនាំនោះ ត្រូវមាន ហើយមានជំហរអត្តចរិតបដិវត្តន៍រឹងមាំ សាមគ្គីភាព រហូតទៅដល់ខាងចុងនៃផ្នែកនេះ និយាយថា ឃ្លាចុងក្រោយនិយាយថា ត្រូវប្រុងប្រយ័ត្នបំផុតចំពោះជំហរអត្តចរិតស្មារតី និស្ស័យនិងសកម្មប្រឆាំង និងវាយប្រហារៗបក្ស សមមិត្តផងគ្នា

ដោយគោលជំហរកម្មសិទ្ធិបុគ្គលសួនតួ និងបក្សពួក តើមានន័យដូចម្ដេច? ត្រូវប្រុងប្រយ័ត្នជាពិសេសស្មារតី ហើយនិងសកម្មភាពផ្សេងៗហ្នឹង តើឃ្លានេះតម្រូវឱ្យសមាជិកបក្សត្រូវតែធ្វើបែបហ្នឹងដែលហៅថាប្រុងប្រយ័ត្នបំផុតនោះបាទ?

**ឆ៖** មនុស្សដែលបក្សមិនចង់បាន មិនចង់ត្រូវការ គឺមនុស្សដែលឆេវឆាវច្រឡោតគោតគូងគ្មានដឹងខុស គ្មានដឹងត្រូវ ដឹងមុខដឹងក្រោយ។ នេះជាមនុស្សដែលបក្សមិនត្រូវការ ហើយត្រូវការជម្រុះ ឬក៏កៀសដកចេញឱ្យឆ្ងាយ ពីរង្វង់ដឹកនាំ។ ផ្ទុយពីនេះ ជាមនុស្សស្លូតបូតទន់ភ្លន់ ចេះដឹកនាំកម្លាំង នេះជាមនុស្សដែលបក្សត្រូវការ។ នេះគេហៅថាសាមគ្គីភាព ដូចដែលខ្ញុំបញ្ជាក់ប្រភេទកាលពីមុនអ៊ីចឹង។ មេវាតែងគិតដល់កូន។ មេអត់កូនគាំទ្រមិនបានទេ។ ដូច្នេះ ខ្ញុំសូមបញ្ជាក់ប៉ុណ្ណេះ។

[១០:២៨:៥៥]

**ស៖** នៅក្នុងការអនុវត្ត ត្រូវតែប្រុងប្រយ័ត្នបំផុតចំពោះជំហរ អត្តចរិត តើសមាជិកបក្សត្រូវធ្វើដូមម្ដេច? ត្រូវប្រុងប្រយ័ត្នដូចម្ដេចនៅក្នុងពេលអនុវត្តភារកិច្ច? ថាតើការប្រុងប្រយ័ត្ននៅក្នុងការអនុវត្តហ្នឹងដូចម្ដេច? ថាតើគោលការណ៍ហ្នឹងសមាជិកបក្សម្នាក់ៗយកទៅអនុវត្តហ្នឹងដូចម្ដេច?

**ឆ៖** អ្នកដែលមានជំហរទទឹងទទែងច្រងេងច្រងាងដាក់ទៅត្រង់ណាក៏មិនចុះ គេពុះពារកសាងហើយគេពុះពាររុញឱ្យឆ្ងាយអំពីការបង្កើតគ្រោះមហន្តរាយដល់ថ្នាក់ដឹកនាំបក្ស ឬក៏ដល់អង្គភាព តាមការទិតៀន តាមការស្វ័យទិតៀន ហើយការរាយការណ៍ចេះតែរាយការណ៍ទៅខាងលើហើយ។ នេះហើយគេហៅថា រាយការណ៍ប្រវត្តិសកម្មភាពរបស់សមមិត្តម្នាក់ៗជូនបក្ស។

បក្សត្រូវក្ដាប់ប្រវត្តិសកម្មភាពរបស់សមាសភាពដែលលំបាក ហើយក៏ក្ដាប់ប្រវត្តិសកម្មភាពរបស់-- សមាសភាពដែលល្អជាប់ជានិច្ច។ នេះគឺការងារបក្សក្ដាប់អ៊ីចឹង។ ដូច្នេះនៅពេលណាមួយ ដែលខាងលើសម្រេចដាក់វិន័យ អាហ្នឹងគេអនុវត្តវិន័យហើយ ដោយចាត់ទុកសកម្មភាពហ្នឹងជាខ្លាំង ទាល់តែខាងលើឯនោះ។ នៅក្នុងមាត្រា និងជំពូកនិយាយអំពីវិន័យ សហព្រះរាជអាជ្ញានឹងឃើញ។

[១០:៣០:៥៤]

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាក ២០នាទីចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់មួយ ខ្វះដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយអនុរក្សមន្ទីរឃុំឃាំងឱ្យអញ្ជើញសាក្សីទៅកាន់បន្ទប់រង់ចាំ ហើយសម្រាប់

សាក្សី ហើយនិងឲ្យអញ្ជើញគាត់មកកាន់បន្ទប់សវនាការនេះវិញ កន្លែងដែលគាត់ផ្ដល់ចម្លើយឲ្យបានមុនអង្គជំនុំជម្រះបានចូលមកកាន់អាសនៈ។

សូមអញ្ជើញលោកមេធាវីការពារក្ដីលោក អៀង សារី!

**លោក អាង ឧត្ដម៖**

សូមគោរពលោកប្រធាន! សូមអរគុណលោក លោកស្រីចៅក្រម។ ដោយសារបញ្ហាសុខភាពជាពិសេសបញ្ហាឈឺចង្កេះ ឈឺខ្នង និងជើង។ លោក អៀង សារី ថ្ងៃនេះសុំស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមផ្ទាល់ក្នុងបន្ទប់សវនាការនេះ សម្រាប់ថ្ងៃនេះទាំងមូល។ ប៉ុន្តែសូមចូលរួមដោយប្រយោលពីបន្ទប់នៅរង់ចាំខាងក្រោម។ ហើយយើងខ្ញុំនឹងពាក្យតាមកំណត់។ អាស្រ័យហេតុនេះសូមលោកប្រធានមេត្តាពិចារណា និងសម្រេច។ សូមអរគុណ។

[១០:៣២:០៦]

**ប្រធានអង្គជំនុំ៖**

បាទ បានស្ដាប់សំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្ដីរបស់គាត់ ស្នើសុំលះបង់សិទ្ធិមិនចូលរួមដោយផ្ទាល់ក្នុងកិច្ចដំណើរការសវនាការនៅក្នុងបន្ទប់សវនាការនេះ ដោយសុំទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមប្រព័ន្ធសោតទស្សន៍នៅបន្ទប់ឃុំខ្លួនខាងក្រោមបន្ទប់សវនាការនេះ ពេញមួយថ្ងៃ ដោយមូលហេតុបញ្ហាសុខភាព មិនអាចអង្គុយតាមដានស្ដាប់កិច្ចដំណើរការផ្ទាល់នៅក្នុងបន្ទប់សវនាការបាន។ អង្គជំនុំជម្រះយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានស្នើសុំតាមរយៈមេធាវីរបស់គាត់ ហើយតែក្រុមមេធាវីការពារក្ដីជនជាប់ចោទ អៀង សារី ត្រូវប្រគល់មកអង្គជំនុំជម្រះនូវលិខិតលះបង់សិទ្ធិចូលរួមដោយផ្ទាល់របស់ជនជាប់ចោទ អៀង សារី។ ហើយបង្គាប់ឲ្យបុគ្គលិកផ្នែកខាងសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ អៀង សារី អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីប្រព័ន្ធសោតទស្សន៍នៅបន្ទប់ខាងក្រោម បន្ទប់សវនាការនេះ។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទ អៀង សារី ទៅកាន់បន្ទប់ខាងក្រោមជាបន្ទប់ដែលសម្រាប់រៀបចំ សម្រាប់គាត់ចុះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣៣ នាទី ដល់ម៉ោង ១០:៥១ នាទី)*

[១០:៥១:៤៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងប្រគល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

សូមអញ្ជើញ!

**លោក វីណ្សៀម ស្មីត៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វីណ្សៀម ស្មីត៖**

**ស៖** លោក កាំង ហ្គេកអ៊ាវ មុនពេលដែលយើងឈប់សម្រាក លោកបានពន្យល់អំពីលក្ខណៈសម្បត្តិមួយដែលចែងថា "សមាជិកត្រូវតែមានស្មារតីប្រុងប្រយ័ត្នបដិវត្តន៍ខ្ពស់" ហើយលោកបានពន្យល់ផងដែរថា បុគ្គលហ្នឹងត្រូវគេស៊ើបអង្កេត ហើយនិងត្រួតពិនិត្យមើលដោយសមាជិកគណៈកម្មការដើម្បីសម្រេចថាតើពួកគាត់ហ្នឹងចូលរួមជាមួយនឹងសកម្មភាពដែលយើងគិតថា ប្រឆាំង។ នៅក្នុងបទពិសោធន៍ផ្ទាល់របស់លោក នៅពេលដែលលោកនៅក្នុងមន្ទីរស-២១ តើលោកខ្លួនគាត់ផ្ទាល់ធ្វើការស៊ើបអង្កេតទៅលើបុគ្គល បានន័យថា ទៅលើប្រវត្តិរូបរបស់បុគ្គលថាតើទោះបី ពួកហ្នឹងជាអ្នកទោស ឬក៏ជាបុគ្គលិក ឬក៏បុគ្គលផ្សេងៗទៀតក៏ដោយ។ ដើម្បីធានាថាលោកមានការប្រុងប្រយ័ត្នខ្ពស់ចំពោះបុគ្គលណាដែលលោកគិតថាវាជាអ្នកៗប្រឆាំង ឬខ្មាំងរបស់មនោគមន៍វិជ្ជា ឬក៏របស់បក្ស តើលោកមានធ្វើការចុះស៊ើបអង្កេតទៅលើបុគ្គលជាក់លាក់ណាមួយនោះទេ? បានន័យថា ក្រៅពីដំណើរការសួរចម្លើយដើម្បីទទួលបានចម្លើយសារភាពនោះ?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** សូមអរគុណ។ សូមបញ្ជាក់ថា លក្ខន្តិកៈអនុវត្តក្នុងផ្ទៃបក្ស និងក្នុងផ្ទៃប្រជាជន យុទ្ធជន

ឯចំណែកជនរងគ្រោះដែលមកជាប់ទោសនៅ ស-២១ មិនអនុវត្តតាមលក្ខន្តិកៈនេះទេ។ គ្រប់រឿងគ្រប់រ៉ាវ ពួកគេត្រួតពិនិត្យកូនពួករបស់គេ ហើយគេរាយការណ៍មកលើ។ ក្រុម គេត្រួតពិនិត្យមនុស្សក្នុងក្រុមរបស់គេ គេរាយការណ៍មកលើ តាមខ្សែចាត់តាំងអ៊ីចឹង។

លេខាគណៈកម្មាធិការ ស-២១ វាទទួលអំពីអនុលេខាដែលកាន់កាប់ការងារនេះដោយផ្ទាល់ ហើយវារាយការណ៍ទៅលើក្នុងករណីចាំបាច់។ នេះ និយាយអំពីការប្រតិបត្តិជាប់ជាប្រចាំ ដែលយើងខ្ញុំធ្វើ។ ដោយឡែក មានតែក្នុងគណៈកម្មាធិការស-២១ ខ្លួនវា ដែលខ្ញុំបានលើកឧទាហរណ៍ពីររួចមក ហើយប៉ុននុ៎ង។

[១០:៥៥:៣៨]

**ស៖** សូមអរគុណ ហើយនៅមន្ទីរស-២១ ដំបូងលោកជាអនុលេខា ហើយបន្ទាប់មកនៅក្នុងឆ្នាំ៧៦ ហើយលោកក្លាយជាប្រធាន បានន័យថា នៅពេលលោកជាអនុលេខាហ្នឹង លោកនៅក្រោមណាត។ នៅក្រោយមកទៀត លោកក្លាយជាលេខានៃមន្ទីរស-២១ នៅឆ្នាំ៧៦ តើពិតដែរឬទេ?

**ឆ៖** អរគុណ។ ខ្ញុំក្លាយជាប្រធានគណៈកម្មាធិការស-២១ ឬក៏ហៅថា លេខាគណៈកម្មាធិការបក្សមន្ទីរស-២១ រវាងខែមី ឆ្នាំ១៩៧៦។

**ស៖** សូមអរគុណ។ នៅពេលដែលលោកមានតួនាទីជាអនុលេខា នៅមន្ទីរស-២១ នោះ។ តើលោកផ្តល់ ឬក៏តើលោកមានរាយាការណ៍អំពីប្រវត្តិរបស់បុគ្គល បានន័យថា លោកមានធ្វើការ មានរៀបចំជារបាយការណ៍អំពីប្រវត្តិរូបទៅឲ្យលេខាដែរឬទេ?

[១០:៥៧:០១]

**ឆ៖** អរគុណ។ មនុស្សទាំងអស់ ដែលរួមកកើតទៅជាស-២១ នេះ ភាគច្រើនលើសលប់មកពីកងពល៧០៣។ ការងារនេះ កាន់កាប់ដោយមិត្ត ហ៊ី តាំងពីហូរហែមក។ ឯចំណែក អ្នកដែលចូលមកថ្មី គឺមានពីរក្រុម។ ក្រុមខាងមន្ទីរ១៣របស់ខ្ញុំ មានប្រហែលជាដប់នាក់ លើសបន្តិចបន្តួច។ ហើយនិងក្រុមមកពីខាងក្រុង។ ទាំងអស់នេះ ធ្លាក់នៅក្រោមការកាន់កាប់របស់បក្សរបស់មិត្ត ហ៊ី ឯចំណែកខាងខ្ញុំនៅពេលដែល ណាត គាត់នៅ ទទួលភារកិច្ចដឹកនាំគេ សួរចម្លើយ និងបង្រៀនសួរចម្លើយ ហើយនិងតាមដានឯកសារដែលគេឆ្លើយ។ នេះ ភារកិច្ចអង្គាល់នុ៎ង។ នេះក្រោយពីភារកិច្ចដែលខ្ញុំបញ្ចប់ ពីរឿងដើរទៅប្រមូលឯកសារពីផ្ទះអ្នកធំៗរបស់របប លន់ នល់ ហើយនិងប្រមូលពីគ្រឹះស្ថានសាធារណៈរបស់របប លន់ នល់។ គ្រឹះស្ថានសាធារណៈដែលខ្ញុំទៅប្រមូលនេះ គឺអគ្គនាយក--។

[១០:៥៨:២២]

**ស៖** សូមទោសលោក។

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** គ្រឹះស្ថានសាធារណៈ ដែលខ្ញុំទៅប្រមូលឯកសារនេះ គឺអគ្គនាយកដ្ឋាននគរបាលជាតិ របស់ វ៉ាន់ សរ កុងសីរបស់ លន់ នល់ គឺនាយសេនាធិការ ហើយនិងស្អីគេហៅថា សង្កាត់ មើល៍ បាវាំង គេហៅថា "*កាត់ដេ ហ្សេណេរ៉ាល់ ឡឺឡាត់ មីនីស្រ្តាសស្យុង ដឺឡារ៉ុមេ*"។ ខ្ញុំទៅប្រមូលឯកសារពីនុ៎ង ហើយនិងពីផ្ទះអ្នកធំៗ ដូចជាផ្ទះ លន់ នល់ ផ្ទះ វ៉ាន់ សរ កុង្សីយ៍ប៉ូលិស អីៗជាដើម។ ហ្នឹង គឺខ្ញុំប្រមូល។ ចប់ពីនុ៎ងមក ខ្ញុំចូលកាន់កាប់ផ្ទាល់នៅនេះ ឯកសារមានជាភស្តុតាងហើយ គឺខ្ញុំត្រួតពិនិត្យការសួរចម្លើយ ដឹកនាំសួរចម្លើយ ហើយនិងបង្រៀនគេសួរចម្លើយ ប៉ុននុ៎ង។ នេះ ខ្ញុំសូមបញ្ជាក់ប៉ុណ្ណេះ។ ហើយដល់ខ្ញុំកាន់កាប់ជាលេខា បានខ្ញុំកាន់កាប់ការងារទាំងអស់។ ដោយប្រគល់ការងារបក្សទៅឲ្យមិត្តហ៊ិ។

[១០:៥៩:៣៤]

**ស៖** អរគុណ។ ឥឡូវនេះ យើងសូមត្រឡប់ទៅលើលក្ខណៈសម្បត្តិ១០យ៉ាង ក្នុងការជ្រើសរើសចូលទៅក្នុងអង្គការដឹកនាំបក្ស។ ប្រសិនបើយើងមើលទៅលើលក្ខណៈសម្បត្តិទីបី នៅចុងទំព័រ២៤ នៅចុងទំព័រ២៥ៗ គឺបាននិយាយថា ត្រូវៗៗមានគោលគំនិតច្នៃប្រឌិត ហើយនិងមានការមោះមុត ហើយនិងមានការប្រុងប្រយ័ត្ន។ តើមានន័យយ៉ាងដូចម្តេច ដែលថាសមាជិកត្រូវតែមានការ-- ត្រូវតែមានការវាយសម្រុកក្តៅជាប់? តើ "ការវាយសម្រុកក្តៅជាប់" ហ្នឹងបានន័យយ៉ាងដូចម្តេចដែរ?

**ឆ៖** ខ្ញុំរកមិនទាន់ឃើញទេ។ សូមបញ្ជាក់ទំព័រជាខ្មែរ។

**ស៖** គឺនៅទំព័រទី២៥ ជួរចុងក្រោយ។

[១១:០១:១២]

**ឆ៖** ជួរចុងក្រោយ ខ្ញុំសូមអានជាខ្មែរ។ ប្រយ័ត្នបំផុតៗ គោលជំហរ និងអាកប្បកិរិយាធ្វើការងារបែបការិយាល័យនិយម នាម៉ឺននិយម អាជ្ញានិយម យោធានិយម សេរីនិយម ឯកចិត្តនិយម អត្តនោម័តិនិយម បែបមិនទទួលខុសត្រូវទាំងអស់ចំពោះបក្ស បដិវត្តន៍ និងប្រជាជន។ ទាំងអស់នេះជាអាកប្បកិរិយាខុសឆ្គង ដែលបក្សមិនឲ្យអនុវត្ត។ អាកប្បកិរិយាការិយាល័យនិយម គឺធ្វើជាការិយាល័យមានមេ មានកើយ ចូលទៅដល់គិតតែអង្គុយការិយាល័យ ចេញសារាចរ ចេញបទបញ្ជា។ នាម៉ឺននិយម

ដើរទៅណាមានអង្គរក្សទៅតាមបួនដប់ម្ភៃនាក់។ អាជ្ញានិយម ច្រងេងច្រងាង សម្តុតកូនចៅ វាលដាល។ យោធានិយម ស្អីក៏គិតតែពីកម្ទេច ស្អីក៏គិតតែអីវាយ ស្អីក៏គិតតែពីខ្លាំង នេះបើខាងយោធា អង្គភាពយោធា អាហ្នឹងធំណាស់។ សេរីនិយម នឹកឃើញចង់ធ្វើៗទៅ ហ្នឹងសេរីនិយម មិនចេះស្តាប់មេ សេរីនិយម។ អត្តនោម័តិ ធ្វើស្រេចនឹងចិត្ត។ សេរីនិយម ហើយនិងអត្តនោម័តិនេះ វាអត់ខុសគ្នាទេ ធ្វើស្រេចនឹងចិត្ត អត់គិតគូរដល់មាគ៌ា អត់គិតគូរដល់អីទេ។

[១១:០៣:០៤]

ដូច្នេះទាំងអស់នេះ គេហៅថាមិនទទួលខុសត្រូវអ្វីទាំងអស់ចំពោះបក្ស ចំពោះបដិវត្តន៍ និងចំពោះប្រជាជន។

**ស៖** សូមអរគុណ។ ការពិតទៅ ខ្ញុំចង់និយាយយោង គឺថាកថាខណ្ឌមួយនៅខាងលើអ្វីដែលលោកនិយាយអម្បាញ់មិញហ្នឹង គឺនៅក្នុងភាសាខ្មែរ គឺទាក់ទងទៅនឹងសមាជិកដែលត្រូវវាយសម្រុកក្តៅជាប់ បានន័យថា វាយសម្រុកក្តៅជាប់។ បានន័យថា វានៅពីលើផ្នែកដែលលោកបានអាននៅមុននេះ គឺនៅលើផ្នែកដែលលោកបានអាន តើលោកអាចពន្យល់បានទេ ថាតើពាក្យថា “វាយសម្រុកក្តៅជាប់” ហ្នឹងមានន័យយ៉ាងដូចម្តេចដែរ?

[១១:០៤:០៣]

**ឆ៖** អរគុណ។ វាយសម្រុកក្តៅជាប់ វាផ្ទុយនឹងប៉ុកល្ញើយ ម៉ោងប្រាំពីរបានចូលធ្វើការ ការងារគរគោកក៏ដោយ ម៉ោងប្រាំពីរចូល។ ម៉ោងមួយដណ្តប់ចេញ ម៉ោងប្រាំបួនសម្រាក។ នេះគេហៅថា ធ្វើការងារត្រជាក់។ ដល់ក្តៅជាប់ បើការងារបន្ទាន់ខ្លាំង វាត្រូវតែធ្វើ។ ទាំងយប់ ទាំងថ្ងៃ បីថ្ងៃជាប់គ្នាក៏មានដែរ នេះខ្ញុំសម្រុកនៅ ស-២១។ យុទ្ធជនខ្ញុំ ក៏គេសម្រុកបែបនោះដែរ បើមេវាទៅហើយ កូនក៏ទៅហើយ។ នេះក្តៅជាប់។ នេះសូមអរគុណ។

**ស៖** សូមអរគុណ។ ឥឡូវ ប្រសិនបើយើងមើលលក្ខណៈសម្បត្តិទី៥ ដែលនិយាយថា ជំហរ--ត្រូវមានជំហរប្រុងប្រយ័ត្នជានិច្ច រក្សាការសម្ងាត់ និងការពារកម្លាំងបដិវត្តន៍ តើលោកអាចពន្យល់បានដែរឬទេ ថាតើឃ្លាដែលសរសេរថា “រក្សាការសម្ងាត់” ហ្នឹង តើសមាជិកបក្សហ្នឹង គាត់ត្រូវធ្វើយ៉ាងដូចម្តេចដែរ? បានន័យថា គោលការណ៍ហ្នឹង ត្រូវឲ្យសមាជិកហ្នឹង គាត់ឲ្យធ្វើយ៉ាងម៉េចដែរ ដើម្បីរក្សាការសម្ងាត់នោះ?

[១១:០៥:៤៩]

**ឆ៖** រក្សាការសម្ងាត់ វាជាគ្រឹះមូលដ្ឋាន នៃការងារទាំងអស់។ យើងធ្លាប់ឮហើយជំនាន់នោះ ការងារគេ គេដឹង ការងារយើង យើងដឹង។ ព្រះរាជអាជ្ញា នៅចាំបានហើយសាក្សីម្នាក់របស់-- កូនចៅខ្ញុំឈ្មោះ ឈុន ផល សូម្បីតែមុខគាត់-- សូម្បីតែមុខខ្ញុំក៏គាត់អត់ចង់ដឹង ចង់ឃើញដែរ។ នេះហៅថា អ្នកដែលគិតគូរតែការងារ មិនគិតគូរចង់ដឹងអីក្រៅពីការងាររបស់ខ្លួន រក្សាការសម្ងាត់បែបហ្នឹងមួយ។ រក្សាការសម្ងាត់មួយបែបទៀត ព្រះរាជអាជ្ញាប្រហែលជានៅចាំ ខ្ញុំបានរាយការណ៍ពីមិត្ត ហ៊ា ធ្វើឲ្យបែកការណ៍ពីរឿងអ្នកទោសឆ្លើយដាក់ សោ ភឹម ដឹងដល់មេ មេដកសិទ្ធិមិនឲ្យមិត្ត ហ៊ា អានឯកសារនគរបាលអស់មួយរយៈ។ នេះជារូបភាព ដែលយើងខ្ញុំបានរក្សាការណ៍សម្ងាត់នៅស-២១។ ដូច្នេះស-២១ គ្មានអ្នកណាចូលទៅជិតបានទេ។ អ្នកដែលចូលមកត្រឹមតែកន្លែងដែលមិត្ត ហ៊ុយ ទទួលភ្ញៀវ ដែលឥឡូវនេះ គេដាក់ទៅកន្លែងស្អី ប៉ុស្តិ៍វិទ្យុសំបុកឃ្មុំស្អីគេនេះ។ ត្រង់នុំង គ្មានអ្នកណាចូលដល់ស-២១ បានទេ។ អ្នកដែលចូលទៅដល់ស-២១ បាន គឺមានមិត្ត ប៉ង់ ចូលដល់ណាក៏ចូលដែរ មិត្ត ប៉ង់ គេតំណាងឲ្យខាងលើហើយ។ មិត្ត លីន ឯចំណែកមេ អញ្ជើញដល់ត្រឹមតែមុខរោងយាម ហើយចូលទៅផ្ទះខ្ញុំ។ សុន សេន គាត់អញ្ជើញទៅ ដូចជាប្អូនដង។

[១១:០៧:២៩]

ដូច្នេះ ស-២១ គ្មាននរណាចូលបានទេ ហើយឯកសារហ្នឹងប្រយ័ត្នណាស់ គ្មាននរណាដឹងរឿងរ៉ាវឯកសាររបស់ស-២១ទេ។ នេះការប្រុងប្រយ័ត្ននៅក្នុងទីនោះ។ ដូច្នេះ រឿងអីក៏ដោយ ក៏មិននិយាយដែរ។

**ស៖** ដូច្នេះ គោលការណ៍រក្សាការសម្ងាត់ហ្នឹងចង់មានន័យថា បក្ខជនត្រូវរក្សាការងាររបស់គាត់ហ្នឹងឲ្យសម្ងាត់ បានន័យថា មិនត្រូវប្រាប់អ្នកដទៃ។ តើមែនឬទេ?

**ឆ៖** យកសម្ងាត់ជាមូលដ្ឋាន១ ហើយពាក្យសម្ងាត់ហ្នឹង គេមានពាក្យស្លោកគេ ដែលផ្សព្វផ្សាយនៅក្នុងឆ្នាំ១៩៧០ “មិនដឹង មិនឮ មិនឃើញ មិននិយាយ”។ គេហៅថា “សម្ងាត់ប្អូនមិន” ដែលគេអប់រំជាទូទៅ ពេញផ្ទៃប្រជាជន កុំថាតែបក្ខជន។

[១១:០៨:៥២]

**ស៖** ឥឡូវនេះ ពាក់ព័ន្ធទៅនឹងអង្គការ-- អង្គភាពរបស់លោក បានន័យថា បក្សកុម្មុយនីស្តកម្ពុជានោះ។ តើនៅពេលអនុវត្តគោលការណ៍រក្សាការសម្ងាត់នេះ តើយើងត្រូវរក្សាការសម្ងាត់ពីអ្នកណា? បានន័យថា តើយើងមិនត្រូវប្រាប់ឲ្យអ្នកណាដឹងខ្លះ?

**ឆ៖** ដំបូង ខ្ញុំសូមឆ្លើយអំពីរឿងមិនត្រូវប្រាប់ឲ្យអ្នកណាដឹងខ្លះ។ អ្នកដែលមានភារកិច្ចដឹង អ្នកដែលមានភារកិច្ចរាយការណ៍ វាមានកំណត់ច្បាស់លាស់ គឺមេរបស់យើង។ ឧទាហរណ៍ជាក់ស្ដែង ឯកសារស-២១ គឺចម្លើយរបស់ខ្មាំង ចម្លើយរបស់ជន-- នៃអ្នកជាប់ទោសនោះ។ ស-២១ គ្មានសិទ្ធិរាយការណ៍ឲ្យអ្នកណាក្រៅពី សុន សេន ទេ ដែលនីរសារគាត់មកយកផ្ទាល់ដៃពីខ្ញុំ ហើយគាត់ប្រយ័ត្នដែរ នៅពេលដែលនីរសារមកយកឯកសារហ្នឹង គឺសុទ្ធតែឲ្យមកឡាន ដើម្បីដាក់បិទបាំងឯកសារហ្នឹង កុំឲ្យគេឃើញ។ ក្រោយ១៥ សីហា ១៩៧៨ អ៎! ៧៧ មិត្ត ទៀង នីរសារបងទីពីរនេះ មកយកផ្ទាល់ពីខ្ញុំ។ ក្រោយមកទៀត ពេលដែលមិត្ត ទៀង ជូនបងទីពីរទៅស្រុកចិន បានមិត្ត លីន ហើយនិង ប៉ង់ ចុះមកយក។ ដូច្នេះឯកសារហ្នឹងគឺវាសម្ងាត់ មានទិសមួយច្បាស់លាស់មិនឲ្យអ្នកណាក្រៅពីមេ សូម្បីតែគណៈកម្មាធិការសេនាធិការក៏ដោយ ក៏ស-២១ គ្មានសិទ្ធិរាយការណ៍ តែអ្នកឯងហ៊ានរាយការណ៍ គឺអ្នកឯងល្មើសវិន័យ អ្នកឯងត្រូវមានពិរុទ្ធ។ នេះរក្សាសម្ងាត់ចំពោះឯកសារស-២១ នោះវាធំអឺចឹង។ ដូច្នេះរក្សាការសម្ងាត់ពីអ្នកណា? រក្សាការសម្ងាត់ដែលមានឡើងនៅក្នុងអង្គភាពយើង។ រក្សាការសម្ងាត់អំពីភារកិច្ចដែលយើងមានជាចំពោះ។

[១១:១១:៣០]

**ស៖** ដូច្នេះ ប្រសិនបើខ្ញុំសង្ខេបទៅ គឺថាគោលការណ៍រក្សាការសម្ងាត់ហ្នឹងមិនមែនរក្សាការសម្ងាត់ពីមេកោយនោះទេ គឺយើងត្រូវរក្សាការសម្ងាត់ពីបុគ្គលដទៃ ដែលមិនស្ថិតនៅក្នុងក្រុមបញ្ជានៅក្នុងកងបញ្ជារបស់លោក តើមែនឬក៏មិនមែន?

**ឆ៖** អរគុណ។ រក្សាការសម្ងាត់ពីមេក៏មានដែរ កុំឲ្យគេដឹងអំពីមេនៅត្រង់ណា បើយើងដឹង។ បើយើងមិនដឹងទេ កាន់តែល្អ។ បើយើងដឹងកុំឲ្យដឹងថាមេនៅត្រង់ណា ធ្វើរណាមេអញ្ជើញទៅណា តាមផ្លូវណា អាហ្នឹងសម្ងាត់ហើយ។ ក៏រក្សាការសម្ងាត់ពីមេដែរ នេះខ្ញុំសូមបន្ថែមប៉ុណ្ណឹង ក្រៅពីនោះ ខ្ញុំរក្សាចម្លើយមុនទាំងអស់។

**ស៖** ដូច្នេះ ទាក់ទងទៅនឹងមូលដ្ឋានការងារ ឬក៏តួនាទីសំខាន់របស់លោកក្នុងនាមជាបក្ខជន តើគោលការណ៍រក្សាការសម្ងាត់ហ្នឹង គឺអនុញ្ញាតឲ្យមានតែមេរបស់លោកមួយគត់ដែលដឹងអំពីតួនាទីសំខាន់របស់លោក បានន័យថាមិនឲ្យសមាជិកដទៃដឹង តើមែនឬក៏មិនមែន?

[១១:១២:៥០]

**ឆ៖** សំណួរនេះទូលាយបន្តិច ខ្ញុំលំបាកឆ្លើយ។ សូមព្រះរាជអាជ្ញាលោកសួរឲ្យស្រួលស្ដាប់។

**ស៖** ក្នុងពេលកន្លងមកនេះ យើងពិភាក្សាអំពីការរាយការណ៍បានន័យថា អំពីការទំនាក់ទំនងរវាងមេកោយ និងកូនចៅ ហើយសំណួរដែលខ្ញុំចង់សួរ គឺពាក់ព័ន្ធទៅនឹងការងារស្នូលរបស់សមាជិកបក្សនីមួយៗ បានន័យថាតើការងារស្នូលរបស់សមាជិកបក្សហ្នឹងត្រូវរាយការណ៍ទៅមេកោយរបស់គាត់តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ត្រឹមត្រូវៗ។ មិនមែនតែក្នុងក្របខ័ណ្ឌស-២១ ទេ ក្នុងក្របខ័ណ្ឌអចិន្ត្រៃយ៍ហ្នឹងក៏ដោយ ឯកសារដែលស-២១ ជូនទៅ ព្រះរាជអាជ្ញាគង់ឃើញហើយ ជូនបងផ្ទាល់ ហើយឯកសារមួយនោះ ជូនបងនួន ផ្ទាល់។ ដូច្នេះក្រៅពី បងនួន ហើយនិងបងផ្ទាល់ គឺមើលអត់បានទេ។ ត្រូវឱ្យបងផ្ទាល់ហ្នឹងមើលសិន ហើយសម្រាប់ឱ្យបងហ្នឹងឱ្យទៅអ្នកទៀតជួយពិចារណាគ្នា អាហ្នឹងផ្សេង។

[១១:១៤:២៥]

**ស៖** បក្សកុម្មុយនីស្ត-- លក្ខន្តិកៈបក្សកម្មុយនីស្តកម្ពុជា តើមានឯកសារ-- តើលក្ខន្តិកៈនេះជាឯកសារសម្ងាត់ ឬក៏ជាឯកសារដែលមានលក្ខណៈសាធារណៈ?

**ឆ៖** ខ្ញុំសូមនិយាយថា ក្នុងនិយមន័យរបស់វា លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាៗស្ថិតនៅជាសម្ងាត់។ ឯកសារនេះជាឯកសារហៅថាសម្ងាត់ក៏បាន ព្រោះជាឯកសារផ្ទៃក្នុងបក្ស មិនឱ្យខ្មាំងឃើញនេះមុនឆ្នាំ៧៥ ដល់ក្រោយមកប្រកាសបក្សជាចំហ ឯកសារនេះលែងនៅជាឯកសារសម្ងាត់ហើយ ក៏ប៉ុន្តែវាគ្រាន់តែប្រើផ្ទៃក្នុងបក្ស។

**ស៖** នៅពេលដែលយើងពិនិត្យមើលលក្ខណៈសម្បត្តិទីប្រាំ វាចែងថាសមាជិកត្រូវរក្សាការសម្ងាត់ ហើយនិងការពារកម្លាំងបដិវត្តន៍គ្រប់កាលៈទេសៈ និងគ្រប់អំពើទាំងការងារនិយាយស្តីអាកប្បកិរិយា ការរស់នៅគ្រប់បែបយ៉ាង។ តើការដែលគេសរសេរថា ការពារកម្លាំងបដិវត្តន៍គ្រប់ពេលត្រឹមត្រូវ រឹងមាំគ្រប់កាលៈទេសៈហ្នឹង តើវាតម្រូវឱ្យមានលក្ខណៈយ៉ាងដូចម្តេចដែរចំពោះសមាជិកបក្ស?

**ឆ៖** រក្សាការសម្ងាត់នេះៗ មានវត្ថុបំណងសំខាន់តែមួយហ្នឹងឯង គឺការពារកម្លាំងបដិវត្តន៍។ រក្សាការសម្ងាត់មិនឱ្យដឹងទីកន្លែងដែលមេគាត់សម្រាន្ត មេគាត់រស់នៅ ដើម្បីការពារអាយុជីវិតមេយើង។ រក្សាការសម្ងាត់អំពីផ្លូវដើរហើររបស់មេ ក៏ការពារអាយុជីវិតមេយើង។ រក្សាការពារសម្ងាត់មិនឱ្យបែកធ្លាយឯកសារ ស-២១ ដែលឆ្លើយដាក់អ្នកនេះ ឆ្លើយដាក់អ្នកនោះ ដើម្បីចៀសវាងកុំឱ្យមានបាតុភាព គេរំខាន គេបំផ្លាញឯកសារនេះ គេបំផ្លាញការសម្ងាត់ គេមានវិធានការទប់ទល់។ នេះជាការ

សម្ងាត់។ ដូច្នេះការសម្ងាត់ទាំងអស់ ធ្វើឡើង គឺសុទ្ធតែដើម្បីរក្សាកម្លាំងបដិវត្តន៍នេះឯង។

[១១:១៧:៣០]

**សៈ** តើលោកចង់និយាយថា តម្រូវឱ្យមានការរក្សាគោលនយោបាយរបស់បក្ស បានន័យថា រក្សាសកម្មភាពរបស់បក្ស ឬក៏ស្ថានភាពរបស់បក្ស គឺរក្សាស្ងាត់ បានន័យថារក្សាមិនឱ្យសាធារណជនបានដឹងតើមែនដែរឬទេ?

**ឆៈ** មែនៗ។

**សៈ** ប្រសិនបើយើងរំលងពីលក្ខន្តិកៈទីប្រាំ ទៅដល់ស្ថានភាព-- ឥឡូវនេះយើងទៅមើលលក្ខន្តិកៈ-- លក្ខណៈសម្បត្តិទីប្រាំពីរវិញ ដែលបានចែងថាត្រូវមានគោលជំហរបដិវត្តន៍ កសាងប្រវត្តិរូបគឺបានន័យថានៅទំព័រទី២៧ របស់ឯកសារលោក។ ប្រសិនបើលោកមើលទៅលក្ខណៈសម្បត្តិទីប្រាំពីរ លោកសូមអាននៅកថាខណ្ឌខ្លីមួយ ខ្ញុំមានសំណួរបន្តិចបន្តួចទាក់ទងទៅនឹងលក្ខខណ្ឌ លក្ខណៈសម្បត្តិទីប្រាំពីរនេះ?

[១១:១៩:២៥]

**ឆៈ** លោកសួរថាម៉េច មិនទាន់ឃើញ--

**សៈ** លក្ខណៈសម្បត្តិទីប្រាំពីរបានចែងថា សមាជិកត្រូវមានគោលជំហរបដិវត្តន៍ត្រឹមត្រូវ និងរឹងប៉ឹងដោយស្មារតីទទួលខុសត្រូវខ្ពស់ក្នុងការធ្វើការត្រួតពិនិត្យ និងកសាងប្រវត្តិរូបបដិវត្តន៍ ជីវទស្សន៍បដិវត្តិន៍របស់ខ្លួនជាបន្តបន្ទាប់ ត្រូវស្មោះត្រង់ក្នុងការត្រួតពិនិត្យប្រវត្តិរូប និងជីវទស្សន៍ និងជីវទស្សនៈបដិវត្តរបស់ខ្លួន ហើយនិងក្នុងការកែប្រែគុណវិបត្តិតូចធំរបស់ខ្លួនជាដាច់ខាត ហើយនិងជំរុញការកសាង ពង្រឹង ពង្រីកគុណសម្បត្តិរបស់ខ្លួនឱ្យរីកចម្រើនឆាប់រហ័សជាបន្តបន្ទាប់។ សំណួរដែលខ្ញុំចង់សួរ គឺថាតើលក្ខណៈសម្បត្តិទីប្រាំពីរនេះ តម្រូវឱ្យសមាជិកដែលចង់ចូលទៅក្នុងតួនាទីដឹកនាំនៅក្នុងបក្សត្រូវផ្តល់នូវប្រវត្តិរូបជាលាយលក្ខណ៍អក្សរដែលកត់ត្រានូវប្រវត្តិរូបផ្ទាល់ខ្លួនរបស់ខ្លួនដែរឬយ៉ាងណា?

**ឆៈ** ដំបូងខ្ញុំសូមបញ្ជាក់ថា ពាក្យចង់ចូលទៅប្រកាន់តួនាទីដឹកនាំ ពាក្យនេះអ្នកណាក៏ចង់ ក៏ប៉ុន្តែលក្ខណៈសម្បត្តិ ១០(ខ) នេះជាការតម្រូវរបស់បក្ស មកបក្ខជនគ្រប់រូបឱ្យខំកសាងទាំង ១០(ខ) នេះ។

[១១:២១:៣២]

បន្ទាប់ទៅទៀត ខ្ញុំសូមនិយាយអំពីការកសាងប្រវត្តិរូបបដិវត្តន៍។ ប្រវត្តិរូបរបស់មនុស្សម្នាក់ ដូច

ខ្ញុំវាមានវណ្ណភាពដើមរបស់វា ក៏ប៉ុន្តែដល់ចូលធ្វើបដិវត្តន៍មក វាមានរារែកបត់បែន វាមានទៅចុះចូលជាមួយនឹងខ្មាំង ឬវាមានអសកម្មទេ? អានេះគេហៅថា ប្រវត្តិរូបបដិវត្តន៍។ កសាងប្រវត្តិរូបបដិវត្តន៍គេកសាងយ៉ាងម៉េច? ក្នុងមួយឆ្នាំ ពេលរៀនសូត្រវគ្គម្តងៗ គេមានគម្រោងធ្វើប្រវត្តិរូបបដិវត្តន៍ត្រៀមប៉ុន្មានថ្ងៃ? ឧបមាថា ត្រៀមបីថ្ងៃ បុគ្គលម្នាក់ៗត្រូវខំសរសេរប្រវត្តិរូបរបស់ខ្លួន សម្រាប់មួយឆ្នាំដែលកន្លងរួចមកហើយនេះ តាមខ្លឹមសារឯកសារដែលរៀនក្នុងឆ្នាំនេះ។ តើវាមានគុណសម្បត្តិយ៉ាងម៉េចៗ? ល្អ កសាងល្អបានកម្រិតណា? ដល់ហើយគេយកទៅប្រមូលផ្តុំ គេហៅថាផ្តុំ សាមីខ្លួនអានប្រវត្តិរូបនោះ ឲ្យសមូហភាពគេស្តាប់។ ហើយឲ្យគេលើកសំណួរ ហើយឲ្យគេជួយមតិ។ នេះ ហៅថាកសាងប្រវត្តិរូបបដិវត្តន៍។ ការកសាងប្រវត្តិរូបបដិវត្តន៍នេះ មិនអាចចេះតែធ្វើទេ គឺត្រូវកសាងប្រចាំឆ្នាំនៅពេលវគ្គរៀនសូត្រនយោបាយជាដាច់ខាត ត្រូវតែធ្វើ។

[១១:២៣:១២]

ជីវទស្សនៈបដិវត្តន៍ ក៏គេកសាងរបៀបនុ៎ងដែរ គ្រាន់តែជីវទស្សនៈបដិវត្តន៍ គេពិនិត្យអំពីទស្សនៈរបស់យើងចំពោះជីវិតរស់នៅ តើរស់នៅត្រូវការអី? តើរស់នៅដើម្បីធ្វើបដិវត្តន៍បម្រើប្រជាជន ឬរស់នៅដើម្បីបុណ្យស័ក្តិ? ជីវទស្សនៈបដិវត្តន៍វាមានគូវាមួយទៀតគេហៅថា លោកទស្សនៈបដិវត្តន៍។ គឺយើងយល់យ៉ាងម៉េចចំពោះ លោក:? ចំពោះសភាពការណ៍ ឯចំណែកជីវទស្សនៈបដិវត្តន៍ គឺយើងយល់ហើយកំណត់ខ្លួនយើង ថាយើងត្រូវមានជីវិតបែបម៉េច? ដូច្នេះមួយឆ្នាំៗ សិក្ខាកាមដែលទៅរៀនវគ្គនយោបាយ ត្រូវតែធ្វើជីវទស្សនៈបដិវត្តន៍ និងប្រវត្តិរូបបដិវត្តន៍ ហើយផ្តុំឲ្យគេជួយមតិ។ ដូច្នេះហើយបានជាមានលក្ខខណ្ឌបន្តទៅទៀត ត្រូវស្មោះត្រង់ក្នុងការត្រួតពិនិត្យប្រវត្តិរូប និងជីវទស្សនៈបដិវត្តន៍របស់ខ្លួន។ ហ្នឹងម្នាក់ៗត្រូវតែធ្វើអាហ្នឹងឲ្យស្មោះត្រង់ បើមិនស្មោះត្រង់មិនបានទេ។ ទាល់តែស្មោះត្រង់បានកែប្រែគុណវិបត្តិតូចធំរបស់ខ្លួនដាច់ខាត។ នេះ ខ្ញុំសូមបញ្ចប់ប៉ុណ្ណេះ។

[១១:២៤:៥៣]

**ស៖** តើប្រវត្តិរូបផ្ទាល់ខ្លួនហ្នឹង បានន័យថានៅពេលដែល-- តើត្រូវវាយការណ៍ទៅមេកោយផ្ទាល់ទៅថ្នាក់លើផ្ទាល់ ឬក៏ទៅអ្នកណាផ្សេងទៀត?

**ឆ៖** នៅពេលផ្តុំប្រវត្តិរូបនីមួយៗនេះ ក្នុងគណ:កម្មាធិការនីមួយៗ រក្សាឯកសារហ្នឹងទុករបស់ខ្លួន ហើយខាងលើក្តាប់បានជារួម តាមសេចក្តីវាយការណ៍របស់លេខា-- គណ:កម្មាធិការ។

**ស៖** សូមអរគុណ។ ឥឡូវនេះ យើងមើលមកលក្ខន្តិក:-- អ៊ំ! លក្ខណ:សម្បត្តិទីប្រាំបីដែលថា

ជំហរបដិវត្តន៍រឹងមាំ ខាងវណ្ណៈភាព និងលក្ខណៈសម្បត្តិទីប្រាំបួន ជំហរបដិវត្តន៍រឹងមាំខាងសីលធម៌រស់នៅ ស្អាតស្អំ និងស្អាតស្អំខាងនយោបាយ។ ដូច្នេះ យើងពិភាក្សាពីលក្ខណៈសម្បត្តិទីដប់ ដែលនិយាយថាលទ្ធភាពកសាងខ្លួន និងទទួលនាទីដឹកនាំទៅអនាគត។ ប្រសិនបើលោកមើលលក្ខណៈសម្បត្តិទីដប់និយាយអំពីលទ្ធភាពកសាងខ្លួន និងទទួលនាទីដឹកនាំទៅអនាគត។ តើលោកអាចពន្យល់បានដែរឬទេ? ថាតើពាក្យដែលថា ទទួលតួនាទីដឹកនាំទៅអនាគតហ្នឹង តើសមាជិកត្រូវបង្ហាញថាតើខ្លួនចង់ទទួលបានតួនាទីដឹកនាំទៅអនាគត ឬក៏វាមានន័យផ្សេងពីក្រៅពីនេះ? បានន័យថា គឺថាត្រូវឆ្លងកាត់នូវការត្រួតពិនិត្យ ថាតើសមាជិកបក្សហ្នឹង អាចទទួលបានតួនាទីខ្ពស់ក្នុងថ្នាក់ដឹកនាំទៅអនាគតដែរ ឬយ៉ាងណា?

[១១:២៧:១២]

**ឆ៖** ខ្ញុំនៅតែរក្សាគោលការណ៍ដដែល បក្ខជនមួយរូបៗ ខំបំពេញភារកិច្ច ក៏ដើម្បីបានខាងលើជឿទុកចិត្ត និងប្រគល់ឋានៈដឹកនាំឲ្យ តួនាទីដឹកនាំឲ្យ ដូចគ្នា។ នេះជាបញ្ហាមួយ។ បញ្ហាពីរ នៅក្នុងលក្ខណៈសម្បត្តិទីដប់នេះ ជាកាតព្វកិច្ចតម្រូវរបស់បក្ស មកលើបក្ខជនគ្រប់រូប ត្រូវខំកសាងខ្លួនទៅដើម្បីឲ្យបានចូលក្នុងតួនាទីដឹកនាំបក្សមើលឃើញ។ ទន្ទឹមនេះ ខ្ញុំក៏សូមរាយការណ៍បញ្ហាមួយ នៅថ្ងៃ ២៧ កញ្ញា ១៩៧៧ ក្នុងសុន្ទរកថាដែលប្រកាសដាក់បក្សកុម្មុយនីស្តកម្ពុជា ជាចំហ ជាផ្លូវការទាំងក្នុងប្រទេស និងលើឆាកអន្តរជាតិ ប៉ុល ពត និយាយពាក្យមួយម៉ាត់ "សមមិត្តរូបណា ដែលគិតថាខ្លួនជាមាសទឹកដប់ ហើយដែលយល់ថា សមូហភាពគេមើលមិនឃើញ។ សូមឲ្យមាសទឹកដប់នៅឲ្យស្ងៀមកុំធ្វើអីរំខានគេ"។ នេះ ជាពាក្យពិត ហើយសូមរាយការណ៍ជូនអង្គប្រជុំ ជូនជាតិប្រជាជនឲ្យយល់បញ្ហានេះ។

[១១:២៨:៥៣]

**សៈ** សូមអរគុណ។ លោកបាននិយាយថា សមាជិកជាច្រើន មនុស្សជាច្រើន គឺចង់ក្លាយខ្លួនជាបានតំណែងជាថ្នាក់ដឹកនាំ។ តើលោកអាចបញ្ជាក់ទេថា តាមទស្សនៈរបស់លោក នៅក្នុងឆ្នាំ១៩៧៥ ដល់៧៩ ថាតើជាការប្រកួតប្រជែងដែរឬទេ ដើម្បីឲ្យកម្មាភិបាលនោះ គឺថាប្រកួតគ្នាដាក់ពាក្យហើយនិងចង់បានតំណែងថ្នាក់ដឹកនាំនោះ?

**ឆ៖** ជំនាន់នោះ គេមិនប្រើពាក្យប្រកួតប្រជែងទេ។ គេប្រើពាក្យប្រឡូងប្រណាំង ហើយគេមិនទាមទារ គេតម្រូវឲ្យប្រឡូងប្រណាំងនឹងគ្នាឯង។ គេដាក់គោលការណ៍មួយ ប្រឡូងប្រណាំងនឹងផែនការ ប្រឡូងប្រណាំងនឹងមាគ៌ា ប្រឡូងប្រណាំងនឹងគោលការណ៍ដែលយើងអនុវត្ត។ នេះមាន ជា

ចលនាមួយនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា។

[១១:៣០:១៥]

**ស៖** សូមអរគុណ។ ឥឡូវនេះ យើងទើបតែបានពិភាក្សាអំពីលក្ខណៈសម្បត្តិដប់យ៉ាងនៃការជ្រើសតាំងបុគ្គលឲ្យចូលជាអង្គការបក្សកុម្មុយនីស្តកម្ពុជា។ ឥឡូវនេះ ខ្ញុំចូលទៅដល់ចំណុចបញ្ចប់នៃការពិភាក្សាអំពីភារកិច្ចរបស់សមាជិកនៅក្នុងមាត្រា២ ដែលនិយាយអំពីទស្សនទានដដែលឡើងវិញ ដែលយើងបានពិភាក្សាពីខាងរួចហើយ។ ប៉ុន្តែភារកិច្ចរបស់សមាជិកបក្សហ្នឹង គឺថាត្រូវតែអនុវត្តការងារមួយចំនួន ប៉ុន្តែពាក្យពេចន៍នៅនេះ ក៏ដូចជាថែងខុសបន្តិចពីខាងដើម ហើយខ្ញុំក៏ចង់សួរលោកនូវសំណួរមួយចំនួន ទាក់ទងទៅនឹងភារកិច្ចសំខាន់ៗរបស់សមាជិកបក្ស។ មាត្រា២ នៅក្នុងលក្ខន្តិកៈនេះ គឺថាជាភារកិច្ចរបស់សមាជិក គឺម្នាក់ៗត្រូវមានកាតព្វកិច្ចដូចតទៅនេះ។ ហើយគេបែងចែកភារកិច្ច ឬកាតព្វកិច្ចទៅជាពីរផ្នែក គឺទីមួយ ភារកិច្ចចំពោះមហាជន ហើយមួយទៀតភារកិច្ចផ្ទៃក្នុង។ ហើយនៅក្នុងទំព័រ ១៥ ខាងៗក្រោម ហើយនិងខាងលើនៃទំព័រ១៦ នៃអត្ថបទជាភាសាខ្មែរនៃលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា។

[១១:៣១:៣៨]

បាទ តើលោកបានឃើញ ខបញ្ញត្តិនៅក្នុងមាត្រា២ ហើយឬនៅ? ប្រហែលជាពាក្យថ្មីដែលត្រូវបានដាក់បញ្ចូលទៅក្នុងភាសាមួយ នៅក្នុងលក្ខខណ្ឌនេះ ដែលទាក់ទងទៅនឹងភារកិច្ចរបស់សមាជិកបក្ស។ ទីមួយ គឺពាក្យទាក់ទងទៅនឹងភារកិច្ចចំពោះមហាជននៅក្នុងនោះ គឺថាផ្នែកទីមួយ ដែលថាការងារ ភារកិច្ចក្នុងមហាជន។ បាទ ឃោសនាអប់រំមហាជនអំពីនយោបាយ សតិអារម្មណ៍ ចាត់តាំងរបស់បក្ស ហើយប្រឡូកជាប់ជានិច្ច ជិតស្និទ្ធនឹងមហាជន។ បាទ តើលោកអាចពន្យល់បានទេ គឺថានិយាយពីការចុះប្រឡូកជាប់ជានិច្ចនឹងមហាជននេះ?

[១១:៣២:៥៥]

**ឆ៖** ពាក្យ “មហាជន” នេះ នៅក្នុងកងទ័ព មហាជន គឺយុទ្ធជនរបស់ខ្លួន យុទ្ធជន យុទ្ធនារីរបស់ខ្លួន។ នៅក្នុងសហករណ៍ មហាជនរបស់គេ គឺសមាជិកអង្គភាពគេ។ ជាកងផលិតធំ សមាជិកក្នុងកងផលិតធំហ្នឹង កងធំ កងចល័ត។ ដូច្នេះ--

**ស៖** ប្រហែល-- ខ្ញុំសូមឲ្យលោកអាន ថាអាចនឹងការបកប្រែ ប៉ុន្តែឲ្យសូមអានបន្ទាត់ពីរ នៅក្នុងផ្នែក(ក) បន្ទាប់មកខ្ញុំនឹងសួរសំណួរទាក់ទងទៅនឹងចំណុចនេះ បាទ។

**ឆៈ** (ក) ឃោសនាអប់រំមហាជន អំពីមាគ៌ានយោបាយ-- អំពីនយោបាយ សតិអារម្មណ៍ ចាត់តាំងរបស់បក្ស ហើយប្រឡូកជាប់ជិតស្និទ្ធនឹងមហាជន កម្មករ កសិករ ក្នុងសហជីព សហករណ៍ និងកងទ័ពបដិវត្តន៍។ proselytize

[១១:៣៤:១២]

**សៈ** បាទ អ៊ីចឹង គឺថានៅ *ក្លសណីថាយស៍* (ប្រកបតាមសំឡេងដើម) គឺថាឃោសនាអប់រំ គឺថាធ្វើឲ្យមនុស្សម្នាក់ គឺក្លាយទៅជាមានសាសនាផ្សេង។ អាហ្នឹង តើតាមការចេះដឹងរបស់លោក ភារកិច្ចរបស់សមាជិកហ្នឹងគឺថាប្តូរ បានន័យថា ធ្វើឲ្យមហាជនក្លាយទៅជាអ្នកទទួលយកមនោគមន៍វិជ្ជារបស់បក្ស ដែលជាអង្គការរបស់--អង្គការកំពូលរបស់បក្សហ្នឹងដែរឬទេ? បាទ ពាក្យថា "ប្រឡូកជាប់ជិតស្និទ្ធនឹងមហាជន" នោះបាទ។

**ឆៈ** អរគុណ។ ខ្ញុំសូមបញ្ជាក់ថា មហាជននេះ បើនៅក្នុងកងទ័ព គឺយុទ្ធជន យុទ្ធនារី។ អប់រំទៅតាមមាគ៌ាបក្ស យកមាគ៌ាបក្សមកអប់រំ យើងអប់រំតែមាគ៌ាបក្សទេ។ នៅត្រង់ទិសទៅជេរសាសនាណាអី គេមិន-- គឺគេជេរទេ នេះតាមពិត គេមិនជេរទេ គឺអប់រំតែមាគ៌ាបក្សជំរុញទៅតាមមាគ៌ាបក្ស។ ហ្នឹងហើយដែលគេហៅថា "ប្រឡូកជាប់ជិតស្និទ្ធហ្នឹងមហាជន" រុញមហាជនឲ្យធ្វើភារកិច្ច យើងអប់រំមាគ៌ាបក្សទៅ យើងរុញតទៅទៀត ដូចខ្ញុំបានជម្រាបតុលាការពីលើកមុនអ៊ីចឹង ដាវ គេកាប់ គេកាប់ ហើយគេសំលៀង គេសំលៀងហើយបានគេកាប់តទៅទៀត។ ដូច្នេះមហាជនគេធ្វើអ៊ីចឹង។ គេរុញភារកិច្ច គេអប់រំ គេរុញភារកិច្ចតទៅទៀត។

[១១:៣៦:២៦]

**សៈ** ដូច្នេះតាមដែលខ្ញុំយល់តាមលោកពន្យល់នោះគឺថា សមាជិកម្នាក់ៗគឺថា ត្រូវធ្វើឃោសនាអប់រំ ឬក៏ធ្វើម៉េចឲ្យមហាជនហ្នឹង ក្លាយទៅជាអ្នកមានការគិតគូរអំពីមាគ៌ា អំពីជំហររបស់បក្ស។ តើត្រឹមត្រូវដែរឬទេ?

**ឆៈ** ត្រឹមត្រូវ មហាជននៅក្នុងក្របខ័ណ្ឌ ដែលខ្លួនគ្រប់គ្រង។

**សៈ** ហើយការប្រើពាក្យថា ថាសមាជិកត្រូវតែប្រឡូកជាប់ជិតស្និទ្ធហ្នឹងមហាជន។ តើពាក្យនេះបង្កើតនូវកាតព្វកិច្ច ឬភារកិច្ចដល់សមាជិក គឺថាមិនត្រូវឲ្យនៅឆ្ងាយពីមហាជន ពីប្រជាជនទេ គឺមិនត្រូវ មិនត្រូវឲ្យនៅដាច់ឆ្ងាយ ទំនាក់ទំនងពីសង្គមនោះទេ តើមានន័យអ៊ីចឹង ឬក៏ដូចម្តេច?

**ឆៈ** ត្រូវហើយ គឺថ្នាក់ដឹកនាំសាខាត្រូវនៅក្នុងសាខាហ្នឹង។ ហើយនៅក្នុងមហាជនយុទ្ធជន

ដែលនៅក្នុងសាខាហ្នឹងជាប់។

**ស៖** ប្រសិនបើយើងមើលផ្នែក (ខ) ដែលនិយាយថា ភារកិច្ចនោះគឺត្រូវបំផុសបំផុលចលនាមហាជន ជាពិសេស មហាជនកម្មករ។ តើពាក្យ "បំផុសបំផុលចលនាមហាជន" នោះមានន័យថាដូចម្ដេច? សូមលោកពន្យល់តុលាការឲ្យបានទូលំទូលាយ ដែលតាមខ្លឹមសារដែលគេប្រើនៅក្នុងលក្ខន្តិកៈបក្សនេះ។

[១១:៣៨:៣៩]

**ឆ៖** ពាក្យ "បំផុសបំផុល" នេះ បានន័យថា យុទ្ធជនរបស់យើងកាលណាបំពេញភារកិច្ចមួយរយៈទៅគេហត់ហេវ ហើយការយល់ដឹងមាគ៌ាវាមានការបេះ ឬក៏ស្ពឹកស្រពន់ យើងបង្រៀន យើងនិយាយម្ដង ដើម្បីឲ្យគេកាន់តែក្លៀវក្លាឡើង ឲ្យគេកាន់តែប្ដូរផ្ដាច់អនុវត្តមាគ៌ានេះឡើង ឲ្យគេឃើញថាមាគ៌ានេះ បើយើងអនុវត្តទៅវាបានផលប្រយោជន៍យ៉ាងម៉េចដល់បដិវត្តន៍ ដល់វណ្ណៈកម្មករ កសិករ។ ដូច្នេះ "បំផុសបំផុល" មានន័យអ៊ីចឹង ធ្វើឲ្យគេក្លៀវក្លាឡើង។

**ស៖** សូមអរគុណ។ ឥឡូវនេះ យើងអាចចូលទៅដល់ភារកិច្ចផ្ទៃក្នុងរបស់សមាជិកនៅក្នុងផ្នែក (ក) ដែលថា ដែលនិយាយថា សមាជិកត្រូវមានជីវភាពនៅក្នុងអង្គការសាខាបក្សមួយទៀងទាត់មួយខែម្ដង គឺថាបក្សគ្រប់រូប ទោះជាមាននាទីខ្ពស់យ៉ាងណាក៏ដោយ រហូតដល់ខ្ពស់បំផុតក៏ដោយ។ សំណួររបស់ខ្ញុំសួរលោកថា តើភារកិច្ចនេះគឺត្រូវអនុវត្តក្នុងអំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យដែរឬទេ ដែលថាភារកិច្ចនេះ តម្រូវឲ្យសមាជិកហ្នឹងចូលរួមក្នុងផ្នែកមួយក្នុងជីវភាពខាងសាខាដោយទៀងទាត់នោះ?

[១១:៤០:៣២]

**ឆ៖** ជីវភាពសាខាខ្ញុំបានរាយការណ៍ជម្រាបរួចមកហើយ អ្នកណាមិនបានប្រជុំទុកដូចជាគ្មានជីវិតបក្ស។ ដូច្នេះបក្សតម្រូវឲ្យសាខានីមួយៗមានជីវភាពជាប្រចាំខែជាប់ជានិច្ច ជាទិតៀន និងស្វ័យទិតៀនក្នុងការអនុវត្តជាក់ស្ដែង។ ក្រោយ១៧ មេសា ច្រើនរយាលៗ នេះក្នុងការអនុវត្តជាក់ស្ដែង។ ទៅខាងលើទៀត ខ្ញុំមិនដឹង។

**ស៖** តើលោកយល់ស្របជាមួយរបស់-- ជាមួយខ្ញុំទេ ថាសមាជិកមានកាតព្វកិច្ច ភារកិច្ចផ្ទៃក្នុងហ្នឹងគឺដែលនិយាយក្នុង គ, ឃ, ង, ច ដែលជាការឆ្លុះបញ្ចាំងនៃលក្ខណៈសម្បត្តិដែលតម្រូវឲ្យម្នាក់ៗចូលជាសមាជិកនៅក្នុង-- ចូលទៅក្នុងអង្គការចាត់តាំងរបស់បក្សផ្សេងៗ។ តើលោកយល់ស្របទេថាគំនិតនិយាយអំពីភារកិច្ចដែលបានចែងទាំងនេះមានលក្ខណៈស្រដៀងទៅនឹងគំនិត និងភារកិច្ចដែលចែង

នៅក្នុងលក្ខណៈសម្បត្តិ១០យ៉ាងនៃការការជ្រើសរើសនោះ បាទ? បាទជាពិសេសគឺចំពោះតួនាទីជាកម្មាភិបាលដឹកនាំនៅក្នុងបក្ស។

[១១:៤២:៣៧]

**ឆ៖** ភារកិច្ចផ្ទៃក្នុងមានប្រាំបី(៤) រហូតដល់ ឆ, ជ, ដល់ ជ។ នេះវាជាភារកិច្ចផ្ទៃក្នុងដែលបក្សជនគ្រប់រូបត្រូវតែធ្វើ ដែលបក្សតម្រូវឲ្យធ្វើ។ បើនិយាយអំពីខ្លឹមសារ វាអំណោយគ្នាទៅវិញទៅមកភារកិច្ចផ្ទៃក្នុងនេះ វាអំណាយតែគោលការណ៍យកទិតៀន និងស្វ័យទិតៀនជាមធ្យោបាយប្រចាំថ្ងៃដែលព្រះរាជអាជ្ញាសួរខ្ញុំរួចមកហើយ។ ដូច្នេះក្នុងលក្ខន្តិកៈបក្ស វាមានមាត្រាខ្លះវាអំណោយគ្នាទៅវិញទៅមក។ យល់មួយ វាពាក់ព័ន្ធដល់មួយទៀត។ ដូច្នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង។

**ស៖** សូមអរគុណ។ គឺថាលោកបានប្រើពាក្យមួយ ដែលត្រូវដែលថាក្នុងការពង្រឹង តើលោកយល់ស្របជាមួយខ្ញុំទេ គឺថាគោលការណ៍ជាមូលដ្ឋាននៃលក្ខន្តិកៈបក្សនេះ គឺលក្ខណៈសម្បត្តិសម្រាប់ចូលជាសមាជិក លក្ខណៈសម្បត្តិសម្រាប់ជ្រើសរើសឲ្យចូលទៅជាកម្មាភិបាលដឹកនាំក្នុងអង្គការបក្សនានា ហើយនិងលក្ខណៈសម្បត្តិសម្រាប់ឲ្យសមាជិកហ្នឹងគឺមានភារកិច្ចដូចម្តេចនោះ ជាពិសេសគឺថាវាគាំទ្រគ្នាទៅវិញទៅមក ដើម្បីឲ្យសមាជិកបក្សនោះយល់ច្បាស់ថាតើអ្វីជាកាតព្វកិច្ចរបស់ពួកគេ ហើយនិងការទទួលខុសត្រូវរបស់គេតាមលក្ខន្តិកៈបក្សនោះ?

[១១:៤៤:២៥]

**ឆ៖** ត្រូវហើយ លក្ខណៈសម្បត្តិ១០(៤) ក៏ដោយ គោលការណ៍ក្នុងមាត្រាក្នុងជំពូកផ្សេងទៀតក៏ដោយសុទ្ធតែជាខតម្រូវដែលបក្សដាក់ទៅឲ្យបក្ខជនរបស់ខ្លួនអនុវត្ត ដើម្បីកសាងខ្លួនឲ្យបានល្អ ដើម្បីកសាងខ្លួនឲ្យមានតួនាទីដឹកនាំ។ នេះជាទ្រឹស្តីដែលដាក់ចេញមក។

**ស៖** សូមអរគុណ។ ដូច្នេះខ្ញុំសូមចូលទៅដល់សួរសំណួរមួយចំនួនអំពីវិន័យរបស់បក្ស។ ហើយយើងត្រឡប់ទៅរកមាត្រា៤ នៅក្នុងទំព័រ១៩ នៅក្នុងអត្ថបទភាសាខ្មែរ ដែលនិយាយថា ដើម្បីរក្សានូវសាមគ្គីភាពនៅក្នុង ឯកភាពនៅក្នុងផ្ទៃបក្ស ឲ្យបានល្អហ្នឹង បក្សកំណត់លើកគោលការណ៍គោរពវិន័យនិងអង្គការរបស់បក្ស នៅក្នុងផ្ទៃក្នុងបក្សឲ្យបានហ្មត់ចត់។ វិន័យរបស់បក្សរឹងប៉ឹងបំផុត តែឈរលើគោលការណ៍ភ្ញាក់រឭករបស់បក្ខជនម្នាក់ៗ។ បក្ខជនម្នាក់ៗទោះជាមាននាទីជាអ្វីក៏ដោយ ត្រូវគោរពប្រតិបត្តិតាមវិន័យរបស់បក្សជាដាច់ខាត។ ការគោរពវិន័យ និងគោរពអង្គការរបស់បក្សនេះ គឺការគោរពមាគ៌ានយោបាយរបស់បក្ស គោលជំហរសតិអារម្មណ៍របស់បក្ស គោលជំហរចាត់តាំង និង

លក្ខន្តិកៈរបស់បក្ស។ សំណួរខ្ញុំចំពោះលោកហ្នឹងគឺថា តើកាលណាគេនិយាយអំពីសមាជិករបស់បក្សមានភារកិច្ចត្រូវតែគោរពវិន័យរបស់បក្ស តើមានន័យដូចម្ដេចពាក្យថាគោរពជាដាច់ខាតហ្នឹង នូវវិន័យរបស់បក្សហ្នឹងមានន័យថាដូចម្ដេច?

[១១:៤៦:៤៤]

**ឆ៖** ដាច់ខាតក្នុងការគោរពវិន័យនេះ មានន័យថាត្រូវតែធ្វើប្រកែកមិនបានទេ។ ធ្វើខុសពីនេះក៏មិនបានដែរ។ វិន័យយ៉ាងម៉េច គឺត្រូវតែធ្វើយ៉ាងនោះ។

**ស៖** សូមអរគុណ។ នៅក្នុងលក្ខន្តិកៈគឺថាមាត្រា១ និយាយថា បុគ្គលណាម្នាក់ ឬដែលជំទាស់នឹងមាគ៌ាបក្ស ឬក៏ជំហររបស់បក្ស ឬក៏ប្រឆាំងនឹងលក្ខន្តិកៈបក្ស គឺធ្វើឲ្យមានការបាក់បែកផ្ទៃក្នុងរបស់បក្ស ហើយនិងឯកភាពរបស់បក្ស ការបង្កើតក្រុម ហើយអនុវត្តការបំបែកបក្ស ឬក៏ប្រឆាំងនឹងបដិវត្តន៍មិនព្រមអនុវត្តភារកិច្ចរបស់បក្ស ធ្វើឲ្យបែកការណ៍សម្ងាត់ ធ្វើឲ្យបក្សមានរងគ្រោះ ឬក៏ធ្វើឲ្យបដិវត្តន៍បំផ្លាញដល់ទ្រព្យសម្បត្តិរបស់បក្សជាដើម ប្រព្រឹត្តសីលធម៌ ឬក៏ពាលាអាវ៉ាសែ មិនប្រជុំជីវភាពបីខែជាប់។ល។ សុទ្ធតែជាបទល្មើសវិន័យរបស់អង្គការបក្ស ហើយត្រូវទទួលវិន័យស្រាលឬធ្ងន់ ដូចតទៅ។

[១១:៤៨:២២]

ហើយលក្ខន្តិកៈបានដាក់នូវទោសពិន័យជាបន្តបន្ទាប់ដូចខាងក្រោម៖

ទីមួយ ដែលនិយាយថា ត្រូវធ្វើការទិតៀន ឬក៏ការព្រមាន។ សំណួរទៅលោក ថាតើលោកប្រាប់តុលាការបានទេ ថាតើប្រភេទអ្វីនៃការបំពានប្រភេទណានូវវិន័យរបស់អង្គការ ដែលនាំឲ្យមានការទិតៀន ឬការព្រមាន? ឬក៏អាចនិយាយថា ទម្រង់នៃទណ្ឌកម្មដែលទាបបំផុតហ្នឹងយ៉ាងដូចម្ដេចបាទ?

**ឆ៖** ទម្រង់ ដំបូងខ្ញុំសូមបញ្ជាក់ថា ក្នុងបក្សកុម្មុយនីស្តកម្ពុជាគេមិនប្រើពាក្យទណ្ឌកម្ម ឬផ្ដន្ទាទោសទេ គេប្រើពាក្យអនុវត្តវិន័យ។ ការអនុវត្តវិន័យកម្រិតទាបបំផុតគឺទិតៀន គឺទិតៀន។ ទិតៀននេះគេអាចធ្វើពីរ ទីមួយក្នុងប្រជុំជីវភាពបក្ស ក៏ប៉ុន្តែពេលខ្លះគេមិនធ្វើក្នុងជីវភាពបក្សទេ គេធ្វើសម្ងាត់។ ឧទាហរណ៍ ណាត គាត់មានកំហុសហ្នឹងធ្ងន់ដែរ ក៏ប៉ុន្តែខ្ញុំជាអនុលេខា ខ្ញុំអត់មានសិទ្ធិទិតៀនអីធ្ងន់ធ្ងរទេ។ ខ្ញុំគ្រាន់តែរំឭកគាត់។ នេះជារូបភាពមួយនៃការទិតៀនបើគាត់ធ្វើតាមហើយ គាត់ឈប់ អាហ្នឹងខ្ញុំក៏អត់ប៉ាន់មាត់តទៅទៀតដែរ។ នេះហៅថា ទិតៀន។ ឯចំណែកធ្ងន់ជាងនុំងទៅទៀត ព្រមាន ដូចឧទាហរណ៍មិត្ត ហ៊ា គាត់ធ្វើឲ្យបែកការណ៍ ខាងលើព្រមាន លែងឲ្យមិត្ត ហ៊ា អានឯកសារ ស-២១ ដែលអ្នកទោសឆ្លើយ។ នេះហៅថាព្រមានហើយ។ ហើយមួយទៀតមុននឹងយកមនុស្សចេញ ភារកិច្ច

របស់មិត្ត ហ៊ី គឺយកមនុស្សចេញ ពេលណាចប់យកចេញៗ។ ក៏ប៉ុន្តែមុននឹងយកមនុស្សចេញឲ្យរាយ-ការណ៍មកខ្ញុំ សុំយោបល់ខ្ញុំ នេះហៅថាព្រមានហើយ។ ដូច្នេះខ្ញុំសូមជូនឧទាហរណ៍ជាក់ស្ដែងអ៊ីចឹងដើម្បីស្រួលយល់។

[១១:៥១:១៨]

**ស៖** នៅក្នុងបទពិសោធន៍របស់លោក នៅក្នុងសម័យនោះថាតើមានបុគ្គលណាម្នាក់ត្រូវបានគេដកចេញពីតំណែងទេ បើសិនជាអ្នកហ្នឹងបំពានវិន័យនោះ ធ្វើខុសវិន័យបក្ស?

**ឆ៖** មានៗ។ មិត្តហ៊ុយ ជាបុគ្គលទីបីរបស់ ស-២១ គាត់ខុសហួរហែ មិត្តហ៊ី រាយការណ៍ឲ្យខ្ញុំខ្ញុំរាយការណ៍ទៅលើ។ ដល់ចុងបញ្ចប់ ខ្ញុំរាយការណ៍ទៅលើ ខាងលើសម្រេចឲ្យចាប់កម្ទេច។

**ស៖** ដូច្នេះ ការអនុវត្តវិន័យនេះ គឺថាវាខ្ពស់ជាងពីអ្វីដែលថាត្រឹមតែដកពីតំណែង រហូតដល់មានការចាប់ ហើយកម្ទេចទៀត តើអ៊ីចឹងមែនឬទេ?

**ឆ៖** ត្រូវហើយ។ ការអនុវត្តវិន័យនេះ គឺក្នុងករណីខ្លះវាខ្ពស់ ខ្ពស់ជាងពីដកហូតពីតំណែង។ គេប្រើពាក្យ ព្រះរាជអាជ្ញាឃើញហើយ "ផ្តន្ទាទោសផ្សេងៗ តាមបទល្មើស"។ ក្នុងភាសាខ្មែរ បន្ទាត់ទីប្រាំរាប់ពីក្រោមឡើងលើ គ) បដិសេធចេញពីបក្ស។ នេះខ្ញុំបានជម្រាបព្រះរាជអាជ្ញារួចហើយ ទាល់តែបដិសេធចេញពីបក្ស បានៗផ្តន្ទាទោសបាន។ បដិសេធចេញពីបក្សហើយ ផ្តន្ទាទោសផ្សេងៗតាមបទល្មើសរបស់ខ្លួន។ រួចត្រឹមមិត្ត ហ៊ុយ ខ្ញុំបានលើករួចមកហើយ កុយ ធួន។ បងប៉ុល គាត់ដកសិទ្ធិបក្សដកសិទ្ធិបក្សអស់សិទ្ធិជាមជ្ឈិមបក្ស អស់សិទ្ធិជាមជ្ឈិមបក្ស មិនអាចបំពេញភារកិច្ចជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មទៀតបាន ដកយកមកទុកឃុំឃាំងក្នុងផ្ទះ។ នេះជាការផ្តន្ទាទោស។ សូមចប់ប៉ុណ្ណេះ។

[១១:៥៣:៤៥]

**ស៖** លោកបាននិយាយថា លោកបានរាយការណ៍ពីករណី ហ៊ុយ ថាមានការបំពាន ហើយរាយការណ៍ទៅលើ តើលោករាយការណ៍ទៅថ្នាក់ហ្នឹង តើថ្នាក់លើហ្នឹង លោកសំដៅយកអ្នកណា?

**ឆ៖** ករណីចុងក្រោយដែលមិត្ត ហ៊ុយ មានកំហុសធ្ងន់ធ្ងរហ្នឹង ខ្ញុំរាយការណ៍ទៅបងទីពីរ។ បងទីពីរជាអ្នកសម្រេច។

**ស៖** តើអ្នកណាជាបងទីពីរហ្នឹង?

**ឆ៖** គឺបង នួន ឬហៅឈ្មោះពេញរបស់គាត់ថា នួន ជា។

**ស៖** លោកនិយាយថា កុយ ធួន ត្រូវបានដកពីតំណែង តើលោកអាចជម្រាបតុលាការបានទេ

ថា កុយ ធួន ហ្នឹងជាអ្នកណា?

[១១:៥៥:០០]

**ឆ៖** កុយ ធួន នេះជាសមាជិកមជ្ឈិមបក្សពេញសិទ្ធិ គាត់ទទួលភារកិច្ចជាលេខាភូមិភាគឧត្តរ នេះតាំងពីមុនមករហូតដល់ថ្ងៃ១៧ មេសា ១៩៧៥។ ក្រោយ ១៧ មេសា ១៩៧៥ ខាងលើដកគាត់យកមកធ្វើរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនៅភ្នំពេញ។ ដល់ក្រោយមកគាត់មានរឿងរ៉ាវទៅធ្វើឃាតប្ដីរបស់នារីម្នាក់ដែលគាត់សីលធម៌ជាមួយនុ៎ង។ ម្ល៉ោះហើយ បងប៉ុល ក៏ដកគាត់យកមកដាក់ឃុំឃាំងក្នុងផ្ទះនៅថ្ងៃ០៨ មេសា ១៩៧៦។

**ស៖** ថាតើនៅក្នុងន័យ ការអនុវត្តវិន័យរបស់បក្ស តើមានដំណើរការតុលាការអ្វីទេ ដើម្បីសម្រេចដែលថាអនុញ្ញាតឲ្យ កុយ ធួន គាត់អាចការពារខ្លួនបានទៅនឹងការចោទប្រកាន់? តើមានបែបនោះដែរឬទេ?

[១១:៥៦:២៩]

**ឆ៖** សូមបញ្ជាក់ថា គ្មានតុលាការទេ។ តុលាការជាន់ខ្ពស់ដែលមានប្រកាស ដោយដាក់ កង ចាប ជាប្រធានតុលាការជាន់ខ្ពស់នោះ ជាស្ថាប័នឧបកិច្ចទេ គ្មានអង្គភាព គ្មានសកម្មភាព។

**ស៖** សូមអរគុណ។ តើលោកបានដឹងពីការច្រានចោល ឬការបដិសេធរបស់បក្សកុម្មុយនីស្តកម្ពុជា ថាបដិសេធកម្មាភិបាលណាមួយដែលថាអ្នកហ្នឹងគាត់បំពានវិន័យទាក់ទងទៅនឹងសកម្មភាពប្រឆាំងនឹងបក្សទេ ឬក៏ការប្រព្រឹត្តជាបន្តបន្ទាប់ ឬក៏ប្រព្រឹត្តក្បត់ជាតិ និងបក្សហ្នឹង? តើលោកបានដឹងករណីណាមួយដែលមានការចោទប្រកាន់ហ្នឹងកើតឡើង ហើយសមាជិករូបនោះត្រូវបានគេដកចេញពីបក្ស ប៉ុន្តែមិនត្រូវបានសម្លាប់ទេ? តើមានករណីបែបហ្នឹងដែរឬទេ?

[១១:៥៧:៤៨]

**ឆ៖** ដូចជាគ្មានទេ បញ្ហានេះលើសការយល់ដឹងរបស់ខ្ញុំហើយ។ បញ្ហានេះលើសការយល់ដឹងរបស់ខ្ញុំហើយ។

**ស៖** ទាក់ទងទៅនឹងវិន័យបក្ស នៅពេលដែលលោកជាប្រធានរបស់ ស-២១ បើមានបុគ្គលណាម្នាក់ត្រូវបានគេរកឃើញ ឬគេចោទប្រកាន់ថា ប្រឆាំងបក្ស ឬក៏ក្បត់ជាតិ ឬក៏ក្បត់បក្ស តើតាមការសង្កេតរបស់លោក តើអ្នកហ្នឹងនឹងជួបជោគវាសនាដូចម្ដេច?

**ឆ៖** បញ្ហានៅតែដដែលទេ។ ចំពោះអ្នកដែលប្រព្រឹត្តមានការខុសឆ្គង កម្រិតទីមួយ គឺទិតៀន

និងព្រមាន។ កម្រិតទីពីរ គឺចាប់ខ្លួន ហើយសួរចម្លើយកម្មេច។

[១១:៥៩:១៣]

**លោក វីល្មៀម ស្មីត៖**

លោកស្រីចៅក្រម ឥឡូវនេះខ្ញុំមើលពេល ដូចជាដល់ពេលលោកតុលាការត្រូវសម្រាក។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ។ អរគុណសាក្សី។ ឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទីរសៀលថ្ងៃនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងដែលបាននាំ កាំង ហ្កេកអ៊ាវ ហៅ ឌុច មកផ្តល់សក្ខីកម្មនេះ សូមឲ្យអញ្ជើញគាត់ទៅកាន់បន្ទប់រង់ចាំសម្រាប់សាក្សី ហើយនិងឲ្យនាំអញ្ជើញគាត់មកកាន់ទីកន្លែងផ្តល់សក្ខីកម្មវិញនៅរសៀលនេះ ឲ្យបានមុនអង្គជំនុំជម្រះចូលមកកាន់អាសនៈ។

សូមអញ្ជើញលោកមេធាវី!

សូមអញ្ជើញលោក នួន ជា!

**លោក នួន ជា៖**

ដោយសុខភាពខ្ញុំមិនស្រួល ឈឺចង្កេះ និងឈឺក្បាល ងោងក្បាល ដូច្នោះថ្ងៃរសៀលនេះ ខ្ញុំបាទសូមអនុញ្ញាតលោកប្រធានមិនចូលរួមសវនាការមួយល្ងាច រហូតមួយល្ងាចនេះ។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

លោក នួន ជា មិនចូលរួមសវនាការយ៉ាងម៉េចទៅ? សូមបញ្ជាក់បញ្ហាការមិនចូលរួមនេះ ឲ្យបានច្បាស់។

**លោក នួន ជា៖**

ខ្ញុំបាទ-- ព្រោះនៅចាំស្នាក់នៅខាងក្រោម។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹង មានន័យថា លោកសូមលះបង់សិទ្ធិមិនចូលរួមតាមដានកិច្ចដំណើរការសវនាការផ្ទាល់

នៅក្នុងបន្ទប់សវនាការនេះ។ ហើយទៅបន្តតាមដានកិច្ចដំណើរការសវនាការនៅបន្ទប់ខាងក្រោម តាមប្រព័ន្ធសោតទស្សន៍។ អ៊ីចឹងពិតមែនទេ?

**លោក នួន ជា៖**

បាទ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីអន្តរជាតិការពារក្តី នួន ជា មានបញ្ហាអីទេ អម្បាញ់មិញនេះ?

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំយល់ពីគំនិតនេះហើយ ថាកូនក្តីរបស់ខ្ញុំបានបញ្ជាក់ជូនតុលាការ ថាគាត់នឹងបន្តការតាមដាននៅក្នុងបន្ទប់ខាងក្រោម។ បាទ ខ្ញុំនឹងដាក់ជូននូវសំណើ ហើយនិងការបោះបង់សិទ្ធិចូលរួមផ្ទាល់នៅទីនេះលោកប្រធាន។

[១២:០១:៤១]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បានស្តាប់សំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំលះបង់សិទ្ធិមិនចូលរួម តាមដានកិច្ចដំណើរការសវនាការដោយផ្ទាល់ នៅក្នុងបន្ទប់សវនាការនេះ ដោយទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមប្រព័ន្ធសោតទស្សន៍ ពីបន្ទប់ឃុំខ្លួននៅខាងក្រោមបន្ទប់សវនាការនេះ សម្រាប់រយៈពេលពេញមួយរសៀលនេះ។ ដោយមូលហេតុបញ្ហាសុខភាព មិនអាចអង្គុយ និងតាមដានកិច្ចដំណើរការសវនាការដោយផ្ទាល់បាន។ ហើយអង្គជំនុំជម្រះយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលសម្រេចលះបង់សិទ្ធិមិនចូលរួមដោយផ្ទាល់ ក្នុងកិច្ចដំណើរការសវនាការក្នុងបន្ទប់សវនាការនេះ ដោយទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមប្រព័ន្ធសោតទស្សន៍។ ហើយឲ្យក្រុមមេធាវីការពារក្តីលោក នួន ជា ប្រគល់មកឲ្យអង្គជំនុំជម្រះភ្លាមៗនូវលិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ នួន ជា ក្នុងការមិនចូលរួមផ្ទាល់នៅក្នុងសវនាការនៅរសៀលនេះ។

[១២:០២:៤១]

បង្គាប់ឲ្យមន្ត្រីផ្នែកខាងសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះអាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ នៅក្នុងអំឡុងពេលសវនាការរសៀលនេះ។ ហើយ

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងឲ្យនាំខ្លួនជនជាប់ចោទទាំងពីររូបទៅកាន់បន្ទប់រង់ចាំខាងក្រោម។ ហើយនៅរសៀលនេះ បង្គាប់ឲ្យនាំខ្លួនតែលោក ខៀវ សំផន មកកាន់សាលសវនាការ ដោយឡែក លោក នួន ជា ឲ្យគាត់បន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ នៅបន្ទប់ដែលមានប្រព័ន្ធសោតទស្សន៍ ដែលបានរៀបចំរួចជាស្រេចសម្រាប់រូបគាត់។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០៣ នាទី ដល់ម៉ោង ១៣:៣៣ នាទី)*

[១៣:៣៣:១២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្តីលោក នួន ជា!

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន អស់លោក លោកស្រីចៅក្រម។ ខ្ញុំចង់បានពេលដប់នាទីដើម្បីធ្វើសំណើទៅដល់អង្គជំនុំជម្រះសាលាដំបូង ហើយនិងសុំបន្តនូវការជំទាស់របស់ខ្ញុំ ទាក់ទងទៅនឹងសំណួររបស់សហព្រះរាជអាជ្ញា។ ខ្ញុំចង់លើកឡើងពីព្រឹកមិញ អំពីបញ្ហានេះ ប៉ុន្តែខ្ញុំសម្រេចចិត្តថារង់ចាំដល់ពេលនេះដើម្បីនឹងលើកឡើង ដើម្បីឲ្យលោក លោកស្រីចៅក្រមត្រឡប់មកវិញ ហើយនិងសហព្រះរាជអាជ្ញា ដើម្បីសម្រេចដោយខ្លួនឯងជាមុនសិន។ ប៉ុន្តែខ្ញុំបាននៅស្ងប់ស្ងៀម ប៉ុន្តែឥឡូវនេះ ខ្ញុំត្រូវតែលើកនៅពេលនេះ ហើយជាពិសេសគឺមានកំណត់ហេតុមួយដែលសហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិដែលបានសរសេរកាលពីថ្ងៃពុធ អាទិត្យមុន។ យើងបានអាននូវកំណត់ហេតុនេះ ដែលហៅថា កំណត់សម្គាល់និយាយអំពីការរាំងស្ទះនៅក្នុង អ.វ.ត.ក ដោយមានការភ្ញាក់ផ្អើល ដូចជា មានអារម្មណ៍ថា នឹងដកខ្លួនចេញ។ ការភ្ញាក់ផ្អើលតែមួយ ដោយសារថា មានការរំខានទៅដល់កិច្ចការតុលាការដោយមន្ត្រីតុលាការនៅក្នុងកិច្ចការនេះ នៅក្នុងការងាររបស់សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ។

[១៣:៣៤:៥៦]

ជាសេចក្តី-- ការជ្រៀតជ្រែកដ៏ងងឹតងងុល ដ៏គួរឲ្យខ្មាស់អៀន ហើយខ្ញុំមានអារម្មណ៍ថា នឹងត្រូវដកខ្លួនចេញនៅក្នុងកំណត់ហេតុនោះជាកំណត់ហេតុដ៏ល្អ ដែលបញ្ជាក់អំពីអ្វីដែលយើងបាននិយាយស្របដូចៗគ្នានៅក្នុងបរិបទមួយ នៅក្នុងការការពារ ឬក៏តប មិនឲ្យមានការកោះយាងសម្តេច ព្រះវរបិតា នរោត្តម សីហនុ ដើម្បីមកបំភ្លឺនៅក្នុងរឿងក្តី០០២ នេះ នៅក្នុងសវនាការ តាំងពីដើមស៊ើបអង្កេតនោះផងដែរ។ ដូច្នេះហើយយើងបាន នេះជារបាយការណ៍មួយដែលមាន១៤ទំព័រ ដែលគាត់បានលើកឡើងគឺថា ជាឧបទ្ទហេតុដែលកំហុសព្រហ្មទណ្ឌមួយដ៏ធ្ងន់ ដែលកើតឡើងនៅក្នុងតុលាការនេះ។ នៅក្នុងកំណត់ហេតុនេះ បានសរសេរថា ថាដូចជាដីកាដំណោះស្រាយបែបនោះដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិនោះ ហើយក៏មានដីកាបញ្ជូនរឿងមកជម្រះ ដែលថាៗជាស្ថាប័នមួយដែលដំណើរការមិនត្រឹមត្រូវ។

[១៣:៣៦:១០]

នៅខែតុលា ឆ្នាំ២០១១ យើងបានសរសេរបណ្តឹងឧទ្ធរណ៍មួយ ដែលថាសុំឲ្យស៊ើបអង្កេតមន្ត្រីរដ្ឋាភិបាលមួយចំនួន។ យើងបានសរសេរថា យើងមិនដឹងទេនៅកាលនោះ ថាតើក្នុងកម្រិតណាមួយដែលសច្ចភាព នៃរឿងក្តីនេះ ០០២នេះ ជាពិសេសសំណុំរឿងក្តីនឹងត្រូវបានប៉ះពាល់ដោយសារថា វាមានការធ្វើឲ្យរាំងស្ទះដោយរដ្ឋាភិបាលនោះ។ ដោយសារការស៊ើបអង្កេតទាក់ទងទៅនឹងការរំខាន ឬក៏ការជ្រៀតជ្រែកដល់កិច្ចការតុលាការនេះ យើងមិនបានធ្វើ-- ចាប់ផ្តើមនោះយើងមិនដឹងថាតើកម្រិតនៃការជ្រៀតជ្រែកនៅក្នុងរឿងក្តីរបស់ខ្ញុំ ឬក៏សំណុំរឿងនោះវាមានលក្ខណៈដូចម្តេច? ហើយយើងក៏មិនដឹងថាតើមានភស្តុតាងដោះបន្ទុក ឬក៏ដោះបន្ទុកយ៉ាងដូចម្តេច ដែលអាចនឹងសម្តេចព្រះវររាជបិតា នរោត្តម សីហនុ សម្តេច ជា ស៊ីម សម្តេច ហេង សំរិន បានដឹងនោះ។ ប៉ុន្តែឥឡូវនេះ យើងបានដឹងថា យើងមានភស្តុតាងយ៉ាងរឹងមាំ ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងបានបញ្ជាក់ គាត់ដាក់នៅក្នុងកំណត់ហេតុរបស់គាត់ដែលថា មន្ត្រីតុលាការខាងភាគីខ្មែរ បានប្រើកិច្ចប្រឹងប្រែងដ៏ខ្លាំងដើម្បីរាំងស្ទះដើម្បីគាំទ្រខាងរដ្ឋាភិបាល ហើយមិនមានស្ថាប័នណាមួយក្នុងតុលាការនេះនឹងត្រូវរួចផុតអំពីជំងឺដ៏អាក្រក់នេះនោះទេ។

សហចៅក្រមស៊ើបអង្កេតអន្តរជាតិក៏បានដាក់ស្ថាប័នមួយចំនួន ដែលពាក់ព័ន្ធនៅក្នុងការជ្រៀតជ្រែកនៅក្នុងកិច្ចការតុលាការនេះ ជាបឋមនោះគឺថា សហចៅក្រមស៊ើបអង្កេតជាតិខ្មែរហ្នឹង ចៅក្រម

យូ ប៊ុនឡេង ហើយនិងប្រធានអង្គបុរេជំនុំជម្រះ ប្រាក់ គឹមសាន, ឯកឧត្តម តូនី ក្រាញ់ ក្រឡាបញ្ជី បុគ្គលិក នៅ ស៊ី.អឹម.អេស អ្នកបើកបរ ហើយនិងអ្នកបកប្រែផងដែរ ហើយនិងគឺ ក្រសួងមហាផ្ទៃផងដែរ។ អ្នកទាំងអស់នោះហើយ បានចូលរួម ឬក៏សមគំនិតនៅក្នុងការបំពានក្រមព្រហ្មទណ្ឌអន្តរជាតិ ដែលមានបទល្មើសថា ជាបទជ្រៀតជ្រែកដល់កិច្ចការតុលាការ។ ដូច្នេះ ខ្ញុំសូមលើកឱកាសនេះថា ការជ្រៀតជ្រែកបែបនេះ វាប៉ះពាល់ធ្ងន់ធ្ងរដល់រឿងក្ដី០០២ ដែលកូនក្ដីរបស់ខ្ញុំនេះពាក់ព័ន្ធ។ ទាំងចៅក្រម យូ ប៊ុនឡេង និងចៅក្រម ប្រាក់ គឹមសាន អាចបានរារាំងក្នុងដំណើរការមួយចំនួននៃនីតិវិធីរឿងក្ដី ០០២។

នៅក្នុងរឿងក្ដីរបស់យើង គឺជាមូលដ្ឋាននៃការជំនុំជម្រះនេះ ក៏បង្កឲ្យមានការសង្ស័យជាច្រើន ដោយផ្អែកលើមូលដ្ឋានទាំងអស់នេះគឺថា យើងខ្ញុំសូមប្រកាន់ជំហរថា កិច្ចការដែលអនុវត្តមិនផ្អែកទៅតាមគោលការណ៍ដ៏ត្រឹមត្រូវនោះទេ ប្រសិនបើយើងមើលកំណត់ហេតុរបស់សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ ដែលថានៅក្នុងតុលាការនេះគ្មានភាគីណាមួយ អាចនឹងរួចផុតអំពីការជ្រៀតជ្រែកខាងនយោបាយពីរដ្ឋាភិបាលទេ។ ហើយមន្ត្រីម្នាក់ៗមិនទំនងជាមានសេចក្ដីក្លាហាន ធ្វើការប្រឆាំងនឹងការជ្រៀតជ្រែកដោយប្រយោល ឬក៏ដោយផ្ទាល់ពីរដ្ឋាភិបាលនោះឡើយ។ នេះជាគំនិតមួយដ៏គួរឲ្យស្មុគស្មាញ មិនចេញពីខ្ញុំទេ គឺចេញពីកូនក្ដីរបស់ខ្ញុំផងដែរ។

[១៣:៣៩:៤៤]

ខ្ញុំសូមដកស្រង់សម្ដីរបស់ អ៊ូ វីរៈ ជាប្រធាននៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាកាលពីសប្ដាហ៍មុន។ គាត់និយាយថា ប្រសិនបើរដ្ឋាភិបាលមានឆន្ទៈដើម្បីនឹងធ្វើឲ្យរាំងស្ទះដល់រឿងក្ដីនោះ ថាតើយើងមានសេចក្ដីទុកចិត្តប៉ុនណាដែលយើងអាចធ្វើទៅបាន ដែលថាមិនត្រូវបានសម្រេចជាមុននោះ ដែលថាកំណត់ឲ្យមានលទ្ធផលនៃរឿងក្ដីនេះ ហាក់ដូចជាកំណត់ទុកជាមុនដូចជារឿងក្ដី០០១, ០០២។ ដូច្នេះហើយ យើងមិនមានអ្វីជាទឡ្ហីករណ៍សល់នោះទេ ហើយយើងមិន ហើយខ្ញុំមិនអាចនឹងយោងទៅរកសេចក្ដីថ្លែងការណ៍មួយរបស់សម្ដេចតេជោ ហ៊ុន សែន ទាក់ទងទៅនឹងកូនក្ដីរបស់ខ្ញុំទេ។ ប៉ុន្តែ ខ្ញុំគ្រាន់អាចនិយាយបានថា រដ្ឋាភិបាលបានមានចេតនាឲ្យមានរឿងក្ដីប្រឆាំងនឹងកូនក្ដីរបស់ខ្ញុំ។ ប៉ុន្តែយើងនឹងដាក់ពាក្យសុំឲ្យបានឆាប់បំផុតនៅក្នុងអាទិត្យនេះ ដើម្បីឲ្យទាន់ពេល ហើយនិងអំពាវនាវជាថ្មីម្ដងទៀតជាចុងក្រោយ ដើម្បីឲ្យមានការស៊ើបអង្កេតទៅលើករណីការជ្រៀតជ្រែកកិច្ចការខាងនយោបាយទៅក្នុងរឿងក្ដីរបស់ខ្ញុំ ហើយទាក់ទងនឹងការិយាល័យសហចៅក្រមស៊ើបអង្កេតផងដែរ។ ហើយសុំស្នើឲ្យបង្អង់

នីតិវិធី ដើម្បីឲ្យលោក លោកស្រីចៅក្រមសាលាដំបូងនេះពិនិត្យពិចារណា រហូតទាល់តែមានការស៊ើបអង្កេតនៅករណីនេះចប់ជាមុនសិន។

[១៣:៤១:១៨]

ហើយចំណុចទីបី ហើយយើងបានធ្វើការងារដោយដឹងថា សំណើរបស់យើងក៏នឹងអាចនឹងត្រូវបដិសេធម្ដងទៀតដែរ ដោយមានចៅក្រមបីរូបនៅក្នុងសាលាដំបូងនេះ ហើយយើងមិនអាចនឹងបានសំឡេងភាគច្រើនលើសលប់នោះទេ។ ដូច្នេះគឺយើងមិនរំពឹងថា នឹងបានលទ្ធផលអ្វីពីតុលាការនេះឲ្យបានសមស្របនោះទេ។ ប៉ុន្តែយើងខំធ្វើការងារក្នុងកម្រិតមួយតាមទស្សនៈរបស់យើង ជាស្ថាប័នការពារក្ដី ដូចដែលយើងបានបញ្ជាក់ពីឆ្នាំមុនរួចហើយ រឿងក្ដី០០១ អំ០០២ មិនទាន់ចប់នោះទេ ហើយក៏វាស្ថិតនៅក្នុងចំណុចមួយដ៏ស្រួចស្រាល់នោះដែរ។ ខ្ញុំជឿជាក់ថា ខ្ញុំមិនមែនតែម្នាក់ឯងនៅក្នុងក្រុមការងារទេ ហើយចៅក្រមអន្តរជាតិផ្សេងទៀតនៅក្នុងសាលាដំបូង គឺថាទោះបីជាចៅក្រម ឡាវ៉ែន៍ និងចៅក្រម ខាតវ៉ាយថ៍ក៏ដោយ ក៏ពេលខ្លះមិនអាចនឹងសង្គ្រោះរឿងក្ដីនេះបានដែរ។

[១៣:៤២:២១]

ដូចដែលអង្គបុរេ-- ចៅក្រមអង្គបុរេជំនុំជម្រះនោះដែរ គឺថាបានសម្រេច បានធ្វើការងារស្របទៅតាមឆន្ទៈរបស់រាជរដ្ឋាភិបាល។ ហើយជាពិសេស ហើយទោះជាយ៉ាងក៏ដោយក៏សូមឲ្យអង្គជំនុំជម្រះសាលាដំបូងកុំធ្វើឲ្យរឿងក្ដីនេះក្លាយទៅជាភាពខ្មាស់អៀនឲ្យសោះ។

ការជំនុំជម្រះនេះ នឹងគប្បីតែពិនិត្យទៅតាមទស្សនៈ ទៅតាមច្បាប់ និងលិខិតបទដ្ឋានទាំងអស់ដែល អ.វ.ត.ក ត្រូវគោរពតាម។ មិនត្រឹមតែធានានូវការជំនុំជម្រះយុត្តិធម៌សម្រាប់កូនក្ដីខ្ញុំទេ សម្រាប់សាធារណជន ហើយនិងគោរពទៅតាមគោលការណ៍វិជ្ជាជីវៈ កិត្តិសព្ទរបស់បុគ្គលិកអន្តរជាតិទាំងអស់ទាំងចៅក្រម និងមន្ត្រីផ្សេងៗនៅក្នុងរឿងក្ដីនេះផងដែរ។

ដល់ចំណុចមួយដែលថា ការស្ងប់ស្ងាត់មិនចាត់វិធានការអ្វីនោះ ហើយនិងការចៀសវាងមិនធ្វើការសម្រេចនូវអ្វីដែលទាក់ទងទៅនឹងបញ្ហានយោបាយនោះ គឺជាកត្តាមួយ។ អ្វីដែលលើកឡើងនៅក្នុងសំណើរបស់យើង ថាតើលោកស្រីចៅក្រម ខាតវ៉ាយថ៍ និងចៅក្រម ឡាវ៉ែន៍ ហើយនិងចៅក្រមអន្តរជាតិផ្សេងៗទៀត ជឿជាក់ដ៏ស្មោះស្ម័គ្រដែរឬទេ ថាអង្គជំនុំជម្រះសាលាដំបូងនេះអាចនឹងធ្វើសេចក្ដីសម្រេចប្រឆាំងនឹងឆន្ទៈរបស់រាជរដ្ឋាភិបាលកម្ពុជានោះ? ហើយយើងរំពឹង និងចាំស្ដាប់នូវចម្លើយពីអង្គជំនុំជម្រះសាលាដំបូង។ សូមអរគុណ។

[១៣:៤៣:៥៣]

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ យើងខ្ញុំជំទាស់ទៅនឹងកំណត់សម្គាល់របស់មេធាវីការពារក្តី។ នៅក្នុងរឿងនេះយើងលើកឡើងអំពីបញ្ហា ពីភាពមិនយុត្តិធម៌នៅក្នុងការស៊ើបអង្កេត នោះមានន័យថា លោកច្រានចោលនូវការងារបឋមៗដែលធ្វើឡើងដោយអង្គបុរេជំនុំជម្រះ។ ប៉ុន្តែពេលនេះ យើងនិយាយអំពីរឿងក្តី០០៣, ០០៤ មិនមែនរឿងក្តីនេះទេ។ តាមអ្វីដែលយើងបានដឹង សហព្រះរាជអាជ្ញា គឺថាជឿជាក់ថាទាំងស្រុង ដែលថាអង្គជំនុំជម្រះសាលាដំបូងនេះអាចនឹងធ្វើសវនាការរឿងក្តីនេះដើម្បីធានានូវយុត្តិធម៌នៅក្នុងរឿងក្តីទាំងមូល។ រីឯដំណើរការដែលបានកើតឡើងនៅថ្ងៃនេះជាដើម បានបង្ហាញពីគោលដៅនោះហើយ។ មេធាវីការពារអាចនឹងប្រមូលភស្តុតាង ឬក៏បង្ហាញនូវភស្តុតាងរបស់ខ្លួនបាន។

[១៣:៤៥:០១]

នៅក្នុងករណីនេះ លោក លោកស្រីចៅក្រមដឹងហើយ គឺថាមេធាវីការពារមិនបានបង្ហាញភស្តុតាងអ្វីក្រៅពីប្រាំមួយនោះទេ។ រីឯមេធាវីការពារក្តីវិញ គឺថាបានស្នើចង់សួរជនជាប់ចោទអំពីប្រវត្តិរបស់គាត់ក៏ដោយ គាត់បានមានពេលពីរម៉ោង ឬក៏កន្លះម៉ោង នោះគឺថាយើងបានស្តាប់ទៅ គឺថាគាត់បានធ្វើដូច្នោះ ប៉ុន្តែបញ្ហាខ្លះវាមិនពាក់ព័ន្ធ។ ប៉ុន្តែនេះវាកើតឡើង បញ្ហាផ្សេងៗដែលទាក់ទងទៅនឹងភាពគ្មានយុត្តិធម៌ ក្នុងការស៊ើបអង្កេតនៅក្នុងរឿងក្តី០០២ ប្រសិនបើមានមែននោះ លោក លោកស្រីចៅក្រមមានលទ្ធភាព ហើយមានអំណាចដើម្បីនឹងសម្រេច ដើម្បីធានាថាទិដ្ឋភាពណាមួយនៃករណីនោះនឹងត្រូវបានស៊ើបអង្កេត។

[១៣:៤៥:៤៧]

ដូច្នេះសហព្រះរាជអាជ្ញាសូមជម្រាបថា អ្វីដែលលើកឡើងនោះ គឺមិនទាក់ទងនឹងរឿងក្តីនេះទេ។ ហើយសុំស្នើឲ្យលោក លោកស្រីចៅក្រមមេត្តាអនុញ្ញាតបន្តនូវអ្វីជានីតិវិធី ហើយនិងបើកសវនាការតាមវិធីមួយ ដែលយុត្តិធម៌ និងស្របទៅតាមច្បាប់។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញលោកស្រីមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

[១៣:៤៦:២២]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ខ្ញុំមានការកត់សម្គាល់បន្តិចបន្តួចតែប៉ុណ្ណោះ។ ខ្ញុំមិនចង់ផ្តល់យោបល់លើសំណុំរឿង០៣, ០៤ នោះទេ ដោយសារខ្ញុំមិនជាអ្នកទទួលបន្ទុកលើសំណុំរឿងនោះទេ។ ទោះបីជាយើងមានការលំបាកយ៉ាងណាក៏ដោយ ដើម្បីជាប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី។ យើងគិតថា ជាការសំខាន់ណាស់ដែលត្រូវកុំឲ្យមានភាពភ័ន្តច្រឡំ ច្របូកច្របល់។ អ៊ីចឹងត្រូវធ្វើឲ្យមានការបែងចែករវាងភាគីជាតិ និងអន្តរជាតិឲ្យច្បាស់។ បើយើងគិតថា នេះជាបញ្ហាមួយគួរឲ្យសោកស្តាយណាស់ យើងចង់ យើងពុំមានជម្រើសអីទេ យើងគ្រាន់តែថាចង់ឲ្យអង្គជំនុំជម្រះសាលាដំបូងជាអ្នកសម្រេចទាក់ទងនឹងបញ្ហានេះ។ ហើយយើងទុកចិត្តលើតុលាការ ហើយយើងសង្ឃឹមថា ការទុកចិត្តរបស់យើងនេះ ជាការត្រឹមត្រូវ ហើយយើងសុំឲ្យចៅក្រមទាំងអស់នោះនឹងផ្តល់សេចក្តីសម្រេចក្នុងរឿង០០២នេះ ដោយសមស្រប។ សូមអរគុណ។

[១៣:៤៧:៣០]

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន!

**លោក អាកទួរ វែកកែន៖**

សូមអរគុណលោកប្រធាន អស់លោក លោកស្រីចៅក្រមជាទីគោរព។ ភាគីការពារក្តីរបស់ក្រុម ខៀវ សំផន ចង់ជម្រាបជូនថា ខាងភាគីក្តី ខៀវ សំផន បានចុះហត្ថលេខាលើលិខិតរួមមួយ ដែលសុំឲ្យមានការបើកការស៊ើបសួរទៅលើកិច្ចបើកការចោទប្រកាន់ ដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត ដែលបានដាក់សរសេរលើលិខិត ដែលមេធាវីក្រុម នួន ជា បានលើកឡើងអម្បាញ់មិញនេះ។ ផ្ទុយស្រឡះពីអ្វីដែលបានលើកឡើងដោយសហព្រះរាជអាជ្ញា ខ្ញុំឃើញហាក់ដូចជាយល់ឃើញថា ព័ត៌មានដែលសហចៅក្រមស៊ើបអង្កេតបានផ្តល់ជូននេះ ដែលថាគាត់បានធ្វើការបកអាក្រាត បង្ហាញនូវព័ត៌មានថ្មីៗនេះ គឺជា គឺបានន័យថា អង្គជំនុំជម្រះពុំបានដឹងអំពីបញ្ហានេះទេ ឬអំពីសេចក្តីសម្រេចពីមុនៗ ឬក៏មិនបានគិតអំពីកិច្ចស៊ើបសួរដែលបានធ្វើឡើងកន្លងមកនេះទេ។ ដោយសារហេតុនេះហើយ បានន័យថា បកអាក្រាតទាំងអស់នេះ ដោយហេតុថា ជាការបកអាក្រាតមានហេតុផល។ ដូច្នេះ សុំឲ្យមានការស៊ើបអង្កេតលើធាតុផ្សំថ្មីនេះ ដូចខាងដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងអ៊ីចឹង។ គឺថាសុំ យើងទុកចិត្តទៅ

លើអង្គជំនុំជម្រះ។ ក៏ប៉ុន្តែនេះប្រហែលជា គ្រាន់ជាសេចក្តីសង្ឃឹមដោយអត់ប្រយោជន៍តែប៉ុណ្ណោះ ដូចៗយើង ដូចកាលដែលពាក្យដែលគេលើកឡើងថា កាលដែលមានព្យុះ ផ្ទុះអារុធនុយក្លេអ៊ែរ នៅ*ឌីណឺប៊ីល៍*នោះ គឺថាវាមកដល់កន្លែងមួយត្រូវឈប់ ក៏ប៉ុន្តែតាមពិតវាមិនឈប់ដូចដែលយើងគិតទុកនោះទេ។

[១៣:៤៩:៤៦]

ដូច្នេះ គឺថាជាការប៉ះទង្គិចនោះ វាមិនអាចកំណត់មកត្រឹមតែថា រឿងក្តី០៣, ០៤ នោះទេ គឺថាវាអាចលើសពីនុ៎ង។ ហើយអាស្រ័យ ហេតុដូច្នេះហើយបានយើងថា ការបកអាក្រាតនេះមានហេតុផលត្រឹមត្រូវ។ ដូច្នេះ សុំឲ្យមានការបើកការស៊ើបអង្កេត ដែលថាតុលាការយើងនេះទទួលឥទ្ធិពលអំពីរដ្ឋាភិបាលកម្ពុជា។ ភាគីការពារក្តីរបស់ក្រុម ខៀវ សំផន ក៏សុំគាំទ្រ នូវការសុំឲ្យមានការបើកស៊ើបអង្កេតនេះ ពីព្រោះថាវាមានហេតុផល ហើយដែលថាពាក្យសុំនេះ យើងកំពុងតែធ្វើ គឺថាយើងសុំឲ្យមានការព្យួរសវនាការសិន នៅក្នុងរយៈពេលស៊ើបសួរនេះ។ ចាំដល់ពេលដែលថា មានរកឃើញថាមាន ឬពុំមានសម្ពាធនោះ បានយើងចាប់ផ្តើមសវនាការឡើងវិញ។ ដូច្នេះ បើសិនជាពុំដូច្នេះនោះទេ គឺថាយើងមិនអាចធ្វើបន្តទៀតបាននោះទេ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ មានអីទៀតទេ?

បើមិនមានទេ សូមផ្តល់វេទិកាជូនទៅតំណាងព្រះរាជអាជ្ញាអន្តរជាតិ ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សីនៅចំពោះមុខនេះ គឺលោក កាំង ហ្កេកអ៊ាវ ហៅ ឌុច ។

[១៣:៥១:២៧]

**លោក វីណ្ឌៀម ស្មីត៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រមផងដែរ។

**សួរដោយលោក វីណ្ឌៀម ស្មីត៖**

**ស៖** លោក កាំង ហ្កេកអ៊ាវ មុនពេលដែលយើងសម្រាកពិសាអាហារថ្ងៃត្រង់នោះ យើងបានពិភាក្សាអំពីវិន័យរបស់សមាជិកបក្ស។ នៅពេលដែលយើងពិនិត្យមើលបញ្ហាដែលទាក់ទងទៅនឹងការដាក់វិន័យដល់បក្ស ហើយកាតព្វកិច្ចភារកិច្ចរបស់សមាជិកបក្សក្នុងការលើកកម្ពស់មាគ៌ាបក្ស ហើយនិងគោលជំហររបស់បក្សនោះ ហើយយើងនឹងពិនិត្យមើលលក្ខណៈសម្បត្តិដែលតម្រូវឲ្យមានសម្រាប់ឲ្យសមាជិកអាចចូលជាសមាជិកបក្សបាន ហើយយើងក៏បានពិនិត្យមើលតួនាទី ពិនិត្យតាមដានដែលបក្ស

មានសម្រាប់សមាជិកម្នាក់ៗដើម្បីធានាថា គេមានប្រវត្តិច្បាស់លាស់ ហើយនិងស្អាតស្អំនៅក្នុងមាគ៌ាបក្ស។ តើត្រឹមត្រូវទេដែលយើងនិយាយថា នោះគឺជាបរិយាកាសដ៏គួរឲ្យភ័យខ្លាចមួយដែលឡោមព័ទ្ធសមាជិកបក្សទាំងអស់នៅក្នុងសម័យនោះចាប់ពីឆ្នាំ១៩៧៥ រហូតទៅដល់ឆ្នាំ១៩៧៩ នោះ។ តើបែបនេះឬទេ?

**ឆ៖** យើងអាចនិយាយបានបែបនេះ។

**ស៖**ប្រហែលជាយើងអាចពិនិត្យមើលឯកសារមួយ IS19.157 សូមអនុញ្ញាតតុលាការដាក់បង្ហាញនៅលើអេក្រង់ ហើយខ្ញុំជូនឯកសារលើក្រដាស ជូនដល់លោកសាក្សីពិនិត្យ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត ហើយមន្ត្រីរដ្ឋបាលតុលាការយកឯកសារពីតំណាងសហព្រះរាជអាជ្ញាអន្តរជាតិជូនទៅសាក្សីដើម្បីពិនិត្យ។

*(មន្ត្រីរដ្ឋបាលតុលាការយកឯកសារជូនសាក្សី)*

[១៣:៥៣:៤១]

**សួរដោយលោក វីណ្ស៊ៀម ស្មីត៖**

**ស៖** សូមអរគុណ។ នៅពេលដែលលោកពិនិត្យឯកសារនេះ លោកបានយោងទៅរកការអនុវត្តរបស់សមាជិកបក្សកុម្មុយនីស្តកម្ពុជាដែលត្រូវសរសេរនូវប្រវត្តិផ្ទាល់ខ្លួនរបស់ខ្លួន ដើម្បីឲ្យគេកត់ត្រាបញ្ជូនទៅតាមលំដាប់លំដោយរហូតទៅដល់ថ្នាក់មួយដើម្បីធានាថា ប្រវត្តិរបស់សមាជិកម្នាក់ៗអាចនឹងស្ថិតនៅក្នុងគុណភាពមួយ ឬក៏ជាប្រភេទមួយដែលបក្សអាចទទួលយកបាន។ បើលោកមើលឯកសារមួយនេះប្រហែលថា ខ្ញុំបញ្ជាក់ថាឈ្មោះនៅខាងលើគេដាក់ថា ឈ្មោះដើម ឈ្មោះ រស់ អែម។ បន្ទាប់ទៅទៀត នៅខាងក្រោមនៃឯកសារនេះ បញ្ជាក់ថា រស់ អែម គឺជានីរសារនៅស-២១។

តើលោកពិនិត្យមើលឯកសារ ហើយជម្រាបតុលាការថាតើ នេះជាប្រភេទនៃឯកសារដែលលោកនិយាយសំដៅនោះដែរឬទេ? ទាក់ទងទៅនឹងការសរសេរនូវប្រវត្តិផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗដែលចង់ធ្វើជាសមាជិកបក្សនោះបាទ។

[១៣:៥៦:០៩]

ប្រហែលជាលោក កាំង ហ្កេកអ៊ាវ ហើយយើងមើលចំណុចមួយនៅក្នុងចុងបញ្ចប់នៃឯកសារនេះទាក់ទងទៅនឹងទំព័រមួយដែលនិយាយថា ជាមិត្តភក្តិ ឬក៏នៅក្នុងក្រុមហ្នឹង គឺថាទំនាក់ទំនងនៅខាង

ក្រៅបក្ស ហើយនិយាយអំពីលំដាប់លំដោយទាក់ទងតាំងពីកុមារភាព រហូតដល់ចុងក្រោយ ហើយនៅខាងចុងក្រោយ ខែកក្កដា ឆ្នាំ១៩៧៦ និង៧៧។ តើលោកអាចជម្រាបតុលាការបានទេថា បុគ្គលម្នាក់នេះជាបឋមនេះលោកស្គាល់គាត់ទេ? ហើយទីពីរ ថាតើប្រភេទនៃឯកសារនេះ គឺជាឯកសារដែលលោកបានឃើញកាលពីមុន ហើយក៏ជាឯកសារមួយដែលលោកអាចប្រាប់ថា តើប្រភេទឯកសារនេះគេផលិត ឬក៏គេធ្វើឡើងក្នុងគោលបំណងអ្វី? ដោយវិធីណា? សូមអញ្ជើញ។

**ឆ៖** ឯកសារនេះ ជាឯកសារស-២១ មិត្តអែម ជាយុទ្ធជនរបស់ខ្ញុំ ពីដើមគាត់នៅមន្ទីរ១៣។ ទម្រង់ប្រវត្តិរូបនេះ ខ្ញុំគិតថាប្រហែលជាមានលក្ខណៈដូចគ្នាទូទាំងប្រទេស។ ក៏ប៉ុន្តែខ្ញុំៗប្រើអាទម្រង់ប្រវត្តិនេះ ដើម្បីឲ្យយុទ្ធជនម្នាក់ៗសរសេរ ដើម្បីតម្កល់ទុក។ នេះមួយផ្នែកទៅ។ ហើយមួយផ្នែកទៀតពេលរៀនចប់វគ្គសិក្សាមួយឆ្នាំៗ បក្ខជនគ្រប់រូបត្រូវបំពេញប្រវត្តិរូបបម្រុងនេះដើម្បីផ្លង។ នេះសូមបញ្ចប់ប៉ុណ្ណឹង។

[១៣:៥៨:២៣]

**ស៖** ដូច្នេះ យើងអាចយល់អំពីលក្ខណៈនៃការអនុវត្តជាលក្ខណៈរីករាយដាល។ ដូច្នេះហើយ ថាតើលោកមានបុគ្គលិកធ្វើការនៅស-២១ នោះចំនួនប្រហែលប៉ុន្មាននាក់ដែរ?

**ឆ៖** បញ្ហានេះ ខ្ញុំភ្លាប់អត់បានទេ។ បញ្ជីដែលបង្ហាញខ្ញុំ អង្កាល់សវនាការសំណុំរឿងលេខ០០១ នោះ ពិនិត្យមើលតាមនុ៎ងចុះ! បញ្ជីហ្នឹងបង្ហាញរួចហើយ។ ស-២១ មានប៉ុន្មាននាក់។

**ស៖** ប្រហែលខ្ញុំសួរអំពីការអនុវត្តនៃការធ្វើជីវប្រវត្តិនេះ។ នៅពេលដែលគេធ្វើជីវប្រវត្តិនេះហើយ ថាតើផ្ញើទៅណា? ហើយផ្ញើទៅឲ្យអ្នកណាដែរ?

**ឆ៖** ជាពិសេស ប្រវត្តិរូបនេះមិត្ត ហែម គាត់ជាមហាជនធម្មតាទេ អត់ផ្ញើទៅណាទេ តម្កល់ទុកនៅ ស-២១ តាមក្រុម តាមពួករបស់គេ។ ប្រមូលផ្តុំមកនៅស-២១។ នៅក្នុងគណៈកម្មាការធិការ ស-២១ មានមិត្ត ហ៊ កាន់កាប់។

[១៣:៥៩:៥៨]

**ស៖** ថាតើ អែម នេះជាសមាជិករបស់បក្សដែរ ឬក៏មិនមែនទេ?

**ឆ៖** មហាជនធម្មតា។ បានន័យថា យុវកកក៏គ្នាមិនទាន់ចូលផង ជាយុទ្ធជនធម្មតាម ខ្ញុំនាំចូលមកប្រហែលជាឆ្នាំ១៩៧៤។ ដើម៧៤ ឬក៏ចុង៧៣ ចូលមកន៏ៃ ម-១៣។

**ស៖** ចុះក្រោយមកគាត់បានក្លាយទៅជាសមាជិកបក្សដែរឬទេ?

**ឆ៖** រហូតដល់ពេលរត់យួន គឺអត់បានក្លាយជាសមាជិកបក្សទេ។

**ស៖** នៅផ្នែកខាងលើនៃប្រវត្តិរូបមួយនេះ បានលើកឡើងឈ្មោះបដិវត្តន៍ ហើយឈ្មោះបដិវត្តន៍នោះដូចគ្នា គឺ រស់ អែម។ ឈ្មោះបដិវត្តន៍ គឺផ្តល់តែចំពោះសមាជិកបក្សតែប៉ុណ្ណោះ ឬក៏ផ្តល់ជូនទៅដល់បុគ្គលទាំងឡាយដែលធ្វើការឲ្យបក្សផងដែរ?

[១៤:០១:១៩]

**ឆ៖** មុនឆ្នាំ១៩៧៥ ជាពិសេសមុនឆ្នាំ១៩៧០ បក្ខជនមួយរូបៗ ជនចម្រើនមួយរូបៗសុទ្ធតែមានឈ្មោះសម្ងាត់ អង្កាល់នុំងគេហៅថា ឈ្មោះបដិវត្តន៍។ ដូចខ្ញុំអ៊ីចឹង កាំង ហ្កេកអ៊ាវ ដល់ធ្វើបដិវត្តន៍ឈ្មោះនៅក្នុងការងារបដិវត្តន៍របស់ខ្ញុំ ឌុច។ ឌុច តាំងពីនុំងមករហូត។ ដល់ក្រោយឆ្នាំ១៩៧៥ (សូមទោស) ដល់ក្រោយឆ្នាំ១៩៧១ មានមួយចំនួនគេដាក់ឈ្មោះពិត។ ឈ្មោះបដិវត្តន៍ ហើយនិងឈ្មោះនៅជាមួយគ្នា។

**ស៖** សូមអរគុណ។ សំណួរ ពេលដែលយើងមើលប្រវត្តិរូបនេះ យើងឃើញទម្រង់ដែលជាលក្ខណៈវាយ ទម្រង់បែបបទវាវាយដោយកំព្យូទ័រ បន្ទាប់មកឈ្មោះនេះ សរសេរដោយដៃ។ ដោយយើងឃើញហើយ រស់ អែម ។ ផ្នែកទីពីរ និយាយអំពីប្រពន្ធ ឈ្មោះប្រពន្ធ និងកូនប្រសិនបើមាន។ ទីបីនិយាយអំពីកូន។ ហើយទីបួន និយាយអំពីឪពុកម្តាយ។ ទីប្រាំ និយាយអំពីឪពុកម្តាយក្មេក។ ទីប្រាំមួយនិយាយអំពីបងប្អូនបង្កើត។ ផ្នែកទីប្រាំពីរ និយាយអំពីមិត្តភក្តិជិតស្និទ្ធ និងក្រុម និងការប្រាស្រ័យក្រៅអង្គការបក្ស អង្គការបដិវត្តន៍។ ហើយសំណួរទាំងឡាយនៅស្ទើរតែគ្រប់ផ្នែកនោះ គេសួរថាតើអ្នកទាំងអស់នោះមកពីវណ្ណៈណា? ហើយមានសម្ព័ន្ធនយោបាយយ៉ាងម៉េចដែរ? ហើយនិងការអប់រំមានកម្រិតបែបណា? យើងឃើញថាសំណួរប្រភេទទាំងអស់នេះនៅក្នុងផ្នែកស្ទើរតែទាំងអស់។ ដូច្នេះហើយខ្ញុំចង់សួរថា ហេតុអ្វីបានជាទម្រង់ប្រវត្តិរូបនេះសួរមានសំណួជាច្រើនសួរទៅលើបុគ្គល មានសំណួរជាច្រើនទម្រង់បែបនេះសួរទៅលើបុគ្គល? តើហេតុអ្វីបានជាគេសួរសំណួរទម្រង់បែបនេះ?

[១៤:០៣:៥២]

**ឆ៖** បុគ្គលហ្នឹង គឺសំដៅបុគ្គលជាមិត្តភក្តិ ឬក៏ជាឪពុកម្តាយ ឬក៏ជាបងប្អូនដែលមានឥទ្ធិពលនយោបាយមកលើយើង។ អ៊ីចឹងហើយបានៗជាទម្រង់ហ្នឹងសួរទៅអ៊ីចឹង ដើម្បីឲ្យយល់នយោបាយរបស់បុគ្គលដែលធ្វើប្រវត្តិរូបនេះ។

**ស៖** សំណួរដែលខ្ញុំចង់សួរនោះគឺថា ហេតុអ្វីបានជាគេចង់បានព័ត៌មានយ៉ាងច្រើនបែបនេះពី

បុគ្គលិកដែលធ្វើការនៅស-២១? តើមានគោលបំណងអ្វីដែរ? តើគោលបំណងដែលគេសួរសំណួរអំពីវណ្ណៈ អំពីកម្រិតអប់រំ និងបញ្ហានយោបាយនោះ? តើហេតុអ្វីបានជាគេសួរព័ត៌មានបែបនេះទៅលើសមាជិកដែលធ្វើការនៅ ស-២១? ហេតុអីចាំបាច់ធ្វើដូច្នេះ?

[១៤:០៥:០០]

**ឆ៖** តាមខ្ញុំចាំ គម្រោងធ្វើប្រវត្តិរូបនេះ មិនមែនជាគម្រោងចេញពីគំនិតផ្ដើមផ្ទាល់របស់ស-២១ ទេ។ ទោះបីពីសម័យ ណាត មកក៏ដោយ។ គម្រោងនេះមានទម្រង់កែលម្អជាបណ្ដើរៗរហូត ពី៧១ មករហូតដល់៧៥ ឃើញប្រើទម្រង់នេះ។ ដូច្នេះមិនមែនតែបុគ្គលិកស-២១ ទេ ដែលត្រូវតែធ្វើរាយ-ការណ៍ជូនបក្សល្អិតល្អន់របៀបនេះ។ នៅក្នុងអង្គភាពផ្សេងទៀតក៏ដូច្នោះ។ នេះហើយដែលហៅថាក្ដាប់ប្រវត្តិរូបឱ្យបានច្បាស់លាស់ជាបន្តបន្ទាប់។ នេះហើយដែលហៅថារាយការណ៍ជូនបក្សដោយស្មោះត្រង់អំពីប្រវត្តិរូបបដិវត្តន៍របស់ខ្លួន។

**ស៖** ព័ត៌មាននៅក្នុងទម្រង់នេះ រស់ អែម ថាតើ រស់ អែម នេះជាអ្នកទោស ឬក៏ជាបុគ្គលិកនៅស-២១?

**ឆ៖** (សាក្សីសើច) ខ្ញុំបានជម្រាបហើយថាជាយុទ្ធជនខ្ញុំ ដែលខ្ញុំប្រមូលពីព្រៃជ្រៅ តាំងពីនៅជាកុមារម្ល៉េះ មិនទាន់ពេញវ័យ យកមកនៅម-១៣ ជាយុទ្ធជនរបស់ខ្ញុំ។ អ្នកទោសគេមិនធ្វើប្រវត្តិរូបអីចឹងទេ។ មកដល់សួរ ហើយនេះទៅ។

[១៤:០៦:៣៦]

**ស៖** តាមអ្វីដែលលោកដឹង ទម្រង់បែបបទហ្នឹងបានចែកជូនទៅដល់អង្គភាពផ្សេង ឬក៏ទៅដល់ផ្នែកផ្សេងដែរឬទេ ដើម្បីឱ្យបុគ្គលិកគេនោះបំពេញព័ត៌មានដូចគ្នាដែរ?

**ឆ៖** ស-២១ អត់ចែកទៅអ្នកណាទេ។ ស-២១ ប្រើនៅតែក្នុងស-២១ ខ្លួនឯង។ ក៏ប៉ុន្តែខ្ញុំបានជម្រាបហើយ ទម្រង់បែបនេះចាប់ផ្ដើមធ្វើបណ្ដើរៗតាំងពី៧១ ហើយចេះតែកែលម្អបណ្ដើរៗមក រហូតបានគ្រប់ជ្រុងជ្រោយរបៀបនេះ។ ដូច្នេះខ្ញុំយល់ថា ទម្រង់បែបនេះមានលក្ខណៈរួមទូទាំងប្រទេស។

**ស៖** តើលោកដឹងថា លោកទទួលទម្រង់បែបបទហ្នឹងពីកន្លែងណាដែរ? ហើយអ្នកណាគេដែលយកទៅប្រគល់លោកនៅមន្ទីរសន្តិសុខស-២១ នៅទីនោះហ្នឹង?

**ឆ៖** អង្កាល់ខ្ញុំធ្វើប្រធានមន្ទីរ១៣ ក៏ខ្ញុំប្រើទម្រង់ប្រវត្តិរូបរបៀបនេះ ប៉ុន្តែមិនទាន់បានពេញលេញអីចឹងទេ។ ដល់ចូលមកដល់ស-២១ ទម្រង់នេះវាសល់ពី ណាត ពី៧០៣មក។ អីចឹងហើយបានៗ

ខ្ញុំសន្និដ្ឋានថា ទម្រង់នេះវាវិវត្តន៍កាន់តែពេញលេញឡើង តាំងពី៧១ រហូតមដល់ទម្រង់ចុងក្រោយគឺរបៀបនេះ។ ចំណែកទម្រង់ដែលប្រើប្រាស់នៅស-២១ នេះវាសល់តាំងពីសម័យ ណាត។ ដូច្នេះពីលើ ណាត ទៅទៀត គេចែកមកហើយ។

[១៤:០៨:២១]

**ស៖** សូមអរគុណ។ ប្រសិនបើខ្ញុំសូមឲ្យលោកមើលឯកសារមួយទៀតគឺ D108/7.7 យើងមានឯកសារជាក្រដាស ដូច្នេះខ្ញុំសូមអនុញ្ញាតស្នើសុំក្រឡាបញ្ជី ឬក៏មន្ត្រីសុំឲ្យយកទៅផ្តល់ជូនសាក្សី គឺ D108/7.7។

លោក កាំង ហ្កេកអ៊ាវ សូមឲ្យលោកមើលឯកសារនេះ ជាពិសេសនៅត្រង់ទំព័រទី១ ហើយលោកមើលទៅ តើអ្នកណាគេជាអ្នកចុះហត្ថលេខានៅលើទំព័រដំបូងហ្នឹង ហើយថ្ងៃខែ ថ្ងៃណាដែរ? ហើយប្រសិនបើលោកមើលទំព័របន្ទាប់ ជាពិសេសទំព័របន្ទាប់ហ្នឹងគឺនៅចុងខាងក្រោម មានថ្ងៃខែដែរ។ ហើយក្រោយពីលោកមើលឯកសារនេះ ខ្ញុំសូមសួរសំណួរមួយចំនួនអំពីឯកសារនេះ។

[១៤:០៩:៥៣]

**ឆ៖** អរគុណ។ មុននឹងឆ្លើយសំណួររបស់សហព្រះរាជអាជ្ញា ខ្ញុំសូមជូនជាការសង្កេតបន្តិចអំពីសហព្រះរាជអាជ្ញា លោកសួរខ្ញុំ ថាម៉េចបានដឹងថាគេជម្លៀសទៅកន្លែងផ្សេងទៀតទូទាំងប្រទេស។ នេះជាភស្តុតាងមួយ បញ្ជាក់ថា ណាត គាត់ដើរទៅតាមផ្លូវលេខ៦ ទៅឃើញ គាម ទត ទៅឃើញ តាប់ ប៊ុនឌីន ទៅឃើញ ង៉ូវ វ៉ា ហើយនិងទៅឃើញ ស កាពុន នៅភូមិព្រែកផ្តៅ អ៊ំ សូមទោស ភូមិផ្តៅជុំ ក្បែរផ្សារស្គន់។ ហើយគាត់មកបញ្ជាឲ្យខ្ញុំស្រាវជ្រាវឯកសារហ្នឹង រាយការណ៍សុំការចាប់ចង-- ចាប់ខ្លួន។ ដូច្នេះ នេះបញ្ជាក់ជាភស្តុតាងមួយទៀត បញ្ជាក់ថាការជម្លៀសប្រជាជនមិនមែនតែទៅតាមផ្លូវលេខ៤ ទៅតាមផ្លូវលេខ៥ វាមានទៅតាមផ្លូវលេខ៦។ មនុស្សអស់នេះ ស្នាក់នៅស្គន់ ផ្សារស្គន់ ស្រុកជើងព្រៃ។ នេះ ខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង មុននឹងចូលទៅទៀត។ បង ០៣ នេះ ឈ្មោះសម្ងាត់របស់ ណាត។ ០៣ នេះ ជាលេខចុងកន្ទុយនៃពាក្យ ៧០៣។ ដូច្នេះ ណាត នេះ ឈ្មោះ ០៣ ផង ឈ្មោះ សែម ផង ឈ្មោះ ណាត ផង។ ដើមពិតប្រាកដរបស់គាត់ គឺ អ៊ិន លន។ ឯចំណែក នៅក្នុងទំព័រដែលយើងនាំគ្នាហៅថា ទំព័រទី១នេះ គឺទំព័រលេខ៤៥៨ នេះ។ ខ្ញុំដាក់ថា ឌុច គឺខ្ញុំជាអ្នកធ្វើឯកសារនេះ តាមបញ្ជា ណាត។

[១៤:១១:៤៤]

**ស៖** សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

**លោក ម៉ៃខល កាណាវាស៖**

សូមគោរពលោក លោកស្រីចៅក្រម។ អស់លោក លោកស្រី នៅក្នុងបន្ទប់សវនាការ និងជុំវិញបន្ទាប់សវនាការ។ ខ្ញុំសូមអរគុណ ប្រសិនបើអង្គជំនុំជម្រះអាចបង្គាប់ឲ្យសាក្សីឆ្លើយតែសំណួរតែប៉ុណ្ណោះបានហើយ។ យើងដឹងហើយថា យើងដឹងជំនាញរបស់លោក ស្មីត និងសហព្រះរាជអាជ្ញាអាចមានលទ្ធភាព ទេពកោសល្យក្នុងការសួរសំណួរហើយ។ ហើយប្រសិនជាអាចសួរអំពីសំណួរនោះ គឺអាចសួរបាន។ ដូច្នេះ ហើយយើងខ្ញុំជំទាស់ ប្រសិនបើគាត់សុំឲ្យសាក្សីបញ្ជាក់ការសង្កេតមួយចំនួនមុននឹងឆ្លើយសំណួរ។ ប្រហែលជាចំណាប់អារម្មណ៍របស់សហព្រះរាជអាជ្ញា ក៏ប៉ុន្តែខ្ញុំសូមជំទាស់ ប្រសិនបើធ្វើបែបនេះ។ ដូច្នេះហើយ ខ្ញុំសូមឲ្យសាក្សីឆ្លើយសំណួរជាក់លាក់របស់សហព្រះរាជអាជ្ញាតែប៉ុណ្ណោះ។ ហើយប្រសិនបើមានភាគីណាមួយ ចង់សួរបញ្ជាក់បន្ថែមនោះ គឺអាចធ្វើទៅបាន។ សូមអរគុណ។

[១៤:១២:៥៧]

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ ខ្ញុំយល់អំពីជំហររបស់មេធាវីការពារក្តី។ ពេលខ្លះទៅវាមានករណីដូច្នេះកើតឡើង។ សាក្សីនោះ គឺត្រូវបានសួរសំណួរដោយសារតែ ហើយគាត់ឆ្លើយនោះ ដោយសារគាត់សន្មតថា ភាគីទាំងឡាយគាត់យល់ ហើយសំណួរដែលយើងខ្ញុំសួរនេះ គឺដើម្បីបញ្ជាក់បំភ្លឺបន្ថែមបន្តតែប៉ុណ្ណោះអំពីឯកសារនេះ។ ដូច្នេះ ហើយពេលខ្លះវាពិបាកក្នុងការឲ្យសាក្សីភ្ជាប់ចម្លើយនោះ ទៅនឹងឯកសារនោះ ក៏ប៉ុន្តែធ្វើយ៉ាងណាក៏ដោយ ខ្ញុំព្យាយាមឲ្យសាក្សីនោះ គាត់ផ្តោតទៅលើភស្តុតាង និងចម្លើយ សំណួរដែលខ្ញុំសួរ ដើម្បីឲ្យភស្តុតាងយើងមានលក្ខណៈជាក់ច្បាស់។

**សួរដោយលោក វីល្លៀម ស្មីត៖**

**ស៖** លោក កាំង ហ្កេកអ៊ាវ លោកមានឯកសារនៅចំពោះមុខលោកហើយ ក៏ប៉ុន្តែមនុស្សជាច្រើនមិនមានឯកសារបែបនេះ នៅចំពោះមុខនោះទេ។ ហើយខ្ញុំសូមសង្ខេបដោយខ្លីៗ ឯកសារនេះ ចុះហត្ថលេខាដោយលោក ហើយបានបញ្ជូនទៅ “បង០៣ ជាទីគោរព” ដែលលោកនិយាយថាជា ណាត។

ហើយនៅក្នុងឯកសារនេះ ពាក់ព័ន្ធទៅនឹងការសួរចម្លើយបុគ្គលចំនួនពីរនាក់។ ឯកសារ មូលហេតុដែលខ្ញុំដាក់ឯកសារចំពោះមុខលោកនោះ គឺដោយសារតែពីមុន លោកបានឆ្លើយអំពីកាតព្វកិច្ចរបស់សមាជិកបក្សក្នុងការធ្វើការងារយ៉ាងណាធានាឲ្យបុគ្គលថ្នាក់ក្រោមបង្គាប់របស់ពួកគេនោះ មានភាពស្អាតស្អំនៅក្នុងបក្ស។

[១៤:១៤:៣៨]

ដូច្នេះ នៅពេលដែលយើងមើលឯកសារនេះ ពាក់ព័ន្ធទៅនឹងបុគ្គលពីរ គឺ គាម ទត និង ង៉ូវ វ៉ា។ ឯកសារនេះ គឺពាក់ព័ន្ធទៅនឹងការស៊ើបអង្កេតទៅលើបុគ្គលពីររូបនេះ។ ដូច្នេះ ខ្ញុំសួរថាហេតុអ្វីបានជាមានការស៊ើបអង្កេតទៅលើបុគ្គលទាំងពីរនេះ?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** បុគ្គលទាំងពីរនេះ អត់ទាន់ចាប់ទេ ណាត ចង់ចាប់ ពីព្រោះអី? ពីព្រោះទាំងបួននាក់នេះប្រែប្រវត្តិរូបដាក់ថា កម្មករ ណាត ទៅឃើញនៅភូមិផ្តៅជុំ ក្បែរផ្សារស្តន់ ស្រុកជើងព្រៃ ហើយចង់ចាប់ហើយបានៗប្រមូលឯកសារឲ្យខ្ញុំធ្វើសំបុត្រនេះមួយ ដើម្បីគាត់បានជាគោលការណ៍យកទៅចាប់ដោយសំអាងលើយើងបានស្រាវជ្រាវឯកសាររបស់ ហ្ស៊ី.កា.ស៊ី ទៅឃើញហើយខ្លួនគាត់ គាត់ឃើញបួននាក់នេះនៅភូមិផ្តៅជុំ។ ដូច្នេះហើយ បានៗ ណាត កែៗនៅទំព័រ ដែលយើងហៅថា នៅទំព័រ៥តាមពិតវាទំព័រ៤៦២ គាត់កែ។ ដល់ចុងបញ្ចប់គាត់សម្រេចយករូបមន្តមួយ គឺទំព័រ៤៦១ នេះអក្សរគាត់ក្រវិចក្រវក់ខាងក្រោមនេះ។ ទាំងពីរនាក់នេះ យើងរើឯកសារយុវជនប្រឆាំងកុម្មុយនីស្តទៅឃើញឈ្មោះវាជាក់ស្តែង ហើយហត្ថលេខា សែម ថ្ងៃ៣១ ខែ១១ តាមពិតវាគ្មាន១១ ទេ។ រឿងរ៉ាវទាំងអស់នេះខ្ញុំរាយការណ៍នៅការិយាល័យសហចៅក្រមស៊ើបអង្កេតច្បាស់លាស់ម្តងរួចទៅហើយ។

ដូច្នេះទាំងពីរនាក់នេះ ទាំងបួននាក់នេះ អត់ទាន់ចាប់ទេ។ ណាត ស្នើសុំចាប់ រួចឯកសារនេះដូចអត់ចេញរួចពីស-២១ ផង មិនដឹងជា ណាត ដោះស្រាយយ៉ាងម៉េចទៀតទេ។

[១៤:១៨:១២]

**ស៖** សូមអរគុណ។ ដើម្បីឲ្យច្បាស់នោះគឺថា គោលបំណងដែលខ្ញុំសួរសំណួរនេះ ដើម្បីឲ្យយើងយល់ឲ្យបានច្បាស់ អំពីការអនុវត្តនៃការស៊ើបអង្កេតទៅលើបុគ្គល ឬក៏ការស៊ើបអង្កេតទៅលើសមាជិកបក្ស ហើយគេកត់ត្រាព័ត៌មានក្រោយពីស៊ើបអង្កេតនោះយ៉ាងណា។ ដូច្នេះ ឆ្លងតាមចំណុចនេះថាតើ ណាត ទទួលប្រវត្តិរូបបុគ្គលពីររូបនេះតាមរបៀបណា? ប្រសិនបើបុគ្គលទាំងពីរនេះ មិនត្រូវបាន

គេឃុំនៅស-២១ ផងនោះ។ ដូច្នេះថាតើ ណាត នោះទទួលប្រវត្តិរូបជនទាំងពីរនេះតាមរបៀបណា ដើម្បីយកមកឲ្យលោកនោះធ្វើការស៊ើបអង្កេតទៅលើជនទាំងពីរនេះ?

**ឆ៖** ទីមួយ ខ្ញុំសូមបញ្ជាក់ជូនព្រះរាជអាជ្ញាបន្តិច ពីរឿងប្រើពាក្យសមាជិកបក្សចំពោះបុគ្គលបួនរូបនេះ មិនមែនទេ។ ពួកនេះជាមន្ត្រីរាជការ។ សូមបញ្ជាក់ថា គាម ទត ធ្លាប់ធ្វើជានាយកវិទ្យាល័យកំពង់ធំ។ ណាត ធ្លាប់ធ្វើជាប្រធានរោងចក្រអគ្គិសនីនៅកំពង់ធំ។ គាម ទត មានចរិតមួយគេហៅថា ចរិតប្រតិកិរិយាប្រឆាំងជនចម្រើននោះ នៅកំពង់ធំ ណាត សម្គាល់ទុក។ ដូច្នេះ ណាត ស្គាល់ គាម ទត ច្បាស់។ ទន្ទឹមគ្នាជាមួយ គាម ទត នោះ វាមាន តាប់ ប៊ុនឌីន មួយទៀត នៅជាមួយគ្នា ជាមួយនឹង ណាត អំ ជាមួយនឹង គាម ទត។ ដូច្នេះ ណាត ស្គាល់ គាម ទត នាំឲ្យ ណាត ក្តាប់បានរឿងរ៉ាវ តាប់ ប៊ុនឌីន មួយចំនួន។

[១៤:១៩:១៨]

ទីពីរ ង៉ូវ វ៉ា ហើយនិង ស កាពុន។ ឈ្មោះមនុស្សពីរនាក់នេះ មាននៅក្នុងឯកសារ របស់យុវជនប្រឆាំងកុម្មុយនីស្តឥណ្ឌូចិន ដែលហៅកាត់ថា ហ្ស៊ី.កា.ស៊ី។ *ហ្ស៊ីណេសខ្មែរ កុងត្រឺសកុម្មុយនីស្តអាំងដូស៊ីន័រ*។ គេរើទៅឃើញពួកខាងក្រុងគេរាយការណ៍ទៀត ម្លោះហើយ ណាត យកឯកសារទាំងអស់នេះ។ សូមបញ្ជាក់ថា ណាត គ្រប់គ្រងពួកក្រុងដែរ ពួកកម្លាំងក្រុងរបស់បក្សកុម្មុយនីស្តកម្ពុជា។ ដូច្នេះបានព័ត៌មានទាំងអស់នេះ ហើយ ណាត ទៅឃើញជាក់ស្តែងបួននាក់នេះ នៅភូមិផ្តៅជុំ នេះរឿងរ៉ាវបែបនេះ។ ដូច្នេះ ណាត ចង់ចាប់តាមគោលនយោបាយរបស់បក្សជំនាន់នុំង ក្រោយ១៧ មេសា ភ្លាមនុំង។ នេះរឿងរ៉ាវដែលសុំសរុបជូនទាំងអស់។ ហើយសូមបញ្ជាក់មួយម៉ាត់ទៀតថា ទាំងបួននាក់នេះមិនមែនជាសមាជិកបក្សកុម្មុយនីស្តកម្ពុជាទេ ជាមន្ត្រីរាជការរបស់ លន់ នល់។

**ស៖** សូមអរគុណ។ សំណួរ ដូច្នេះហើយយើងអាចយល់យ៉ាងច្បាស់ថា នេះគឺបង្ហាញអំពីឧទាហរណ៍ដែលសមាជិកបក្សគឺ ណាត គាត់អនុវត្តការទទួលខុសត្រូវរបស់គាត់នៅក្នុងបក្សក្នុងការស៊ើបអង្កេត សួរចម្លើយតាមដានបុគ្គលណាមួយដែលគាត់ចាត់ទុក ជឿថាប្រឆាំងនឹងមាគ៌ាបក្ស ឬក៏ប្រឆាំងនឹងបដិវត្តន៍។ ដូច្នេះហើយឯកសារនេះបង្ហាញជាឧទាហរណ៍បែបហ្នឹង មែនទេ?

[១៤:២១:១១]

**ឆ៖** ត្រូវហើយ ក្រោយ១៧ មេសា បន្តិច ណាត មានភារកិច្ចហ្នឹងមួយ ដើរប្រមូលមនុស្សពីគ្រប់ភូមិភាគ ទៅខ្លួនឯង ចាត់តាំង យូ ប៉េងគ្រី ហៅ ម៉ុន ឲ្យទៅ។

**ស៖** ខ្ញុំមានសំណួរខ្លីៗប្រហែលជាបួនទៅប្រាំ ដើម្បីសួរលោកអំពីជីវប្រវត្តិរូប និងការស៊ើបអង្កេតដែលលោកបានធ្វើឡើង។ សំណួរទីមួយ គឺលោកបាននិយាយនៅខាងលើថា គាម ទត និង ង៉ូវ វ៉ា បានថ្លែងប្រវត្តិរូបដាក់ថាជាកម្មករ។ នេះគឺជាសន្និដ្ឋានដែលលោកបានធ្វើឡើងក្រោយពេលដែលលោកស៊ើបអង្កេតទៅប្រវត្តិរូបរបស់អ្នកទាំងពីរហ្នឹង។ តើពិតជាត្រឹមត្រូវដែរឬទេ?

**ឆ៖** ពាក្យក្លែងៗប្រវត្តិរូបធ្វើជាកម្មករនេះ ជាសម្ដី ណាត បញ្ជាឲ្យខ្ញុំសរសេរ។ គាត់ចុះទៅដល់មូលដ្ឋាន គាត់ឃើញ គាម ទត គាត់ឃើញ ង៉ូវ វ៉ា គាត់ឃើញ តាប់ ប៊ុនឌីន គាត់ឃើញ ស កាពុន។

**ស៖** ពាក់ព័ន្ធទៅនឹង គាម ទត ឪពុកបង្កើតជាកសិករកណ្ដាលលើ ឪពុកក្មេកឈ្មោះ-- ឪពុកក្មេកនោះគឺជាសក្តិភូមិម្ចាស់ដី តើចំណុចពីរហ្នឹង អង្គហេតុពីរហ្នឹងត្រឹមត្រូវដែរឬទេ?

**ឆ៖** ត្រឹមត្រូវ។

[១៤:២៣:១៥]

**ស៖** ដូច្នេះ ថាតើចំណុចដែលអង្គហេតុពីរដែលត្រឹមត្រូវហ្នឹង ណាត យល់ យ៉ាងម៉េចដែរ? ហើយថាតើ ណាត នោះចាត់ទុកយ៉ាងម៉េច ថាវាជាលក្ខណៈសម្បត្តិមួយល្អ ឬក៏លក្ខណៈសម្បត្តិមួយមិនល្អ?

**ឆ៖** ខ្ញុំមិនដឹងជាគាត់ចាត់ទុកយ៉ាងម៉េចទេ ក៏ប៉ុន្តែគ្រាន់តែដឹងជាក់ច្បាស់ថា គាត់បញ្ជាឲ្យខ្ញុំសរសេរឯកសារនេះឡើងម្ដងជាពីរដង កែចុះកែឡើងដើម្បីទាមទារចាប់ប៉ុន្មាននាក់នេះ។

**ស៖** នៅក្នុងនេះលោកក៏បានកត់ត្រាផងដែរ លោកបានសរសេរចំណុចដែលថាបុគ្គលទាំងពីរនេះ គឺបានប្រឆាំង គាត់បានស្នើសុំរដ្ឋាភិបាលសីហនុ កម្ទេចបញ្ញាជន បញ្ជាចម្រើនជនទាំងបីនាក់ តើចំណុចនេះត្រឹមត្រូវដែរឬទេ? ហើយគាត់ក៏បាន-- លោកក៏បានសរសេរក្នុងនេះថា ពេលចេញទៅធ្វើការនៅកំពង់ធំប្រឆាំងនឹងចលនាបដិវត្តជាប់រហូត។ តើចំណុចហ្នឹងត្រឹមត្រូវដែរឬទេ?

[១៤:២៤:៤១]

**ឆ៖** ប្រវត្តិរូប គាម ទត អត់ស្គាល់ទេ គេដឹង។ ពួកនេះសុទ្ធសាស្ត្រាចារ្យជំនាន់គាត់ដឹង។ គាម ទង ធ្វើញត្តិមួយសម្លាត់ស្នើសុំចាប់ ខៀវ សំផន។ នេះ ខៀវ សំផន នេះ។

**ស៖** ពាក់ព័ន្ធទៅនឹង ង៉ូវ វ៉ា គឺបងប្អូនខាងក្រុមឲ្យព័ត៌មានថា គាត់ធ្លាប់ចេញចូលផ្ទះ លន់ នល់, ប្ញូរ៉េត, ប៉ាន់ សុធី។ តើចំណុចហ្នឹងត្រឹមត្រូវដែរឬទេ? បុគ្គលទាំងបីនេះ គឺជានរណាដែរ? តើអង្គហេតុនេះ គឺជាអង្គហេតុមួយដែលមិនត្រឹមត្រូវ ដើម្បីជាការដាក់បន្ទុកទៅលើ ង៉ូវ វ៉ា ឬក៏យ៉ាងម៉េច?

[១៤:២៦:០៣]

**ឆ៖** អរគុណ។ មុននឹងឆ្លើយ ខ្ញុំសូមកែពាក្យមួយម៉ាត់ បងប្អូនខាងក្រុម។ ខ្ញុំបានកែជូនសហចៅក្រមស៊ើបអង្កេតហើយ មិនមែនមែន “ខាងក្រុម” ទេ “ខាងក្រុង” វ៉ៃម៉ាស៊ីននេះខុស ខុសមួយម៉ាត់ហ្នឹង “ង” មិនមែន “ម”ទេ។ បងប្អូនខាងក្រុង។ គឺខ្សែសម្ងាត់របស់បក្សកុម្មុយនីស្តកុម្មុយនីស្តកម្ពុជានៅខាងក្រុងភ្នំពេញ។ គេឲ្យព័ត៌មានមកគាត់ មក សុន សេន ថាធ្លាប់ចេញចូល ថាបី-- ថា ង៉ូវ វ៉ា ធ្លាប់ចេញចូលផ្ទះលន់ នល់, ឡុង បូរ៉េត, ប៉ាន់ សុធី ញឹកញាប់។ លន់ នល់ ព្រះរាជអាជ្ញាស្គាល់ហើយ ខ្ញុំមិនបាច់បញ្ជាក់ទេ មេធំខាងសាធារណរដ្ឋ។ បូរ៉េត នេះ គឺ ឡុង បូរ៉េត នាយករដ្ឋមន្ត្រីចុងក្រោយរបស់ លន់ នល់។ ឯចំណែក ប៉ាន់ សុធី ជាមនុស្សដែលចេះម្នាក់ មិនដឹងជាតួស្អីសំខាន់ ខ្ញុំធ្លាប់ទៅ ក៏ប៉ុន្តែគាត់ទៅសហប្រជាជាតិម្តង ត្រូវបានគេកត់សម្គាល់ថា ជាអ្នកពូកែខាងវោហារ។ ដូច្នេះ គាត់មានសញ្ញាបត្រខ្ពស់ណាស់ ហើយមានតម្រិះវិជ្ជាឆ្លាតណាស់ ប៉ាន់ សុធី។ រួចតួនាទីរបស់គ្នានៅក្នុងរដ្ឋបាល លន់ នល់ ខ្ញុំក្លាប់មិនបាន។ ដូច្នេះ នេះជាព័ត៌មានដែលខាងកម្លាំងសម្ងាត់របស់បក្សកុម្មុយនីស្តកម្ពុជារាយការណ៍ជូន សុន សេន ជូន ណាត។ ជាពិសេស គឺជូន សុន សេន។

[១៤:២៧:៥៣]

**ស៖** សូមអរគុណ។ របាយការណ៍នេះ បានបញ្ជូនទៅ ណាត ហើយនៅចំណុចចុងក្រោយនោះ លោកបាននិយាយថា ចាប់ ឬក៏មិនចាប់ អាស្រ័យទៅលើកាលវិភាគរបស់អ្នកឯង។ តើត្រឹមត្រូវដែរឬទេ ដែលលោកសរសេរបែបនោះ?

**ឆ៖** គាត់សរសេរមក ដើម្បីឲ្យខ្ញុំសរសេរតាម ហើយដល់ទៅ ខ្ញុំដែលថានៅចំណុចទីបីរបស់ខ្ញុំ ចាប់ ឬមិនចាប់ស្រេចលើបងទេ។ ខ្ញុំអត់ហៅ អ្នកឯងទេ ហៅបង។ ដូច្នេះ ចាប់ ឬមិនចាប់ លើបងឯងទេទទួលខុសត្រូវចំពោះបក្សទេ ចាប់ ឬមិនចាប់។ បើបងឯងសរសេឲ្យខ្ញុំសរសេរអ៊ីចឹងហើយ ខ្ញុំជាអនុបងឯង ខ្ញុំសរសេរ។

**ស៖** លោកបាននិយាយថា លោកមិនដឹងថាអ្នកទាំងពីរនេះត្រូវបានគេចាប់ ឬក៏មិនត្រូវបានគេចាប់ទេ។ តើត្រឹមត្រូវដែរឬទេ លោកបាននិយាយដូច្នេះ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ថា គ្មានឈ្មោះ ហើយក៏មិនដែលឃើញមុខអ្នកទាំងពីរហ្នឹង ទាំងប្អូនហ្នឹងចូលទៅដល់ ស-២១ ទេ ក្នុងបញ្ជីកម្មេចរបស់ ស-២១ ក៏គ្មានឈ្មោះអ្នកប្អូននាក់។ ឯខ្ញុំនៅធ្វើអនុប្រធានហែម។ ចេញពី ហែម ក្រោយមកក៏ជាប្រធាន ក៏អត់ឃើញឈ្មោះប្អូននាក់ហ្នឹងដែរ។ តាប់ ប៊ុនឌីន ខ្ញុំ

ស្គាល់។ គាម ទត ខ្ញុំស្គាល់ អ្នកស្រុកស្មោងជាមួយនឹងខ្ញុំ។ រួចដល់ក្រោយមកទៀត ខ្ញុំអត់ដែរឮដំណឹងថា បង គាម ទត ហើយនិង តាប់ ប៊ុនឌីន ទៅដល់ស្មោងទេ អត់មាន។

**ស៖** សំណួរចុងក្រោយនៅក្នុងកថាខណ្ឌពាក់ព័ន្ធទៅនឹង គាម ទត បានលើកឡើងថា "សរសេរញត្តិសូមឱ្យរដ្ឋាភិបាលសីហនុ កម្ទេចបញ្ញាជនចម្រើនទាំងបីនាក់។ តើបញ្ញាជនចម្រើនទាំងបីនាក់ហ្នឹង លោកសំដៅទៅលើអ្នកណាដែរ?

**ឆ៖** ខ្ញុំចូលទៅវិទ្យាស្ថានជាតិគរុកោសល្យក្រោយ គាម ទត ប្រហែលជាបីឆ្នាំ។ ដំណឹងហ្នឹង អត់ស្ងាត់ទេណ៎ា! រឿង គាម ទត ធ្វើញត្តិមួយសម្លាត់ទាមទារសូមឱ្យគេចាប់ ខៀវ សំផន។ ប៉ុន្តែមិនដឹងយ៉ាងម៉េចបានជា ណាត បញ្ជាខ្ញុំឱ្យចាប់ទាំងបីនាក់ គឺមួយ ខៀវ សំផន នេះមានមុខនៅទីនេះ។ ទីពីរ គឺ ហ៊ូ យន់ ទីបី គឺ ហ៊ូ នឹម។

[១៤:៣១:១១]

**ស៖** សូមអរគុណ។ ឥឡូវនេះយើងចេញពីឯកសារនេះ ហើយយើងចូលទៅដល់ប្រធានបទមួយផ្សេងទៀត ទាក់ទងទៅអ្វីដែលយើងបានពិភាក្សាអម្បាញ់មិញនេះ ហើយបញ្ហានោះទាក់ទងទៅនឹងគំនិតនៃការរាយការណ៍ គឺបែបបទនៃការរាយការណ៍នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា។ ហើយយើងមើលមាត្រា៦ នៃលក្ខន្តិកៈបក្សដែលមានចំណងជើងថា "ការ-- គោលការណ៍ចាត់តាំងរបស់បក្ស" ហើយនិងយើងមើលមាត្រា៦(៥) ដែលនិយាយអំពី៖ តាមការកំណត់នីមួយៗថ្នាក់ក្រោមត្រូវរាយការណ៍ជូនថ្នាក់លើអំពីសភាពការណ៍ និងអំពីការងារដែលត្រូវបានធ្វើ។ នៅពេលដែលយើងពិនិត្យមើលអំពីវិធីនៃការទំនាក់ទំនងដែលគេអនុវត្តនោះ នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ តើត្រូវទេបើយើងនិយាយថានោះហើយជាវិធី ថាជាកាតព្វកិច្ចដែលថ្នាក់ក្រោមត្រូវតែរាយការណ៍ទៅថ្នាក់លើអំពីសភាពការណ៍ ហើយនិងការងារដែលបានធ្វើនៅតាមមូលដ្ឋាននោះ។

[១៤:៣២:៣៧]

**ឆ៖** សូមព្រះរាជអាជ្ញាបញ្ជាក់ជំពូក មាត្រា ហើយនិងទំព័រ។

**ស៖** ប្រហែលជានៅក្នុងភាសាខ្មែរមាត្រា៦ កថាខណ្ឌទី៥ នៅក្នុងជំពូកទី៣ អត្ថបទភាសាខ្មែរ ទំព័រ៣០-៣១។ ហើយ--

**លោក វីល្លៀម ស្មីត៖**

សូមជម្រាបលោកប្រធានថា ឥឡូវនេះនៅសល់តែប្រាំ *មីនុត*ទេ យើងនឹងដល់ពេលសម្រាក

ហើយ។ ប៉ុន្តែខ្ញុំមានសេចក្ដីសង្ខេប ហើយរហូតមកដល់ពេលនេះ ដល់ថ្ងៃនេះសហព្រះរាជអាជ្ញាបាន លើកនូវសំណើមួយដែលថា គឺរយៈពេលដែលមាននៅសល់ដែលថា ប្រាំពីរម៉ោងកន្លះនោះ។ ហើយ យើងមានពេលដែលសហព្រះរាជអាជ្ញាត្រូវបានចែកជូននោះ គឺថាប្រាំពីរម៉ោងកន្លះរហូតមកដល់ព្រឹក មិញនេះ។ នៅថ្ងៃនេះ សូមជម្រាបតុលាការថា សហព្រះរាជអាជ្ញានឹងត្រូវការប្រាំម៉ោងបន្ថែមទៀត។ ដូច្នេះ នឹងអាចដប់ពីរម៉ោងកន្លះ។

[១៤:៣៣:៥៧]

លោក លោកស្រីចៅក្រម យើងខ្ញុំស្នើសុំពេលម៉ោងបន្ថែមនោះ គឺថាយើងមានពេល ១៥ថ្ងៃ ដោយសារសាក្សីរូបនេះមានព័ត៌មានសំខាន់ៗច្រើនណាស់។ ឥឡូវនេះ យើងចូលដល់ការពិភាក្សាអំពី មធ្យោបាយទំនាក់ទំនងអំពីវិធី ថាតើបក្សកុម្មុយនីស្តកម្ពុជាទំនាក់ទំនងគ្នាយ៉ាងដូចម្ដេច ទាក់ទងទៅនឹងពី កន្លែងមួយទៅកន្លែងមួយនៅក្នុង ស-២១ នៅក្រៅស-២១ ដើម្បីឲ្យតុលាការបានជ្រាបច្បាស់អំពី មធ្យោបាយប្រាស្រ័យទាក់ទងក្នុងកាលនោះ។ ហើយយើងមានផែនការនឹងចូលទៅដល់ចំណុចពិសេស និយាយអំពីស្ថាប័នរបស់បក្សកុម្មុយនីស្តកម្ពុជា ហើយសាក្សីរូបនេះក៏បានដឹងអំពីស្ថាប័នកំពូលក្រសួង នានារបស់បក្សកុម្មុយនីស្តកម្ពុជា។ បន្ទាប់ទៅទៀត យើងនឹងពិភាក្សាអំពីតួនាទីរបស់ជនជាប់ចោទ ជា ពិសេសដែលយើងចង់ដឹងក្រៅពីអង្គហេតុដែលយើងនិយាយថ្ងៃនេះ។

[១៤:៣៤:៥៦]

យើងខ្ញុំយល់ថា ហើយយើងនឹងប្រើពេលវេលាប្រាំថ្ងៃទាំងស្រុង ដើម្បីឲ្យពិភាក្សាបញ្ហានេះលម្អិត ហើយយើងទទួលការណែនាំពីតុលាការថា ឲ្យធ្វើបែបនោះ ហើយមិនមានការជំទាស់ពីមេធាវីការពារក្ដី ទេ។ ដូច្នេះ យើងសុំឲ្យតុលាការផ្ដល់ពេលឲ្យយើងខ្ញុំសួររហូតថ្ងៃស្អែក មុនបាយថ្ងៃត្រង់ដោយមិន សម្រាក។ ដូច្នេះកុំឲ្យខាតពេលរបស់យើងខ្ញុំ។ ពេលនោះសហព្រះរាជអាជ្ញាអាចនឹងបញ្ចប់នៅថ្ងៃ ព្រហស្បតិ៍ នៅពេលបាយថ្ងៃត្រង់។ ហើយពេលវេលា ហើយនិងទំហំនៃសំណួរហ្នឹង គឺវាទាក់ទងទៅនឹង បញ្ហាជាច្រើននូវគ្រប់ប្រធានបទនៅក្នុងដីកាបញ្ជូនរឿងមកជម្រះនេះ។ ហើយនិងធ្វើការដោយមាន ប្រសិទ្ធភាព ហើយខ្ញុំសូមអនុញ្ញាតតុលាការផ្ដល់ឲ្យយើងខ្ញុំ ឬក៏ការបង្ហាញបន្ទាប់ពីការសម្រាកនេះ ថា តើអាចនឹងតុលាការអនុញ្ញាតឲ្យយើងខ្ញុំដែរឬអត់? ជាពិសេស គឺរហូតដល់ថ្ងៃព្រហស្បតិ៍ មុនថ្ងៃសម្រាក អំ មុនពេលសម្រាកអាហារថ្ងៃត្រង់។

នេះហើយ គឺជាពេលវេលាដែលរាប់បញ្ចូលទាំងការឈប់សម្រាក។ អ៊ីចឹងសូមដកពេលឈប់

សម្រាកនោះទៅទៀត។ ដូច្នេះដើមបណ្តឹងរដ្ឋប្បវេណី ក៏មានសំណើដ៏ខ្លីបន្ទាប់ពីខ្ញុំស្នើនេះដែរ ក៏អាចនឹងជាសារប្រយោជន៍ ដើម្បីឲ្យលោក លោកស្រីចៅក្រមពិនិត្យ ពិចារណានូវសំណើរបស់យើងខ្ញុំនេះ។ បន្ទាប់ពីការសម្រាកនៅពេលនេះ ប្រហែលជាខ្ញុំប្រគល់វេទិកាទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីគាត់អាចនឹងលើកឡើងនូវសំណើ បាទ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម!

[១៤:៣៦:៥០]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ ចំពោះលោក ស្នឹត សូមឲ្យលោកបំភ្លឺ លោកបានបញ្ជាក់ថា ប្រធានបទមួយចំនួនដែលលោកបន្តធ្វើការសំណួរ-- តាំងសំណួរនៅក្នុងសប្តាហ៍នេះ។ ហើយលោកក៏មានផែនការនឹងគ្របដណ្តប់លើប្រធានទាំងអស់នៅក្នុងដីកាបញ្ជូនរឿងមកជម្រះ។ ខ្ញុំគិតថា លោកនិយាយថា នៅក្នុងភាគនៃសវនាការនេះទេ ហើយនិងប្រធានបទដែលស្ថិតនៅក្នុងការពិនិត្យនៅពេលនេះតែប៉ុណ្ណោះ។ តើអ៊ីចឹងឬទេ?

ជាពិសេស នៅក្នុងចំណុចដែលលោកបានបញ្ជាក់នោះ គឺវិធីសាស្ត្រទំនាក់ទំនងរបស់បក្សកុម្មុយនីស្តកម្ពុជា ទាក់ទងទៅតួនាទីរបស់ជនជាប់ចោទ។

[១៤:៣៧:៣៤]

**លោក វីណ្ស្យៀម ស្នឹត៖**

ពិតហើយលោកស្រីចៅក្រម គឺខ្ញុំចង់និយាយបែបនោះឯង។ ខ្ញុំបានបញ្ជាក់ខុសបន្តិច។ អ៊ីចឹងសូមអភ័យទោស។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

**កញ្ញា លី ម៉ាញឿន៖**

សូមអរគុណលោកប្រធាន។ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ចង់សុំឲ្យមានការសំណើមួយ ហើយយើងបានចង្អុលបង្ហាញថា ទៅមន្ត្រីជាន់ខ្ពស់ច្បាប់ហើយ។ ហើយយើងបានស្នើសុំឲ្យបានពេល ដើម្បីឲ្យយើងតាំងសំណួរទៅលោក កាំង ហ្កេកអ៊ាវ ចំនួនបីម៉ោង។ ហើយឥឡូវនេះ យើងសូម

ជម្រាបថា យើងនឹងស្នើពេលច្រើនជាងបីម៉ោងនេះ ពីព្រោះថា សាក្សីរូបនេះ គាត់ដឹងច្បាស់ គឺមានៗនិន្នាការនឹងបង្ហាញសេចក្ដីលម្អិតទូលំទូលាយ ដែលត្រូវពិចារណា។ ជាពិសេសនៅពេលដែលយើងៗពិនិត្យមើលពេលដែលបានចែកឲ្យភាគីនោះទេ។

[១៤:៣៨:៣៨]

នេះ គឺជាបញ្ហាមួយដែលមិនពាក់ព័ន្ធទេ បើពេលខ្លីបែបនេះ បើសិនសាក្សីមានចំណេះដឹងផ្ទៃក្នុងដ៏ច្រើន ដូចដែលលោក កាំង ហ្គេកអ៊ាវ មាននេះ ហើយគាត់គឺជាមនុស្សដែលសកម្មបំផុតនៅក្នុងការងារនោះ។ ហើយមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីនឹងប្រើពេលវេលា ហើយនិងចង់ប្រើគុណភាពនៃសាក្សីនេះ ដើម្បីចុចទៅលើបរិបទមួយចំនួន ប្រធានបទមួយចំនួន ហើយនិងយើងបញ្ជាក់ឡើងវិញជូនតុលាការផងដែរ តាមវិធាន២៣(១)នៃវិធានផ្ទៃក្នុង ដើមបណ្ដឹងរដ្ឋប្បវេណីហ្នឹង គឺមានគោលបំណងពីរក្នុងការចូលរួម។ ទីមួយ យើងមានអាណត្តិក្នុងការចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ទាក់ទងទៅនឹងបទឧក្រិដ្ឋក្នុងយុត្តាធិការ អ.វ.ត.ក គាំទ្រដល់សហព្រះរាជអាជ្ញា។ ហើយទីពីរ ដើម្បីស្វែងរកនូវសំណងផ្លូវចិត្ត និងសំណងសមូហភាពនោះផងដែរ។ ទីបី គឺថាដើមបណ្ដឹងរដ្ឋប្បវេណីមានការព្រួយបារម្ភ ហើយអាចនឹងលើបញ្ហាមួយចំនួនដែលទាក់ទងទៅនឹងសួរសំណួរទៅសាក្សី ទាក់ទងទៅនឹងរចនាសម្ព័ន្ធរដ្ឋបាល ដែលឥឡូវនេះយើងខ្ញុំយល់ថា នឹងត្រូវការឲ្យមានការសួរនូវការទទួលខុសត្រូវដ៏ទូលំទូលាយ ដើម្បីជូនដល់តុលាការបានជ្រាប។

[១៤:៣៩:៥៣]

អ៊ីចឹងហើយ យើងស្នើសុំតុលាការផ្ដល់ពេលឲ្យយើងបន្ថែម យើងនឹងផ្ដែកទៅលើសំណួរសំខាន់ៗគឺរចនាសម្ព័ន្ធរដ្ឋបាល និងការប្រាស្រ័យទាក់ទង ដែលថាចំណុចទីមួយ គឺការទទួលខុសត្រូវរបស់ អៀង សារី ទាក់ទងទៅនឹងជនរងគ្រោះនៅស-២១ ដែលគាត់បានកោះហៅពួកគេមកកម្ពុជាវិញ ហើយនិងៗជនរងគ្រោះមួយចំនួនបានយកមកពីក្រសួងការបរទេស។ ហើយទីពីរ ការចាប់ជនបរទេសនៅសមុទ្រកម្ពុជា ហើយនិងការបញ្ជូនពីទីនោះមកស-២១។ ហើយជាពិសេសអាចនឹងបំភ្លឺដល់តុលាការមួយចំនួនអំពីតួនាទីរបស់ នួន ជា នៅក្នុងខ្សែសង្វាក់បញ្ជានេះ។ ទីបី អំពីគោលនយោបាយ និងខ្សែបញ្ជា ការប្រើនូវចម្លើយសារភាពដោយពួកជនជាតិវៀតណាម ជាបុគ្គលដែលជាសញ្ជាតិវៀតណាមនៅស-២១ នោះដោយរាប់បញ្ចូលទាំង-- គឺថាទាក់ទងនឹងទិសដៅ និងគោលនយោបាយ និងបញ្ជាហ្នឹង។ ចំណុចមួយទៀត គឺការបញ្ជូនលិខិតពីប្រធានកងពល ពីកន្លែងផ្សេងៗមកស-២១។ ពេលវេលាទាក់ទងហ្នឹង គឺជា

បញ្ហាដែលតុលាការត្រូវពិនិត្យ ដើម្បីពិចារណា ដើម្បីការគ្រប់គ្រងសំណុំរឿង ហើយសុំស្នើថា សុំឲ្យពិចារណានូវសារសំខាន់នៃភស្តុតាង ដែលលោក កាំង ហ្កេកអ៊ាវ មានលទ្ធភាពនឹងបំភ្លឺដល់តុលាការ និងដល់ដើមបណ្តឹងរដ្ឋប្បវេណីនោះផងដែរ។

[១៤:៤១:៣២]

**ប្រធានអង្គជំនុំ៖**

ពេលវេលាបានបែងចែករួចហើយថា បីម៉ោង ហើយឥឡូវលោកស្រីមេថាវីសូមបន្ថែម។ សុំប៉ុន្មានទៅ?

**កញ្ញា លី ម៉ាញឿន៖**

នៅដំណាក់កាលនេះ ខ្ញុំអាចជម្រាបតុលាការបានថា លោកប្រធានថា យើងត្រូវការពេលមួយថ្ងៃ។ នេះគឺជាបញ្ហាដែលតុលាការមានឆន្ទានុសិទ្ធិក្នុងការសម្រេច គឺថាយើងចង់បានពេលមួយថ្ងៃពេញ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណនូវការលើកឡើងនូវសំណូមពរនេះ អង្គជំនុំជម្រះនឹងពិចារណាសម្រេច។

ឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយអនុរក្សឃុំឃាំងអញ្ជើញលោក កាំង ហ្កេកអ៊ាវ ទៅសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ហើយនិងអញ្ជើញគាត់មកកន្លែងផ្តល់សក្ខីកម្មនៅទីនេះឲ្យបានមុនពេលអង្គជំនុំជម្រះចូលកាន់អាសនៈ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤២ នាទី ដល់ម៉ោង ១៥:០៦ នាទី)*

[១៥:០៦:៤៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ មុននឹងផ្តល់វេទិកាទៅដល់តំណាង

សហព្រះរាជអាជ្ញាអន្តរជាតិ ដើម្បីបន្តសំណួរដេញដោលចំពោះសាក្សីរូបនេះ។ អង្គជំនុំជម្រះសូមឆ្លើយតបទៅនឹងសុំរបស់តំណាងសហព្រះរាជអាជ្ញា ក្នុងការតាំងសំណួរដេញដោលចំពោះសាក្សី កាំង ហ្កេកអ៊ាវ ហៅ ឌុច ក៏ជាសំណើសុំរបស់ក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីនូវពេលវេលាក្នុងការតាំងសំណួរ គឺអង្គជំនុំជម្រះទទួលយល់ព្រមតាមសំណើសុំ។

ជាបន្ត សូមផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តតាំងសំណួរដេញដោល។

សូមអញ្ជើញ!

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ សូមអរគុណលោក លោកស្រីចៅក្រម។

**សួរដោយលោក វីល្លៀម ស្មីត៖**

**ស៖** លោក កាំង ហ្កេកអ៊ាវ មុនពេលដែលយើងឈប់សម្រាក យើងបានចាប់ផ្តើមពិភាក្សាអំពីរចនាសម្ព័ន្ធទំនាក់ទំនង ប្រព័ន្ធទំនាក់ទំនងនៅក្នុងកម្ពុជាប្រជាធិបតេយ្យ។ ហើយខ្ញុំបានឲ្យលោកមើលមាត្រានៅក្នុងលក្ខន្តិកៈត្រង់មាត្រា៦ ចំណុច ៥។ នៅក្នុងទំព័រជាភាសាខ្មែរ គឺទំព័រ៣០ ។ តើលោកមានឃើញទេ មាត្រា៦ ចំណុច ៥?

[១៥:០៨:៤១]

លោកបានងក់ក្បាល ដូច្នេះ ខ្ញុំគិតថា លោករកចំណុចហ្នឹងឃើញហើយ។ ខ្ញុំ នៅពេលដែលយើងមើលមាត្រា៦ ចំណុច ៥ វាជាមូលដ្ឋាន នៃការពិភាក្សារបស់យើងនៅត្រង់សំណួរក្រោយៗ ដូច្នេះហើយខ្ញុំសូមឲ្យលោកជួយអានចំណុច ៥។

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** អរគុណ។ តាមកាលកំណត់នីមួយៗ ថ្នាក់ក្រោមត្រូវរាយការណ៍ជូនថ្នាក់លើអំពីសភាពការណ៍ និងអំពីកិច្ចការដែលខ្លួនបានធ្វើ។ ហ្នឹង ខ្ញុំសូមអានមួយកំណាត់នេះសិន។ សូមអានមួយកំណាត់នេះសិន។

**ស៖** ចំណុចនេះ វាជាចំណុចមួយ-- បើសិនជាអានមួយកំណាត់អ៊ីចឹង យើងអាចយល់ច្បាស់។ នៅពេលដែលយើងមើលបទប្បញ្ញត្តិនេះ មាត្រានេះ បានន័យថា ថ្នាក់ក្រោមត្រូវរាយការណ៍ជូនថ្នាក់លើអំពីសភាពការណ៍ និងអំពីកិច្ចការ។ តើពាក្យថា “ថ្នាក់លើ និងថ្នាក់ក្រោម” នេះមានន័យយ៉ាងម៉េច? លោកបានលើកឡើងហើយក្នុងចំណុចមុននោះ ក៏ប៉ុន្តែពាក្យថា “ថ្នាក់” ទទេនេះ តើមានន័យយ៉ាងម៉េច

ដែរ?

**ឆ៖** បើនិយាយអំពីថ្នាក់ទទេ ត្រូវនិយាយឲ្យពេញពាក្យថា "គណៈកម្មាធិការបក្សថ្នាក់"។ ដូច្នេះវាមានគណៈកម្មាធិការបក្សថ្នាក់សហករណ៍ គណៈកម្មាធិការបក្សថ្នាក់ស្រុក គណៈកម្មាធិការបក្សថ្នាក់តំបន់ គណៈកម្មាធិការបក្សថ្នាក់ភូមិភាគ។ ក្នុងកងទ័ព គណៈកម្មាធិការបក្សថ្នាក់អនុសេនាធំ ថ្នាក់វរសេនាតូច ថ្នាក់វរសេនាធំ ថ្នាក់កងពល ហើយនិងថ្នាក់អគ្គសេនាធិការ។ ដូច្នេះ ថ្នាក់នេះពាក្យកាត់។

**ស៖** ថាតើមានថ្នាក់ស្រុកដែរឬទេ?

**ឆ៖** មាន។ គណៈកម្មាធិការបក្សថ្នាក់ស្រុក។

[១៥:១១:៤៤]

**ស៖** នៅលើភូមិភាគ-- នៅលើគណៈកម្មាធិការភូមិភាគ ថាតើមានថ្នាក់អ្វីនៅពីលើ?

**ឆ៖** នៅលើគណៈកម្មាធិការបក្សថ្នាក់ភូមិភាគ វាមានគណៈកម្មាធិការអចិន្ត្រៃយ៍បក្ស។

**ស៖** លោកបាននិយាយនៅខាងដើមថា មានគណៈកម្មាធិការមជ្ឈិម។ ដូច្នេះ ខ្ញុំចង់សួរថាតើគណៈកម្មាធិការអចិន្ត្រៃយ៍មានទំនាក់ទំនងជាមួយនឹងគណៈកម្មាធិការមជ្ឈិមដោយរបៀបណា? ហើយយ៉ាងម៉េចដែរ?

**ឆ៖** គណៈកម្មាធិការមជ្ឈិម វាមានរួមទាំងអចិន្ត្រៃយ៍ផងដែរ បន្ទាប់មកវាមានថ្នាក់មជ្ឈិមពេញសិទ្ធិ ថ្នាក់មជ្ឈិមត្រៀម ហើយនិងថ្នាក់មួយទៀតគេហៅថា ជំនួយការមជ្ឈិម។

[១៥:១៣:០៨]

**ស៖** យើងបាននិយាយអំពីរចនាសម្ព័ន្ធរបស់គណៈកម្មាធិការនេះ ប្រហែលជានៅថ្ងៃស្អែក ក៏ប៉ុន្តែខ្ញុំចង់សួរអំពីលក្ខខណ្ឌនៃប្រព័ន្ធរាយការណ៍ គឺមានថ្នាក់ក្រោមត្រូវរាយការណ៍ជូនថ្នាក់លើ។ នៅក្នុងនេះគឺបានថែងថា ត្រូវរាយការណ៍អំពីសភាពការណ៍ និងអំពីកិច្ចការដែលខ្លួនបានធ្វើ។ តើលោកអាចពន្យល់ទេ ពាក្យទាំងពីរនោះមានន័យយ៉ាងម៉េច សភាពការណ៍ និងអំពីកិច្ចការដែលខ្លួនបានធ្វើ? ពាក្យទាំងពីរនេះ មានន័យខុសគ្នា ឬក៏វាមានន័យតែមួយទេ នៅពេលដែលគេនិយាយអំពីពាក្យទាំងពីរនេះ?

**ឆ៖** សភាពការណ៍ផ្សេង កិច្ចការផ្សេង។ សភាពការណ៍ គឺលក្ខណៈសម្បត្តិសម្ភារៈដែលកើតមានឡើងនៅក្នុងភារកិច្ចរបស់យើង។ ឧទាហរណ៍ ចំពោះស-២១ ក្នុងមួយថ្ងៃនេះ គេបញ្ជូនមនុស្សមកពីណា? ប៉ុន្មាននាក់? អាហ្នឹងគេហៅថា សភាពការណ៍។ ហើយកិច្ចការ ក្នុងមួយថ្ងៃនេះ បានឯកសារល្អ

ប៉ុន្មាន ដែលត្រូវរាយការណ៍ជាបន្ទាន់ជូនបក្ស នេះហៅថា កិច្ចការ។

[១៥:១៥:០២]

**ស៖** គោលការណ៍រាយការណ៍នេះ តើគោលការណ៍រាយការណ៍នេះអនុវត្តនៅស-២១ ដែរឬទេ? លោកបាននិយាយថា គេអនុវត្តចំពោះថ្នាក់លើ និងថ្នាក់ក្រោម រួមទាំងនៅថ្នាក់វរៈផងដែរ។ ហើយគេត្រូវរាយការណ៍ទៅថ្នាក់ខាងលើៗគេ។ ដូច្នេះថាតើនៅក្នុងៗកងវរៈវិញ នៅក្នុងស-២១ វិញ តើមានគោលការណ៍អនុវត្តដែលថាថ្នាក់ក្រោមអនុវត្តទៅថ្នាក់លើនៅក្នុងអង្គការភាព ឬក៏កងវរៈដែរទេ? ឬក៏វាអនុវត្តតែថ្នាក់លើទៅថ្នាក់ក្រោម ថ្នាក់ក្រោមទៅថ្នាក់តែប៉ុណ្ណោះ?

**ឆ៖** គោលការណ៍ក្នុងចំណុចទីប្រាំនេះ កំណាត់ខាងដើមវាមានលក្ខណៈជាសកល។ ថ្នាក់ក្រោម គ្រប់ថ្នាក់ត្រូវតែរាយការណ៍ទៅថ្នាក់លើរបស់ខ្លួនជាប់ ថ្នាក់លើជាប់របស់ខ្លួន។ បានន័យថាអនុសេនាធំរាយការជូនអនុសេនាតូច (សូមទោស) អនុសេនាធំរាយការណ៍ជូនវរសេនាតូច។ វរសេនាតូចរាយការណ៍ជូនវរសេនាធំ។ ថ្នាក់លើជាប់របស់ខ្លួនអ៊ីចឹង។ នេះលក្ខណៈនេះវាក្រឹត្យក្រមជាសកល។

ដោយឡែកនៅស-២១ ក៏ត្រូវអនុវត្តក្រឹត្យក្រមនេះជាមួយនឹង សុន សេន គាត់ច្រើនហៅខ្ញុំទៅធ្វើការបីថ្ងៃម្តង មិនដែលលើស ហើយក៏យូរៗអាចដល់បួនថ្ងៃអីម្តង ក៏ប៉ុន្តែជាមួយ សុន សេន ដោយឡែក គាត់តាមដានការងារជាប់ខ្លាំងណាស់ ណែនាំជាប់ណាស់ មួយថ្ងៃគាត់ទូរស័ព្ទមកខ្ញុំ ឆ្លងឆ្លើយគ្នាតាមទូរស័ព្ទប្រហែលជាអាចមួយម៉ោង ឬក៏លើស។ រាល់ល្ងាច ប្រហែលជាពីម៉ោងបួន ដល់ម៉ោងប្រាំ។ គាត់សួរអ្នកនេះឆ្លើយហើយម៉េច? ជាពិសេសមនុស្សណាដែលគាត់យកចិត្តទុកដាក់ គាត់សួរអ៊ីចឹងជាប់។ នេះកន្លែងដែលខ្ញុំរាយការណ៍ជូន សុន សេន ទៅរាយការណ៍ជូន សុន សេន ខ្ញុំសរសេរហើយនៅក្នុងកំណត់ហេតុដែលខ្ញុំបានរាយការណ៍ ទាំងផែនទី ផែនអីជូនចៅក្រមស៊ើបអង្កេត។ ដោយឡែកក្រោយមកនៅជាមួយនឹង នួន ជា មេធំ។ ត្រូវរាយការណ៍ដែរ បីថ្ងៃ ឬក៏យ៉ាងយូរណាស់ប្រាំថ្ងៃម្តង។ ប៉ុន្តែ នួន ជា គាត់អត់ប្រើទូរស័ព្ទទេ គាត់ហៅខ្ញុំទៅធ្វើការ។ កន្លែងរាយការណ៍ភាគច្រើនលើសលុបស្ទើរតែទាំងអស់គឺនៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត។ គាត់អង្គុយបែរខ្នងមកផ្លូវ ឌុកទ័រ ហាន់ ផ្លូវនោះ ខ្ញុំជឿថាផ្លូវ ឌុកទ័រ ហាន់។ ខ្ញុំអង្គុយទៅខាងក្នុងគាត់។ នេះការរាយការណ៍គឺទៅអ៊ីចឹង។ ក៏ប៉ុន្តែដោយឡែក ស-២១ ឯកសារណាបន្ទាន់ ចម្លើយសារភាពណាចាំបាច់ ខ្ញុំតែទៅមេ សុន សេន ឲ្យមកយក ឲ្យគេមកយក ឲ្យនីរសារមកយកភ្លាម។

[១៥:១៨:៣៣]

ដូច្នេះនៅស-២១ ការរាយការណ៍បន្ទាន់ ឬយ៉ាងម៉េចគឺអាស្រ័យនៅលើសេចក្ដីសារភាពរបស់អ្នកទោស។ នេះសូមបញ្ចប់ប៉ុណ្ណឹង។

**ស៖** សូមអរគុណដែលលោកឆ្លើយប្រាប់។ យើងបានពិភាក្សាអំពីរបៀបដែលលោករាយ-ការណ៍ពីស-២១ ទៅថ្នាក់លើ លោករាយការណ៍ជូននរណា រាយការណ៍តាមរបៀបណា ហើយគេបញ្ជូនព័ត៌មានដោយរបៀបណា? ក៏ប៉ុន្តែនៅពេលនេះ ខ្ញុំចង់សុំសួរនៅក្នុងស-២១ ផ្ទាល់តែម្ដង ថាតើព័ត៌មានរបបប្រព័ន្ធរាយការណ៍នោះ គេយ៉ាងម៉េច? គេរាយការណ៍ពីក្រោមទៅដល់លោកតាមរបៀបណា? ហើយលោកបញ្ជូនព័ត៌មានពីលោកទៅថ្នាក់ក្រោមនេះដោយរបៀបណា? ដូច្នេះសូមលោកជួយបញ្ជាក់បំភ្លឺឲ្យបានច្បាស់។ នៅក្នុងស-២១ វាជាកងវរៈមួយឯករាជ្យ។ នៅក្នុងស-២១ត្រូវបែងចែកជាកងអនុសេនាធំតូចៗតាមផ្នែកតូចៗនៅក្នុងស-២១។ ដូច្នេះ នៅក្នុងផ្នែក ឬក៏អង្គភាពតូចៗនេះរាយ-ការណ៍ទៅថ្នាក់លើរហូតទៅដល់លោក។ នេះគឺជាអ្វីដែលលោកចង់មានន័យអ៊ីចឹងមែនទេ? អ្វីដែលលោកសង្ខេបអម្បាញ់មិញហ្នឹង?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលឆ្លើយ! សូមអញ្ជើញមេធាវីអន្តរជាតិការពារក្ដីលោក នួន ជា!

[១៥:២០:១៥]

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ វាជាសំណួរមួយលម្អិត ហើយខ្ញុំខ្លាចសាក្សីឆ្លើយណាស់។ ហើយខ្ញុំខ្លាចថាចម្លើយហ្នឹង វានឹងឆ្លើយហួសពីវិសាលភាពនៃការជំនុំជម្រះវគ្គទីមួយ។ យើងដឹងហើយថាសហព្រះរាជអាជ្ញាគឺគាត់ពិតជាព្យាយាមខំប្រឹងសួរសំណួរក្នុងហ្នឹងប្រហែលជា២០ចំណុច អំពីវគ្គដំបូងនេះ។ ហើយក្នុងនោះ គឺគាត់បានសុំដាក់បញ្ចូល ស-២១ នៅក្នុងបញ្ជីជំនុំជម្រះវគ្គទីមួយផងដែរ។ តាមអ្វីដែលខ្ញុំដឹងនោះ គឺសេចក្ដីសម្រេចថា សុំឲ្យបញ្ចូល ស-២១ ទាំងមូលនោះ គឺមិនទាន់បានទទួលស្គាល់និងសម្រេចនៅឡើយនោះទេ។ ហើយខ្ញុំសូមបញ្ជាក់ថា នៅក្នុងនេះគឺ យើងនិយាយអំពីតែប្រព័ន្ធរាយការណ៍ដែលពាក់ព័ន្ធទៅនឹង ស-២១ ត្រង់សវនាការវគ្គដំបូងរបស់យើងតែប៉ុណ្ណោះ។

[១៥:២១:១៨]

វគ្គដំបូងរបស់យើង គឺពាក់ព័ន្ធតែនឹងអង្គហេតុផ្លាស់ទីលំនៅ ពីទីក្រុងភ្នំពេញដំណាក់កាលវគ្គទីមួយ ដែលបានកើតឡើងមុនពេល ស-២១ បានបង្កើត។ ដូច្នេះ បើសិនជាអង្គហេតុក្រៅពីហ្នឹង គឺវាមិន

ពាក់ព័ន្ធនៅ ស-២១ នោះទេ។ ហើយវាមិនពាក់ព័ន្ធទៅនឹងការជម្លៀសទីក្រុងភ្នំពេញ រួមទាំងការផ្លាស់ទីលំនៅ វគ្គដំបូង ដំណាក់កាលទីមួយនោះទេ។

ដូច្នេះហើយ ខ្ញុំសូមអនុញ្ញាតជំរុញអង្គជំនុំជម្រះឲ្យធ្វើការកំណត់ ការតាំងសំណួររបស់សហព្រះរាជអាជ្ញា ហើយយើងក៏មានការចង់ដឹង ហើយយើងក៏មានការគិតគូរអំពីបញ្ហានៃពេលវេលាដែលសហព្រះរាជអាជ្ញាចង់បានក្នុងការដេញដោលសាក្សីរូបនេះផងដែរ។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញ!

[១៥:២២:១១]

**លោក វីណ្ឌៀម ស្មីត៖**

លោកប្រធាន! គោលបំណងដែលយើងដេញដោលភស្តុតាងមួយនេះ គឺមិនមែនបញ្ចូលអង្គហេតុ ស-២១ នោះទេ។ អង្គជំនុំជម្រះបានសម្រេចហើយ ហើយអង្គជំនុំជម្រះមានឆន្ទានុសិទ្ធិក្នុងការសម្រេចទៅលើចំណុចនេះ។ គោលបំណងដែលយើងខ្ញុំតាំងសំណួរនេះ គឺដើម្បីបង្ហាញឲ្យបានជាក់លាក់ ថាតើប្រព័ន្ធទំនាក់ទំនងវាយ៉ាងម៉េច? សហព្រះរាជអាជ្ញា គឺនឹងកំណត់គោលដៅរបស់ខ្លួន ប្រសិនបើសហព្រះរាជអាជ្ញានឹងជំទាស់ទៅនឹងការឆ្លើយ ប្រសិនបើគាត់ថាមិនមានភស្តុតាងទៅនឹងអង្គហេតុដែលគាត់ឆ្លើយនោះទេ។ អ្វីដែលយើងធ្វើនេះ ដើម្បីប្រមូលព័ត៌មានភស្តុតាងទៅលើប្រតិបត្តិការ ប្រព័ន្ធទំនាក់ទំនងនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា។

[១៥:២៣:០០]

កថាខណ្ឌ៧២ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ តែក្នុងនេះ ពាក់ព័ន្ធនឹងវគ្គដំបូង វាទាក់ទងទៅនឹងប្រព័ន្ធទំនាក់ទំនងនេះ។ នៅក្នុងកថាខណ្ឌនោះ លើកឡើងថាប្រព័ន្ធទំនាក់ទំនងនៅ ស-២១ កំណត់ហេតុត្រូវបានរក្សាយ៉ាងខ្ជាប់ខ្ជួន យ៉ាងលម្អិត។ ខ្ញុំគិតថា អ្វីដែលខ្ញុំសួរ វាសំខាន់ ដោយសារតែវាពាក់ព័ន្ធទៅនឹងការធ្វើទំនាក់ទំនងពីអង្គភាពមួយ ទៅអង្គភាពមួយ ហើយឲ្យយើងយល់យ៉ាងមុតមាំ ថាតើអង្គភាពនីមួយៗនោះធ្វើការទំនាក់ទំនងយ៉ាងម៉េចក្នុងអំឡុងពេលនោះ។ វាជាការលើកឡើងខុស ដោយមេធាវីការពារក្តី ដែលថាចំណុចនេះវាពាក់ព័ន្ធទៅនឹងការផ្លាស់ប្តូរដំណាក់កាលទី-- ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយតែប៉ុណ្ណោះ។ ក៏ប៉ុន្តែវាក៏ពាក់ព័ន្ធដំណាក់កាលទីពីរផងដែរ ដែលចូលទៅដល់ឆ្នាំ ១៩៧៦-៧៧។ ស-២១ បានដំណើរការក្នុងពេលដែលបទល្មើសទាំងអស់នេះបានកើតឡើង។

ដូច្នេះហើយ វាជាសូចនាករមួយ បង្ហាញអំពីប្រព័ន្ធទំនាក់ទំនងដែលបានអនុវត្ត ធ្វើឡើងនៅក្នុងកម្ពុជាប្រជាធិបតេយ្យ។ សហព្រះរាជអាជ្ញាមិនព្យាយាមសុំឱ្យសាក្សីបង្ហាញអំពីបទល្មើសដែលកើតឡើងនៅ ស-២១នោះទេ។ អង្គជំនុំជម្រះបានបង្គាប់យើងខ្ញុំហើយថា ឱ្យសំណួររបស់ខ្ញុំហ្នឹងក្តោបតែទៅលើប្រព័ន្ធទំនាក់ទំនង ថាតើព័ត៌មាននោះប្រមូលយ៉ាងម៉េច? ទំនាក់ទំនងយ៉ាងម៉េចដែលពាក់ព័ន្ធទៅនឹងដំណាក់កាលជំនុំជម្រះនេះ។ សូមអរគុណ។

[១៥:២៤:៣៦]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវីការពារក្តីលោក អៀង សារី!

**លោក ម៉ៃខល កាណាវាស៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម អស់លោក លោកស្រីនៅក្នុងបន្ទប់សវនាការ និងជុំវិញបន្ទប់សវនាការសាជាថ្មី។

សហព្រះរាជអាជ្ញាអាចលើកឡើងថា តើស-២១ ដំណើរការយ៉ាងម៉េច? បង្កើតឡើងដោយរបៀបណា? ប្រព័ន្ធរាយការណ៍យ៉ាងម៉េច? សហព្រះរាជអាជ្ញាបានបញ្ជាក់-- សាក្សីបានបញ្ជាក់មុនហើយថា ខាងដើមហើយថា របាយការណ៍តាមផ្តល់ជូន បញ្ជូនតាមរយៈនីរសារ ឬតាមឡាន។ យើងបានស្តាប់ឮពីសហព្រះរាជអាជ្ញាគាត់ចង់សួរជន-- សាក្សីរូបនេះឱ្យគាត់ធ្វើជាអ្នកជំនាញ ដែលនៅក្នុងនោះគាត់-- ដែលសាក្សីរូបនេះ គឺជាអ្នកដំណើរការស-២១ ហើយដើម្បីឱ្យគាត់យល់អំពីប្រព័ន្ធរាយការណ៍នៅក្នុងក្រសួង និងស្ថាប័នផ្សេង។ យើងខ្ញុំសូមជំទាស់ទៅនឹងការសួរសំណួរបែបនេះ គឺយើងឱ្យសួរតែសំណួរណាដែលសាក្សីបានដឹង អង្គហេតុដែលវាពាក់ព័ន្ធទៅនឹងប្រព័ន្ធរាយការណ៍នៅក្រៅ ស-២១ ក៏ប៉ុន្តែត្រូវសួរមួយដំណាក់កាលម្តងៗ។ ក៏ប៉ុន្តែសាក្សីរូបនេះ យើងដឹងហើយគាត់ជាអ្នកដំណើរការស-២១ ហើយយើងដឹងហើយថា គាត់ប្រព័ន្ធរាយការណ៍នៅក្នុងនោះយ៉ាងម៉េច? ក៏ប៉ុន្តែបើយើងសន្និដ្ឋានជារួមអំពីប្រព័ន្ធរាយការណ៍នៅទូទាំងប្រទេស គឺជាកំហុសមួយ។

[១៥:២៦:១៥]

ប្រសិនបើយើងសួរអំពី ស-២១ ថាតើគាត់ដំណើរការមន្ទីរនោះយ៉ាងម៉េច? ហើយយកជាគំរូមិនបញ្ហាទេ។ នេះគឺជាឧទាហរណ៍ដែលយើងអាចសន្និដ្ឋានបាន ក៏ប៉ុន្តែតាមការយកចម្លើយពីសាក្សីនេះ មិនមែនថាចម្លើយរបស់គាត់អាចសន្និដ្ឋានថាវាអនុវត្តនៅទូទាំងប្រទេសនោះទេ។ យើងគួរតែយកកោះហៅ

សាក្សីមួយផ្សេងមកផ្តល់សក្ខីកម្ម។ ដូច្នេះយើងដឹងហើយ គឺអ្វីដែលសហព្រះរាជអាជ្ញាចង់ធ្វើនោះ ដើម្បីធ្វើការដេញដោលចម្លើយទាំងអស់ពី ឌុច ហើយគាត់ចង់ទាញយកសក្ខីកម្មដែលថា វាអាចពាក់ព័ន្ធទៅនឹងរឿងក្តីរបស់គាត់។ ហើយវាអាស្រ័យទៅលើអង្គជំនុំជម្រះតែប៉ុណ្ណោះដែលជាអ្នកផ្តល់ទម្ងន់ទៅលើភស្តុតាង និងសក្ខីកម្មទាំងអស់នេះ។ សូមអរគុណ។

[១៥:២៧:២៣]

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ សាក្សីនេះ គឺសាក្សីដែលល្អប្រពៃនៅក្នុងរឿងក្តីនេះ ដើម្បីឲ្យយើងយល់អំពីរចនាសម្ព័ន្ធធ្វើការងារនៅក្នុងកម្ពុជាប្រជាធិបតេយ្យ។

ព័ត៌មានយ៉ាងច្រើនលើសលុបដែលយើង-- ព័ត៌មានដែលយកចេញពីអ្នកទោសជាង១២ពាន់នាក់នោះ ដែលវាអាចបង្ហាញឲ្យយើងឃើញអំពីប្រព័ន្ធវាយការណ៍ និងប្រព័ន្ធការងារនៅស-២១។ ខ្ញុំសូមមើលទៅលើលោក ដេវីដ ឆេនដ៍ល័រ ដែលគាត់លើកឡើងអំពីថា អ្នកទោសត្រូវបានគេចាត់ទុកយ៉ាងម៉េច? ជាពិសេសនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ អ្វីដែលសហព្រះរាជអាជ្ញាចង់ធ្វើនេះ គឺរបៀបដែលបក្សធ្វើទំនាក់ទំនងរួមទាំងនៅស-២១ ផងនោះ គឺវាមានលក្ខណៈស្រដៀងគ្នាតែប៉ុណ្ណោះ។

[១៥:២៨:២៨]

វាដូចទៅនឹងការធ្វើទំនាក់ទំនងគោលនយោបាយរបស់បក្សទៅគ្រប់ទីកន្លែងនៅក្នុងប្រទេស។ ខ្ញុំសូមដកស្រង់សម្តី--

**លោក ម៉ៃខល កាណាវ៉ាស៖**

ខ្ញុំសូម ខ្ញុំមិន--

**ប្រធានអង្គជំនុំ៖**

តំណាងសហព្រះរាជអាជ្ញានិយាយចប់សិន។ លោកមិនអាចធ្វើដូច្នេះបានទេ! សូមអញ្ជើញលោកតំណាងអយ្យការ! សូមអញ្ជើញតំណាងអយ្យការ!

**លោក វីល្លៀម ស្មីត៖**

គឺលោក ដេវីដ ឆេនដ៍ល័រ បាននិយាយអំពីបញ្ហាដែលពាក់ព័ន្ធទៅនឹងស-២១ ព័ត៌មានទាំងឡាយ

វាបានបង្ហាញអំពីការសិក្សាទៅលើ ស-២១។ គេបានលើកឡើងផងដែរ អំពីអ្នកទោសដែលត្រូវបានរត់គេចខ្លួន ហើយការដែលបង្ហាញរូបភាពអ្នកទោសនោះ ជាការបង្ហាញមួយយ៉ាងច្បាស់លាស់ បង្ហាញអំពីសង្គមនៅក្នុងសម័យរបបនោះ។ ដូច្នេះហើយយើងដឹងហើយថា សាក្សីរូបនេះ គឺមានព័ត៌មានយ៉ាងច្រើនពាក់ព័ន្ធទៅនឹងប្រព័ន្ធរាយការណ៍នៅស-២១។ ដូច្នេះហើយពេលដែលយើងសួរទៅលើចំណុចទាំងអស់នេះបង្ហាញឲ្យយើងឃើញជាសូចនាករពាក់ព័ន្ធទៅនឹងការអនុវត្តនៅតាមកន្លែងផ្សេងទៀត នៅក្នុងប្រទេស។

[១៥:២៩:៤៩]

ខ្ញុំដឹងហើយថា ខាងមេធាវីការពារក្តីចង់ជំទាស់ទៅលើការតាំងសំណួរនេះ ដូច្នេះគាត់ចង់បិទជំពូកទៅលើប្រព័ន្ធទំនាក់ទំនង និងអង្គហេតុទាំងអស់នេះ។ អ្វីដែលខ្ញុំចង់សួរនេះ គឺគ្រាន់តែយើង ឲ្យយើងយល់អំពីកម្ពុជាប្រជាធិបតេយ្យតែប៉ុណ្ណោះ។ ជនជាប់ចោទ គាត់មិនផ្តល់សក្ខីកម្ម គាត់មិនបានជម្រាបយើង ថាតើមានអ្វីកើតឡើងនៅក្នុងរយៈកាលនោះ? ហើយប្រព័ន្ធទំនាក់ទំនងយ៉ាងម៉េច? ដូច្នេះហើយយើងត្រូវតែប្រើបុគ្គលដែលគាត់មានលទ្ធភាពមកប្រាប់យើង។ ដូច្នេះហើយ ត្រង់ចំណុចនេះបុគ្គលនេះ គឺគាត់អាចជាអ្នកដែលអាចដឹងអំពីប្រតិបត្តិការ និងប្រព័ន្ធទំនាក់ទំនង។ យើងផ្តោតតែសំណួររបស់យើងលើប្រព័ន្ធរាយការណ៍តែប៉ុណ្ណោះ ហើយយើងមិនផ្តោតសំណួររបស់យើងក្រៅវិសាលភាពទាំងអស់នេះទេ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក កាណាវាស!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ ការជំទាស់របស់ខ្ញុំជាបឋមហ្នឹង គឺថាយើងមានសាក្សីនៅទីនេះដែលបញ្ជាក់ព័ត៌មានទាំងអស់ ក្នុងត្រៀម ក្នុងការត្រៀមរឿងក្តីរបស់គាត់។ ដូចដែលលោកចៅក្រមជ្រាបហើយថា យើងឆ្លើយសំណួរជាច្រើនខែ ដោយមានមេធាវីជំនួយរបស់គាត់ផងដែរ។ ដូច្នេះ ប្រសិនបើមិនមែនជាអ្វីដែលបង្កើតជាព័ត៌មាន តើអ្វីជាបង្កើតព័ត៌មាន? ឥឡូវនេះ យើងមានសហព្រះរាជអាជ្ញាដោយវត្តមានសាក្សី ហើយទៅសួរគឺសាក្សី អ្វីដែលចង់ឲ្យសាក្សីនិយាយអ្វីដែលគាត់ចង់បាន។ យើងចង់បានឲ្យច្បាស់នោះ គឺថាតើសាក្សីនោះចង់និយាយពីអ្វី? ពីរចនាសម្ព័ន្ធ សាក្សីនេះ និយាយអំពីអ្វីដែលគាត់បានដឹង អ្វីដែលគាត់បានអាន អ្វីដែលគាត់បានវិភាគ ហើយអ្វីដែលគាត់បានស្រាវជ្រាវ អ្វីដែលគាត់បាន

សរសេរអំពីហ្នឹង ចាប់តាំងពីនោះមក គឺមិនពាក់ព័ន្ធនោះទេ។ ថាតើជនជាប់ចោទផ្តល់សក្ខីកម្ម មិនផ្តល់សក្ខីកម្ម អាហ្នឹងជាសិទ្ធិរបស់ពួកគាត់។

[១៥:៣១:៤២]

ខ្ញុំឃើញថាជាការបំពាន គឺបំពានយ៉ាងដាច់ខាត ដែលសហព្រះរាជអាជ្ញានៅឈរនៅទីនេះ ហើយប្រើនៅទីនេះ ថាជាការអនុគ្រោះ។ នោះ ថាជាបុគ្គលពិសេស។ បុគ្គលម្នាក់នេះ ក៏អាចនិយាយអំពីទារុណកម្ម អាចនិយាយពីការសម្លាប់ អាចនិយាយអំពីការបង្ខំ ក្នុងកុហក ក្នុងការកុហក ក្នុងការចម្លើយសារភាព និយាយទារុណកម្មនៅស-២១ ហើយថាតើគាត់រាយការណ៍ទៅអ្នកណា? ប្រសិនបើ សហព្រះរាជអាជ្ញាបង្ហាញពីមូលដ្ឋានមិនបានធ្វើបែបនោះទេ គឺថាវាអាចនឹងទទួលព័ត៌មានពីសាក្សីរូបនេះ អំពីព័ត៌មានដែលត្រូវបន្តទៅទៀត ថាតើត្រូវដូចម៉េច នៅក្នុងកាលៈទេសៈ កាលពេលវេលានោះ? ប៉ុន្តែគំនិតនេះ ហាក់ដូចជាបង្ហាញថា គាត់គឺជាប្រភពនៃព័ត៌មាន។ ហើយថាមិនមានអ្នកណាផ្សេងទៀត ដែលផ្តល់សក្ខីកម្មទេ គឺថា ហើយគាត់ទៅយោង ដេវីដ ឆេនដ៍ល័រ ដែលថាអាចបង្ហាញ ឬមិនបង្ហាញខ្លួននៅតុលាការនោះ។ ដោយសារតែ ឆេនដ៍ល័រ និយាយថា ប្រព័ន្ធគុកនោះ គឺតំណាងឱ្យសង្គមទាំងមូលរបស់កម្ពុជាប្រជាធិបតេយ្យ។ ហើយមិនមែនជាគំនិតដែលត្រឹមត្រូវទេ នេះគួរឱ្យអស់សំណើចទៅវិញទេ គ្មានន័យទេ ការលើកបែបនេះ។ នេះហើយដែលខ្ញុំលើកការជំទាស់។

[១៥:៣២:៥០]

គាត់ គប្បីតែចុចទៅរកចំណុចមួយ ហើយអ្វីដែលសហព្រះរាជអាជ្ញាលើកឡើងនេះ គឺថាវាជាការបំពានមួយ ដែលគឺថាដូចជាឱ្យសាច់ដុំដ៏ខ្លាំងទៅសាក្សីរូបនេះ គឺថាគាត់អាចនិយាយអ្វីក៏បាន ដោយសមស្រប។ អ្វីដែលសហព្រះរាជអាជ្ញាបានចង្អុលបង្ហាញ។ គឺមិនកម្រិតទៅលើសមត្ថភាពរបស់សហព្រះរាជអាជ្ញាទេ ប៉ុន្តែឱ្យគាត់ធ្វើការងារឱ្យបានត្រឹមត្រូវ។ សហព្រះរាជអាជ្ញាបានដឹកមុខសាក្សីពេញមួយថ្ងៃហើយ គឺគាត់នាំមុខរហូតបែបនេះ។

ដូច្នេះ ដែលហៅថាសំណួរនាំមុខ គឺថាមិនត្រឹមត្រូវទេ។ ប៉ុន្តែការពិត គឺគាត់បានសួរសំណួរនាំមុខ។ ខ្ញុំជំទាស់ ថាការធ្វើបែបនោះ គឺមិនត្រឹមត្រូវទេ។ ហើយយើងព្យាយាមថា ធ្វើម៉េចគឺមិនត្រូវ ធ្វើឱ្យរឿងក្តីទាំងមូលនេះ ផ្អែកលើតែសាក្សីរូបនេះទេ។ ហើយអះអាងថា មិនមានសាក្សីរូបណាផ្សេងទៀតនោះទេ។ ហើយយើងត្រូវតែស្តាប់គាត់តែម្នាក់នោះទេ។ យើងគ្រាន់តែសួរគាត់ថា អ្វីដែលគាត់បានដឹងអ្វីដែលពិតជាគាត់បានដឹងនោះ។ ដូច្នេះហើយ ដូច្នេះ គឺថាសូមបញ្ឈប់សំណួរនោះ សំណួរថាតើអ្នក

ណា? អ្វីពីកន្លែងណា? គួរតែចាប់ផ្តើមពីសំណួរបែបនោះវិញ បាទ។

[១៥:៣៤:១៨]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៣៥:១៨]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសម្រេចថា សេចក្តីជំទាស់មេធាវីទាំងពីរក្រុម មិនមានប្រសិទ្ធភាព អង្គជំនុំជម្រះត្រូវការស្តាប់នូវការផ្តល់សក្ខីកម្មរបស់សាក្សីរូបនេះ ចំពោះសំណួរដែលតំណាងសហព្រះរាជអាជ្ញាបានសួរ ហើយសូមឱ្យសាក្សីឆ្លើយតបទៅនឹងសំណួរ ដែលសហព្រះរាជអាជ្ញាបានសួរចុងក្រោយអម្បាញ់មិញនេះ ហើយប្រសិនបើសាក្សីមិនចាំសំណួរទេ គឺសូមតំណាងសហព្រះរាជអាជ្ញា តាំងសំណួរចុងក្រោយនេះសាជាថ្មីម្តងទៀត។ សូមអញ្ជើញ!

**សួរដោយលោក វីណ្សៀម ស្មីត៖**

អាចនឹងមានការពិបាក ដើម្បីឱ្យសាក្សីចាំសំណួរដែលខ្ញុំបានសួរដោយសារថា ការពិភាក្សានេះក៏លំបាក ប៉ុន្តែមានកំណត់ត្រានៅក្នុងឯកសារតុលាការ ហើយយើងមិនបានសួរសាក្សីរូបនេះ នៅក្នុងដំណាក់កាលស៊ើបអង្កេតរបស់រឿងក្តីទេ អាហ្នឹងជាភារកិច្ចរបស់សហចៅក្រមស៊ើបអង្កេតឯណោះទេ។

**ស៖** លោក កាំង ហ្គេកអ៊ាវ សំណួរទាំងអស់នេះ ដែលខ្ញុំនឹងបម្រុងនឹងសួរលោកនោះ គឺនិយាយអំពីប្រព័ន្ធទំនាក់ទំនង គឺមិនមែនជាបទឧក្រិដ្ឋនៅស-២១ ទេ ហើយក៏មិនមែនអំពីទារុណកម្មដែរ គឺនិយាយអំពីវិធីនៃការប្រាស្រ័យទាក់ទង ដើម្បីឱ្យតុលាការ ឬក៏យើងខ្ញុំបានយល់បាន ហើយយើងក៏ចង់យល់ តើទំនាក់ទំនងវាដំណើរការចេញរបៀបណា? ពីណា ពីថ្នាក់ក្រោម ពីស-២១ រហូតទៅដល់ថ្នាក់ដែលលោកធ្វើការ? ថាតើដោយវិធីណា? ចេញពីថ្នាក់លោកទៅថ្នាក់ក្រោមនោះ ដោយវិធីណា? បន្ទាប់មកទៀត ហើយយើងនឹងសួរលោកអំពី ថាតើលោកប្រាស្រ័យទាក់ទងទៅនឹងថ្នាក់លើដែលនៅក្រៅស-២១ នោះដូចម្តេច? ដូច្នេះ ប្រសិនបើលោក អាចពន្យល់អំពីការសង្កេត អំពីគំនិត អំពីការប្រាស្រ័យទាក់ទងនោះ គឺថាអាចនឹងធ្វើឱ្យសំណួរ និងចម្លើយនោះ អាចចំទិសដៅ។ តើលោកអាចនិយាយបានទេ ជាបឋម យើងនិយាយអំពីប្រព័ន្ធទំនាក់ទំនង យើងនិយាយអំពីព័ត៌មានថាតើព័ត៌មានវាធ្វើដំណើរដូចម្តេច? តើព័ត៌មានអ្វីខ្លះ ដែលត្រូវបានកត់ត្រានៅស-២១? ហើយប្រភេទព័ត៌មានបែបណា

ដែលគេកត់ត្រានោះ ជាពិសេសនៅក្នុងការប្រព្រឹត្តទៅនៃប្រតិបត្តិការស-២១ របស់លោកនោះ?

[១៥:៣៨:២៨]

**ឆ៖** ព័ត៌មានមានពីរ។ ទីមួយ គឺផ្ទៃក្នុង អង្គភាពស-២១ ទាំងមូល ពីខាងក្រោមគេរាយការណ៍រហូតជាខ្សែចង្វាក់ មកប្រមូលផ្តុំគ្នាត្រឹមមិត្ត ហ៊ី, មិត្ត ហ៊ី សរុបជាគោលការណ៍រាយការណ៍ប្រាប់ខ្ញុំ។ ហើយដល់សភាពការណ៍ណាមួយ ពេលវេលាណាមួយ ខ្ញុំរាយការណ៍ទៅខាងលើ នេះពីរឿងផ្ទៃក្នុងអង្គភាព។ ឯចំណែក ព័ត៌មានជាចម្លើយ អ្នកសួរគេរាយការណ៍នៅពេលណាដែលចប់មនុស្សម្នាក់ៗ ហើយគេផ្តល់ឯកសារដែលគេកសាងបានមកឲ្យខ្ញុំ ខ្ញុំអានពិនិត្យសង្ខេបខ្លីៗ។ មានសំណៅជាភស្តុតាងស្រាប់ជូនទៅខាងលើ ហើយខ្ញុំមិនបាច់និយាយថា ខាងលើជាអ្នកណាទៀតទេ វាច្បាស់ហើយឯកសារនៅមានជាភស្តុតាង។ ដូច្នេះ ឯកសារដែលជាសេចក្តីសារភាពរបស់ស-២១ ទៅខាងលើ វាមួយផ្នែកទៅអាហ្នឹងពេលខ្លះបន្ទាន់ត្រូវការរាយការណ៍បន្ទាន់។ ឯចំណែកម្យ៉ាងទៀត ខាងភស្តុភារ ខាងទៅរៀនសូត្រអី អាហ្នឹងជាការទាក់ទងរវាងខ្ញុំជាមួយនឹងខាងគណៈកម្មាធិការសេនាធិការ ដែលមានជំនួយការគេប្រចាំការនៅនុ៎ង ដូច ឧទាហរណ៍មិត្ត សោម។ ថ្ងៃណាខាងលើបើករៀន ថ្ងៃណាប្រគល់ឯកសារទង់បដិវត្តមកឲ្យខ្ញុំ ហ្នឹងគឺជាប់គ្នា ទាក់ទងជាប់គ្នាអ៊ីចឹង។ បាទសូមចប់។

**ស៖** សូមអរគុណ។ យើងអាចនឹងពិនិត្យមើលចំណុចមួយ ហើយយើងផ្តោតទៅលើព័ត៌មានដែលបានកត់ត្រា។ លោកបានផ្តល់សក្ខីកម្មថា នៅក្នុងអំឡុងពេលនៃប្រតិបត្តិការស-២១ ដែលថាមានជនរងគ្រោះជាង១២.000 ដែលត្រូវបានស្លាប់នៅទីនោះ ហើយក៏មានឯកសារជាច្រើននុ៎ងត្រូវបានរក្សាទុកទាំងនោះដែរឬទេ?

[១៥:៤១:១៨]

**ឆ៖** ឯកសារដូចមិនមែនជាច្រើនទេ បើតាមខ្ញុំយល់គឺទាំងអស់ គ្រាន់តែការិយាល័យសហព្រះរាជអាជ្ញា ឯកសារខ្លះបង្ហាញឲ្យខ្ញុំពន្យល់ ឯកសារខ្លះមិនបង្ហាញនៅឡើយ។

**ស៖** នៅពេលដែលគេបញ្ជូនមនុស្សមកដល់ស-២១ បន្ទាប់ពីគេចាប់ខ្លួនហើយនោះ តើមានព័ត៌មានអ្វីកត់ត្រា ដែលត្រូវបានកត់ត្រាទេ ទាក់ទងនឹងការបញ្ជូនមកដល់។ ប្រសិនបើមាន តើព័ត៌មានប្រភេទណាដែលត្រូវបានកត់ត្រាទុក ដែលបញ្ជាក់ពីព័ត៌មានអ្នកដែលត្រូវបានគេចាប់ខ្លួននោះ?

**ឆ៖** អ្នកដែលត្រូវគេចាប់ខ្លួនមានពីរប្រភេទ ប្រភេទមនុស្សធម្មតាដែលមេក៏ក្តាប់មិនបាន ខ្ញុំក៏ក្តាប់មិនបាន មិនមានសារៈសំខាន់។ ព្រះរាជអាជ្ញាឃើញហើយ សំបុត្រទទួល អ៎! សំបុត្រដែល

អ្នកទោសចូលរបស់មិត្ត ហ៊ី គាត់សរសេរនុ៎ង នៅក្នុងសំណុំរឿងលេខ០០១ មានបង្ហាញ។ សំបុត្របែបនេះច្រើនដែរ ជាពិសេសសំបុត្ររបស់លោកពូ ចាន់ ស្អី? ចិន-- នង ចិន ហើយនិងមីង មុំ យ៉ូវ ឪពុកម្ដាយ នង ចាន់ផល។ ឃើញហើយ ឃើញគេសរសេរយ៉ាងម៉េច អីយ៉ាងម៉េចច្បាស់។ ឯកចំណែកអ្នកដាក់ណាដែលសំខាន់ចូលមក ចូនអីគេមិនទាន់កត់អាហ្នឹងភ្លាមទេ ព្រោះគេខ្លាចបែកការណ៍ គេប្រគល់ទៅកន្លែងមួយពិសេស។ ដូចជា កុយ ធួន ចូល អ្នកណាកត់? អត់ទាន់កត់ទេ។ ខ្ញុំរៀបចំចាត់តាំងសួរដោយខ្លួនឯង ដោយគ្មានទារុណកម្ម។ អាហ្នឹងមួយផ្នែកទៅ។ មេតាមជាប់ មិត្ត ឌុច ឆ្លើយហើយឬនៅ? ខ្ញុំថានៅបង។ ស្អែកឡើងសួរទៀត មិត្តឌុច ឆ្លើយហើយនៅ? ខ្ញុំថា ជិតហើយ។ ដល់នេះ មិត្ត ឌុច ឆ្លើយនៅ? ខ្ញុំថា ឆ្លើយហើយ។ ហ្នឹង មេតាមជាប់អ៊ីចឹង។ រួចដល់បានចម្លើយ គឺហ្វូតូកូពីទៅភ្លាមៗជូនគាត់ ហ្នឹងមួយបែបទៀត។ ដូច្នេះបញ្ហាវាខុសគ្នាអ៊ីចឹង។ ស្អីដែលបក្សចាប់អារម្មណ៍ខ្លាំង ស្អីដែលបក្សមិនសូវចាប់អារម្មណ៍។ ដូចឯកសារខ្លះ ឧទាហរណ៍ព្រះរាជអាជ្ញារើទៅឃើញហើយ។

[១៥:៤៤:០៧]

**ស៖** សូមអរគុណ ហើយយើងអាចនឹងផ្ដោតទៅលើតែសំណួរដែលខ្ញុំសួរ នៅពេលដែលគេបញ្ជូនអ្នកទោសមកដល់ស-២១ តើគេបង្កើតបញ្ជីសម្រាប់អ្នកទោសដែលមកដល់ហ្នឹងដែរឬទេបាទ?

**ឆ៖** បញ្ជីគេរាយការណ៍មួយសន្លឹកៗមក នៅក្នុងសំណុំរឿងលេខ០០១ គឺឃើញច្បាស់ហើយមានរាយការណ៍ថ្ងៃនេះចូលប៉ុណ្ណេះនាក់ ថ្ងៃនេះចូលប៉ុណ្ណេះនាក់។

**ស៖** លោកនិយាយថា តាមធម្មតានៅពេលដែលគេចាប់មនុស្ស គេបញ្ជូនមក ហើយមានបញ្ជីមកជាមួយដែរ។ តើអាចមានផងដែរឬទេ ដែលថាបញ្ជីហ្នឹងកត់ត្រាដោយ ស-២១ ផ្ទាល់របស់ខ្លួន ឬក៏បញ្ជីដែលគេបញ្ជូនមកជាមួយមនុស្សដែលគេបញ្ជូនមកបាទ?

**ឆ៖** ភាគច្រើន អ្ហេ!ទាំងស្រុង ហើយនិងដាច់ខាត វាមានបញ្ជីមួយរបស់ ស-២១ របស់វា។ ក៏ប៉ុន្តែពេលខ្លះ ម្ចាស់អង្គភាពដើម គេបញ្ជូនពីនាយមក។ ជូនអីម្ចាស់ដើម ម្ចាស់អង្គភាពគេរាយការណ៍ព័ត៌មានខ្លីៗមកឲ្យថែមទៀត។

[១៥:៤៥:៥០]

**ស៖** តើលោកអាចប្រាប់តុលាការបានទេថា តើព័ត៌មានប្រភេទណាដែលតែងតែគេកត់ត្រានៅ ស-២១ ទាក់ទងនៅក្នុងអ្នកទោសនោះ តើសេចក្ដីលម្អិតទាក់ទងទៅនឹងអ្នកដែលត្រូវគេចាប់ខ្លួនម្នាក់ៗហ្នឹង កត់ត្រាដោយរបៀបណា លម្អិតប៉ុនណា?

**ឆ៖** ខ្ញុំមិនសូវយល់សំណួរទេ។

**ស៖** នៅលើបញ្ជីដែល ស-២១ បានធ្វើ ខ្ញុំគិតថាគឺមានឈ្មោះរបស់អ្នកទោស តើត្រូវដែរឬទេ?

**ឆ៖** ត្រឹមត្រូវ។

**ស៖** ថាតើមានអ្វីផ្សេងទៀតទេ ជាព័ត៌មានដែលដាក់បញ្ចូល ដាក់ភេទរបស់ជននោះ ទីកន្លែងដែលគេចាប់ខ្លួន អាយុ ឬក៏មានទិដ្ឋភាពអ្វីផ្សេងជាព័ត៌មាន ដែលគេកត់ត្រាដែរដើម្បីកំណត់ថាអត្តសញ្ញាណជននោះក្រៅពីឈ្មោះហ្នឹង មានអ្វីបន្ថែមបាទ?

**ឆ៖** ឯកសារស-២១ វាបញ្ជាក់ហើយ ប៉ុន្តែខ្ញុំសូមរំឭកត្រួសៗ ក្រៅពីឈ្មោះមានភេទ មានអាយុ មានមុខងារ ហើយទីកន្លែងចាប់ខ្លួនហ្នឹង គឺសំដៅអង្គភាពដើមទេ។ មិនមែនយើងទៅចាប់ខ្លួនពីនោះមកទេ ប៉ុន្តែអង្គភាពដើមគេ អង្គភាពណា។ ហើយដល់ក្រោយមកមានកម្ពស់មនុស្សទុំង។ នេះបើតាមខ្ញុំចាំគឺប៉ុណ្ណឹង។

[១៥:៤៧:៥៩]

**ស៖** ខ្ញុំគិតថា លោកបាននិយាយពីខាងដើម ដោយពិនិត្យមើលទៅព័ត៌មានដែលចូលមកស-២១ ពីទីកន្លែងដែលគេចាប់មនុស្សនោះ ធ្វើឲ្យលោកយល់អំពីរចនាសម្ព័ន្ធនៃរបស់បក្សកុម្មុយនីស្តកម្ពុជា តើត្រូវដែរឬទេ?

**ឆ៖** សូមសួរម្តងទៀត ខ្ញុំអត់សូវយល់ទេ។

**ស៖** នៅពេលដែលលោកពិនិត្យមើលចំណងជើង ឬក៏មុខងារមនុស្សនៅក្នុងបញ្ជី តើប្រភេទនៃ-- តើជាចំណងជើងនៅលើឯកសារហ្នឹង គេដាក់ថាអ្វីបាទ?

**ឆ៖** ពិបាកណាស់ បកប្រែ។ ដូច្នេះខ្ញុំសូមនិយាយតាមការយល់ឃើញ ហើយនិងការបានអនុវត្តមិនមែនតាមការយល់ឃើញទេ តាមការបានអនុវត្តទៅចុះ។ ដូចជាឈ្មោះ ប៉ង់ អ៊ីចឹងចូលមក។ គេដាក់ថាប្រធានមន្ទីរសន្តិបាល ស-៧១។ អាហ្នឹងវាច្បាស់ហើយ ពីលើកមុនមក ខ្ញុំមិនដឹង ស-៧១ គឺស្អីទេ ដល់ឃើញអាហ្នឹងៗបានយើងដឹងច្បាស់ថា អ៊ូ! អាហ្នឹងវាមានអង្គភាពមួយ ទូលំទូលាយឈ្មោះស-៧១។ ដូចបញ្ជូនពីខាងចាមពលមក អេង មេងប៊ាង ហៅ ឆុន ដាក់ថាអនុលេខាចាមពល។ អាហ្នឹងយើងដឹងហើយ ថាអ៊ូ!នៅខាងចាមពល វាមានលេខារបស់វាឈ្មោះ ឆាយ គឹមហ៊ ហៅ ហុក, អេង មេងប៊ាង ហៅ ឆុន ជាអនុលេខា។ ហើយដល់យើងសួរទៅបានដឹងថា អ៎! អេង មេងប៊ាង ហៅ ឆុន នេះវាមកពីឧត្តរ។ ហើយ អេង មេងប៊ាង ហៅ ឆុន នេះជាមនុស្សម្នាក់ដែល ប៉ុល ពត ត្រូវការចម្លើយ

បន្ទាន់។ នេះវាមានព័ត៌មានវាហូរហែអ៊ីចឹង។

**ស៖** តើលោកបានពិនិត្យមើលបញ្ជីទាំងអស់របស់ស-២១ ដែរឬទេ ដែលជាផ្នែកមួយនៃការងាររបស់លោកនោះ?

**ឆ៖** អរគុណ។ និយាយតាមពិតខ្ញុំអត់បានពិនិត្យអីស៊ីជម្រៅប៉ុន្មានទេ។ ការងារខ្ញុំមួយថ្ងៃគិតតែធ្វើម៉េចសរុបអាចម្លើយហ្នឹងឲ្យខ្លីៗ ស្រួលឲ្យមេមើល ហើយនិងទាក់ទងនឹងគាត់ត្រូវសួរយ៉ាងម៉េចទៀត គិតគូរយ៉ាងម៉េចទៀត ខ្ញុំទាក់ទងជាប្រចាំជាមួយ សុន សេន ដូចខ្ញុំជម្រាបអ៊ីចឹង។ មួយថ្ងៃយ៉ាងតិចមួយម៉ោង ភាគច្រើនជាមធ្យមយើងគិតថាមួយម៉ោងទៅចុះតាមទូរស័ព្ទ។ ហើយសូមបញ្ជាក់ថា ទូរស័ព្ទខ្ញុំពិសេសណាស់ ចុចប៊ូតុងមួយអ៊ីចឹងទៅតាមផ្លូវ តាមខ្សែ ខ្សែតាមផ្លូវហ្នឹងគ្មាននរណាដោតស្ដាប់បានទេ ប្ដូរ*ហ្វ្រេកង់*អស់ហើយ។

[១៥:៥១:៣១]

**ស៖** ប្រសិនបើលោកមិនបានមើលបញ្ជីដោយលម្អិតទេ តើបើសិនជាលោកមើលបញ្ជី តើបញ្ជីនោះដាក់បញ្ចូលកាលបរិច្ឆេទទេ ដែលគេចាប់ខ្លួនអ្នកជាប់ឃុំនោះ?

**ឆ៖** ចំពោះបញ្ហាកាលបរិច្ឆេទមាន ក៏ប៉ុន្តែចំពោះកាលបរិច្ឆេទនោះវាមានបញ្ហាខ្លះ ខុសពីហ្នឹងបន្តិចដែរ ដែលត្រូវបញ្ជាក់។

**ស៖** តើដាក់បញ្ចូលកាលបរិច្ឆេទដែលមនុស្សនោះត្រូវបញ្ជូនមកស-២១ ដែរឬទេ?

**ឆ៖** ភាគច្រើនគឺសរសេរចុះ កាលបរិច្ឆេទដែលមនុស្សនុំងចូលមកដល់ ស-២១ ប៉ុន្តែវាមានបញ្ហាផ្សេងទៀត។

**ស៖** អ៊ីចឹងគឺថា ដើម្បីឲ្យច្បាស់លោកនិយាយថា វាអាចមានភាពខុសគ្នារវាងកាលបរិច្ឆេទ។ អ៊ីចឹងតើលោកចង់ពន្យល់ម៉េច? បើថាវាមានកាលបរិច្ឆេទអាចមានបញ្ហា ឬក៏មានផ្សេងនោះ លោកពន្យល់បានទេ?

**ស៖** អ្នកទោសសាមញ្ញមកដល់ មកដល់ម៉ោងណា? ថ្ងៃណា? គេកត់ថ្ងៃនុំង។ នេះច្បាស់លាស់ ក៏ប៉ុន្តែអ្នកទោសសំខាន់ មកដល់គេទុកនៅនឹងគុកពិសេស អ្នកសួរក៏ពិសេស អ្នកកត់ក៏មិនទាន់ប៊ានឲ្យកត់ព្រោះខ្លាចបែកការណ៍។ ដូច្នេះកាលបរិច្ឆេទ ដល់ក្រោយមកដាក់ស្មានក៏មានដែរ។ សូមលើកឧទាហរណ៍មួយ ភឹង តុន កាលបរិច្ឆេទខុសគ្នាបី។

[១៥:៥៣:៥៣]

**ស៖** នៅពេលដែលគេបញ្ជូនអ្នកទោសមកដល់ ស-២១ ចូលទៅដល់នោះ គឺថាក្រៅពីការធ្វើបញ្ជីហើយនោះ ថាតើមានការកត់ត្រាព័ត៌មានអ្វីទៀតទេយកពីអ្នកទោសនុ៎ង ក្នុងទម្រង់ឯកសារមួយដែលនៅពេលអ្នកទោសនោះមកដល់?

**ឆ៖** ចូលមកដល់អ្នកទោសត្រូវគេថត។ នេះជាចាំបាច់ហើយ អ្នកណាដែលត្រូវបញ្ជូនទៅព្រៃស គេសួរហើយគេកត់ទុកហ្នឹង គេបញ្ជូនទៅព្រៃស តាមឡានទៅ។ ឯចំណែក បឋម មិត្តហ៊ួ គាត់ត្រូវសួរហើយ រឿងស្អីយ៉ាងម៉េចៗ? គ្រាន់តែសន្និដ្ឋាន មនុស្សណាសំខាន់គាត់មករាយការណ៍ភ្លាម ល្ងាចឡើងគាត់មករាយការណ៍។ មនុស្សនេះសំខាន់បង ដូច្នេះវាមានបញ្ហាហ្នឹង ប៉ុន្តែអត់មានជាលាយ-លក្ខណ៍អក្សរអីទេ។

**ស៖** នៅពេលដែលគេមកដល់ គេថតរូប។ តើមានអ្វីតម្រូវថាឲ្យផ្ដល់ព័ត៌មានអ្វីផ្សេងទៀតទាក់ទងទៅនឹងអ្នកទោសនោះទេ នៅពេលដែលគេបានមកដល់ភ្លាម មកដល់ស-២១ ថាមានតម្រូវឲ្យផ្ដល់ព័ត៌មានអីចឹង ឬក៏មិនមាន?

**ឆ៖** ចូលទៅដល់កន្លែងហើយ បានមិត្ត ហ៊ គាត់សួរ។

**ស៖** ឧទាហរណ៍ថា នៅពេលដែលអ្នកទោស២០នាក់ ដែលគេបញ្ជូនមកដល់ស-២១ តើព័ត៌មានប្រភេទអ្វីដែលស-២១ កត់ត្រាយកពីអ្នកទាំងនោះ? និយាយព័ត៌មានបឋម។

**ឆ៖** ឧបមាថា ២០នាក់ មកពីកងពល១៧០ គេសង្កេតហើយ អ្នកណាថ្នាក់អី? ថ្នាក់អនុសេនាធំ ធំជាងគេ ឬថ្នាក់ណា? ហើយគេសង្កេត តាំងពីអ្នកធំ ដល់អ្នកតូច។ ហើយគេសួរអ្នកធំបន្តិច មួយម៉ាត់ ពីរម៉ាត់ទៅ ដើម្បីយកជាគោល តើមនុស្សនោះ សំខាន់ ឬមិនសំខាន់? ហ្នឹង គេយកប៉ុណ្ណឹង។ ហើយគេរាយការណ៍មកខ្ញុំហើយ ដើម្បីគិតគូរទាំងអស់ តើត្រូវសួរអ្នកណាមុន? ទុកអ្នកណាក្រោយ? អាហ្នឹង យើងលែលកអីចឹង។

**ស៖** ដូច្នេះ ព័ត៌មានបឋមសង្ខេបនេះ តើគេកត់ត្រាដូចម្ដេច? រក្សាទុកដូចម្ដេច?

**ឆ៖** មិត្ត ហ៊ ចូលមកដល់ មករាយការណ៍ឲ្យខ្ញុំ ដូចមិនមានក្រដាសទេ មកមាត់ទទេ។ និយាយជាមួយគ្នាមួយព្រួសនោះ ហើយខ្ញុំក៏ចេញបញ្ហាឲ្យអ្នកណាសួរមនុស្សរូបនេះ អ្នកណាសួរមនុស្សរូបនោះ។

**ស៖** តើប្រវត្តិរូបហ្នឹង គេត្រូវកត់ត្រាពីអ្នកទោសនៅដំណាក់កាលណាទេ ដែលថាជាប្រវត្តិរូបសង្ខេបនោះ?

**ឆ៖** គេមិនឲ្យគំរូប្រវត្តិរូបដែលបង្ហាញនេះ ទៅៗជនជាប់ចោទ ជនរងគ្រោះ សរសេរបំពេញទេ អត់ទេ។ គេឲ្យអ្នកទាំងនុ៎ង សរសេរប្រវត្តិសកម្មភាពក្បត់ តាំងពីដើមទីមក។

**សៈ** តើគេសុំឲ្យអ្នកទាំងអស់នោះ ធ្វើបែបនោះ នៅពេលមកដល់ភ្លាម ឬក៏នៅពេលក្រោយមកដល់?

**ឆ៖** គេសួរសិន។ សួរ-- គេសួរពីរបីម៉ាត់សិន ជជែកជាមួយនឹងគ្នា សួរ បើថាសរសេរប្រវត្តិ-សកម្មភាពក្បត់បាន សរសេរ បើមិនបានទេ គេសួរដេញដោល ឆ្កឹះនាយឆ្កឹះអាយ ស្ទាបស្ទង់នាយអាយ ដើម្បីនឹងឲ្យបានសរសេរ។

[១៥:៥៩:១២]

**លោក វីល្លៀម ស្មីត៖**

សូមអរគុណ។ ឥឡូវនេះ យើងដល់ម៉ោងបួនហើយ លោកប្រធាន ខ្ញុំគិតថាប្រហែលជាខ្ញុំអាចនឹងរក្សាសំណួរខ្លះ សម្រាប់ពេលខាងមុខនោះ បាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ។ អរគុណ សាក្សី។ ឥឡូវនេះ ដល់ពេលសមល្មមនឹងសម្រាកហើយ នូវកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។ អង្គជំនុំជម្រះប្រកាសផ្អាកសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ។ ហើយសវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។

អនុរក្សមន្ទីរឃុំឃាំងឲ្យលោក កាំង ហ្កេកអ៊ាវ ហៅ ឌុច ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញ ហើយនិងឲ្យនាំខ្លួនគាត់មកកាន់កន្លែងផ្ដល់សក្ខីកម្មនេះ នៅព្រឹកថ្ងៃស្អែកឲ្យបានមុនអង្គជំនុំជម្រះចូលកាន់អាសនៈ។ ហើយដូចគ្នា បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទាំងបីរូប ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញ ហើយនិងឲ្យនាំខ្លួនគាត់មកកាន់បន្ទប់សវនាការនេះ នៅព្រឹកថ្ងៃស្អែកឲ្យមុនម៉ោងប្រាំបួន។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០០ នាទី)*